សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

## របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា

# ការគ្រប់គ្រងទិន្នន័យរបស់
# ការិយាល័យស្ថិតិសេដ្ឋកិច្ចតាមវិស័យ

កម្មសិក្សាពីថ្ងៃទី ០១ ខែមេសា ឆ្នាំ ២០១៧ ដល់ថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០១៧

ឈ្មោះស្ថាប័ន៖ **ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

តាក់តែងឡើងដោយ
និស្សិតឈ្មោះ **ហេង សិរីវឌ្ឍន៍**
**ទៀវ លីហុង**

សាស្ត្រាចារ្យណែនាំ
លោក **ឃាង ហ៊ុយ**

ថ្នាក់បរិញ្ញាបត្រ វិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំចូលសិក្សា ២០១៣
ជំនាញ គ្រប់គ្រងធុរកិច្ច ជំនាន់ទី១៦ ឆ្នាំសរសេររបាយការណ៍ ២០១៧

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំជាក្រុមនិស្សិតដែលមានឈ្មោះ ហេង សិរីវឌ្ឍន៍ និង ទៀវ លីហុង ដែលជានិស្សិតបរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាញគ្រប់គ្រងសហគ្រាស ឆ្នាំទី៤ ជំនាន់ទី១៦ ក្រុម$E_4MA_1$ ឆ្នាំសិក្សា២០១៦-២០១៧ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ៖

លោកឪពុក និងអ្នកម្តាយរបស់យើងខ្ញុំទាំងពីរនាក់ដែលបានផ្តល់កំណើត និងខិតខំក្នុងការចិញ្ចឹមបីបាច់ ថែរក្សា ផ្គត់ផ្គង់ និងទំនុកបំរុងដល់យើងខ្ញុំទាំងផ្លូវកាយ និងផ្លូវចិត្ត។ លោកទាំងពីរតែងតែផ្តល់នូវសុភមង្គល និងផ្តល់ជាដំបូន្មានល្អៗ ហើយជាពិសេសនោះគឺបានជម្រុញអោយយើងទាំងពីរខិតខំ ប្រឹងប្រែង តស៊ូ ជម្នះនូវរាល់ការលំបាកទាំងឡាយរហូតដល់យើងទទួលបាននូវចំណេះដឹង និងបញ្ចប់ការសិក្សានេះយ៉ាងរលូន។

ឯកឧត្តមសាកលវិទ្យាធិការ លោកសាកលវិទ្យាធិការរង លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យទាំងអស់នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំអស់ពីកម្លាំងកាយចិត្តក្នុងរយៈពេល៤ឆ្នាំមកនេះ។

លោកគ្រូសាស្ត្រាចារ្យ **ឈាង ហ៊ុយ** ដែលបានចំណាយពេលវេលាដ៏មានតម្លៃរបស់លោកក្នុងការណែនាំ ពន្យល់ ផ្តល់ជាអនុសាសន៍ល្អៗ និងជួយកែសម្រួលអស់ពីប្រាជ្ញាស្មារតីដល់យើងខ្ញុំនៅក្នុងដំណើរការសរសេររបាយការណ៍បញ្ចប់ការសិក្សាមួយនេះ ឲ្យមានភាពល្អប្រសើរ និងទទួលបានភាពជោគជ័យ។

អ្នកគ្រូ សំណាង ផលដេត ដែលបានជួយក្នុងការសម្រួលនូវរាល់ដំណើរការដែលពាក់ព័ន្ធនឹងការសរសេររបាយការណ៍ ពាក្យសុំ និងរាល់សំណើចុះកម្មសិក្សាទាំងអស់។

លោកប្រធានការិយាល័យស្ថិតិសេដ្ឋកិច្ចតាមវិស័យ ដែលបានអនុញ្ញាតក្នុងការផ្តល់ឯកសារដល់ក្រុមយើងខ្ញុំ ក្នុងការធ្វើរបាយការណ៍បញ្ចប់ការសិក្សានេះ ពិសេសមន្ត្រីជំនាញដែលបម្រើការនៅក្នុងការិយាល័យស្ថិតិសេដ្ឋកិច្ចតាមវិស័យដែលបានខ្នះខ្នែងជួយស្វែងរកទិន្នន័យដើម្បីផ្តល់អោយយើងខ្ញុំ ក៏ដូចជាចំណាយពេលក្នុងការបង្ហាត់បង្រៀនផ្ទាល់ រហូតបានជារបាយការណ៍នេះឡើង។

ជាទីបញ្ចប់ យើងខ្ញុំសូមជូនពរដល់ឯកឧត្តម លោក លោកស្រី អ្នកនាង កញ្ញា និងមិត្តរួមថ្នាក់ទាំងអស់អោយជួបប្រទះតែសំណាងល្អ និងទទួលបានពុទ្ធពរទាំង៤ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ដោយឆ្លងកាត់ការសិក្សាថ្នាក់បរិញ្ញាបត្រ វិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាញគ្រប់គ្រងធុរកិច្ច នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចអស់រយៈពេល៤ឆ្នាំមក យើងទទួលបាននូវចំណេះដឹងជាច្រើនលើផ្នែកទ្រឹស្តី ចំណែកឯការសិក្សាស្រាវជ្រាវជាការស្វែងយល់បន្ថែមទៅលើទ្រឹស្តីក្នុងការអនុវត្តន៍ជាក់ស្តែងរបស់អង្គភាពនានា។ ទន្ទឹមនឹងមានចំណេះដឹងផ្នែកទ្រឹស្តី បានយល់ច្បាស់គ្រប់គ្រាន់ហើយ នៅចុងឆ្នាំនៃការបញ្ចាប់ការសិក្សានេះសាកលវិទ្យាល័យបានតម្រូវអោយនិស្សិតចុះកម្មសិក្សាស្រាវជ្រាវ ដើម្បីអនុវត្តន៍ចំពោះអ្វីដែលបានសិក្សាកន្លងមកនេះផងដែរ ។ ដើម្បីជាការឆ្លើយតបទៅនឹងតម្រូវការរបស់សាកលវិទ្យាល័យ យើងខ្ញុំបានសុំចុះកម្មសិក្សា នៅក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយជ្រើសរើសយកប្រធានបទស្តីពី៖ ការគ្រប់គ្រងទិន្នន័យរបស់ការិយាល័យស្ថិតិសេដ្ឋកិច្ចតាមវិស័យ ដើម្បីទទួលបានចំនេះដឹងបន្ថែម និងយល់កាន់តែច្បាស់អំពីការប្រព្រឹត្តទៅនៃដំណើរការការងារជាក់ស្តែង ព្រោះយើងយល់ឃើញថា ដំណើរការគ្រប់គ្រងរបស់រដ្ឋាភិបាលមានសារៈសំខាន់ណាស់ចំពោះការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិនាពេលបច្ចុប្បន្ននេះ ។

ដោយយល់ឃើញថាពីសារៈសំខាន់ខាងលើទើបយើងខ្ញុំបានរៀបចំចងក្រងជារបាយការណ៍ស្រាវជ្រាវបញ្ចប់កម្មសិក្សាក្នុងគោលបំណងអោយមជ្ឈដ្ឋានទូទៅ ក៏ដូចជាខ្លួនឯងផ្ទាល់បានស្គាល់ និងយល់ដឹងអោយកាន់តែច្បាស់ អំពីដំណើរការការងាររបស់រដ្ឋាភិបាល រចនាសម្ព័ន្ធ និងកាតព្វកិច្ចដែលត្រូវធ្វើ ដើម្បីអភិវឌ្ឍន៍ និងថែរក្សាស្ថេរភាពសេដ្ឋកិច្ចជាតិអោយមានតុល្យភាពសេដ្ឋកិច្ច ហើយប្រជាពលរដ្ឋមានការងារធ្វើគ្រប់គ្នា ជាមួយនឹងការទទួលបាននូវប្រាក់ចំណូលសមរម្យទៅតាមជីវភាពរស់នៅប្រចាំថ្ងៃ ។

ជាចុងបញ្ចប់នេះ យើងខ្ញុំសូមប្រសិទ្ធិពរជ័យ ដល់អ្នកអានទាំងឡាយ អោយទទួលបានពុទ្ធពរទាំងបួនប្រការក្នុងដំណើរជីវិតរបស់អ្នក ។ លើសពីនេះទៅទៀតយើងខ្ញុំនឹងរីករាយក្នុងការរិះគន់ដើម្បីស្តាបនាគ្រប់ពេលវេលា។

# មាតិកា

តារាងសម្គាល់អក្សរកាត់ ........ iii

## សេចក្តីផ្តើម

១ លំនាំបញ្ហា ........ ១
២ ចំណោទបញ្ហា ........ ១
៣ គោលបំណងនៃការស្រាវជ្រាវ ........ ២
៤ វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ ........ ២
៥ វិធីសាស្រ្តនៃការស្រាវជ្រាវ ........ ២
៦ អត្ថប្រយោជន៍នៃការស្រាវជ្រាវ ........ ៣
ក ចំពោះអ្នកស្រាវជ្រាវ ........ ៣
ខ ចំពោះការិយាល័យស្ថិតិសេដ្ឋកិច្ចតាមវិស័យ ........ ៤
គ ចំពោះអ្នកស្រាវជ្រាវជំនាន់ក្រោយ ........ ៤
៧ រចនាសម្ព័ន្ធនៃកម្មសិក្សាស្រាវជ្រាវ ........ ៤

## ជំពូកទី១

## រំលឹកទ្រឹស្តី

១.១ និយមន័យនៃការគ្រប់គ្រង ........ ៥
១.១.១ ការគ្រប់គ្រង ........ ៥
១.១.២ ទិន្នន័យ ........ ៦
១.២ អំពីស្ថិតិ ........ ៩
១.៣ ការធ្វើវិនិយោគ ........ ១០
១.៣.១ អ្វីជាការវិនិយោគ ........ ១០
១.៣.២ ប្រភេទនៃការវិនិយោគ ........ ១១
១.៣.៣ ការវិនិយោគផ្ទាល់ពីបរទេស ........ ១២
១.៣.៣.១ សារៈប្រយោជន៍នៃការវិនិយោគផ្ទាល់ពីបរទេស ........ ១២
១.៣.៣.២ កត្តាទាក់ទាញវិនិយោគផ្ទាល់ពីបរទេស ........ ១៣

## ជំពូកទី២

## ស្ថានភាពទូទៅនៅក្នុងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

២.១ ប្រវត្តិទូទៅរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ........ ១៦

២.១.១ ប្រវត្តិនិមិត្តសញ្ញានៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ........ ១៦

២.១.២ ទស្សនៈវិស័យ និងបេសកកម្មរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ........ ១៧

២.១.៣ រចនាសម្ព័ន្ធនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ........ ១៧

២.១.៤ តួនាទី និងមុខងាររបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ........ ២១

២.១.៥ គោលនយោបាយរបស់រដ្ឋាភិបាលចំពោះក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ........ ២៣

២.២ តួនាទី និងភារកិច្ចរបស់នាយកដ្ឋានស្ថិតិ និងការិយាល័យក្រោមឱវាទ ........ ២៦

## ជំពូកទី៣

## ការគ្រប់គ្រងទិន្នន័យរបស់ការិយាល័យស្ថិតិសេដ្ឋកិច្ចតាមវិស័យ

៣.១ ភារកិច្ចរបស់ការិយាល័យស្ថិតិសេដ្ឋកិច្ចតាមវិស័យ ........ ៣៣

៣.១.១ ដំណើរការងារជាក់ស្តែង ........ ៣៣

៣.១.១.១ ការសម្របសម្រួល និងការរក្សាទំនាក់ទំនង ........ ៣៣

៣.១.១.២ ការប្រមូលទិន្នន័យ ........ ៣៤

៣.២ ទិន្នន័យវិនិយោគឯកជនក្នុងស្រុក ........ ៣៥

៣.២.១ ក្រាហ្វិចក្នុងឆ្នាំ២០១៥ ........ ៣៧

៣.២.២ ក្រាហ្វិចក្នុងឆ្នាំ២០១៦ ........ ៣៨

៣.៣ ទិន្នន័យការវិនិយោគឯកជនពីបរទេស ........ ៣៩

៣.៣.១ ការបកស្រាយទិន្នន័យ ........ ៤១

៣.៣.២ ការវិភាគទិន្នន័យផ្ទាល់លើការវិនិយោគឯកជនបរទេស ........ ៤២

៣.៤ ទិសដៅឆ្នាំ២០១៧ របស់ការិយាល័យស្ថិតិសេដ្ឋកិច្ចតាមវិស័យ ........ ៤៣

៣.៥ សារៈសំខាន់របស់របស់ការិយាល័យស្ថិតិសេដ្ឋកិច្ចតាមវិស័យ ........ ៤៦

៣.៦ បញ្ហាប្រឈម ........ ៤៦

៣.៧ ដំណោះស្រាយ ........ ៤៧

៣.៨ ចំនុចខ្លាំង ........ ៤៧

៣.៩ ចំនុចខ្សោយ........................................................................................................................ ៩៨

## សេចក្តីសន្និដ្ឋាន និងអនុសាសន៍

១ សេចក្តីសន្និដ្ឋាន........................................................................................................................ ៩៩
២ អនុសាសន៍ ........................................................................................................................ ៩៩
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# តារាងសម្គាល់អក្សរកាត់

1. MEF : Ministry of Economy and Finance
2. GFS : Government Financial Statistics
3. NBC : National Bank of Cambodia
4. COA : Chart of Account
5. CPI : Consumer Price Index
6. IMF : International Monetary Funds

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

អាចជាមោទនភាពដ៏អស្ចារ្យមួយដល់ខេមរាគ្រប់រូប នៅពេលដែលយើងរំលឹកដល់ភាពរុងរឿងនាសម័យអង្គរ ប៉ុន្តែវាជាស្នាមឈឺចាប់ចាក់ចូលយ៉ាងជ្រៅដែលមិនអាចនឹងបំភ្លេចបានទៅវិញទេ ពេលដែលនឹកឃើញដល់សម័យប៉ុលពត ដែលសេដ្ឋកិច្ចរបស់កម្ពុជាបានធ្លាក់ដល់ចំណុចសូន្យ រចនាសម្ព័ន្ធត្រូវបានបំផ្លាញគ្មានសល់ សំណង់អាគារធំៗសំខាន់ៗបានក្លាយជា គុក ឬ ជាទីរហោឋានដែលត្រូវបានគេបោះបង់ចោល និង បំផ្លាញចោលស្ទើតែទាំងស្រុង ។

សព្វថ្ងៃ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បាននឹងកំពុងខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការអភិវឌ្ឍន៍ជាតិមាតុភូមិ អោយមានភាពឧដ្តុងឧត្តម និងមានកេរ្តិ៍ឈ្មោះរីកសាយពាសពេញក្នុងសកលលោក ។ យោងទៅតាមកិច្ចខិតខំប្រឹងប្រែងទាំងនោះ រាជរដ្ឋាភិបាល បានស្ថាបនានូវរចនាសម្ព័ន្ធនៃការគ្រប់គ្រងប្រទេសដ៏ប្រសើរ ដើម្បីបង្កើនជាប្រសិទ្ធភាព ឈានទៅដល់ការសម្រេចគោលបំណងដែលបានដៅទុក ។ ក្នុងនោះដែរ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការរក្សានិងអភិវឌ្ឍនប្រទេស ។ ស្ថិតនៅក្នុងក្រសួងសេដ្ឋកិច្ចត្រូវបានបែងចែកជារចនាសម្ព័ន្ធគ្រប់គ្រង ដែលមានជាលំដាប់លំដោយទៅតាមឋានានុក្រមយ៉ាងច្បាស់លាស់ ដែលមានអគ្គនាយកដ្ឋានជាច្រើន ហើយនៅក្នុងអគ្គនាយកដ្ឋានមាននាយកដ្ឋានមួយចំនួននិងនៅក្នុងនាយកដ្ឋានមានការិយាល័យមួយចំនួន ដែលបំរើការងារទៅតាមការងារ និងតួនាទីរៀងៗខ្លួន ។

ការិយាល័យស្ថិតិសេដ្ឋកិច្ចតាមវិស័យ ជាការិយាល័យស្ថិតិមួយនៅក្រោមនាយកដ្ឋានស្ថិតិ ដែលធ្វើការវិភាគស្ថិតិមួយចំនួនដែលពាក់ព័ន្ធនិងវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ សព្វថ្ងៃការិយាល័យនេះបានដើរតួនាទីយ៉ាងសំខាន់ ក្នុងការប្រមូល ចងក្រង វិភាគ និងសហការជាមួយក្រសួងដែលពាក់ព័ន្ធមួយចំនួនដើម្បីចេញជាគោលនយោបាយសំរាប់អនុវត្ត ដើម្បីការអភិវឌ្ឍន៍ និងថែរក្សាស្ថេរភាពសេដ្ឋកិច្ច នៅក្នុងប្រទេសអោយមានតុល្យាភាព និងកិត្យានុភាព ។ ដូចដែលមានខាងលើទាំងអស់នេះជាប្រយោជន៍យ៉ាងសំខាន់របស់ ការិយាល័យស្ថិតិសេដ្ឋកិច្ចតាមវិស័យចំពោះរដ្ឋាភិបាល ដែលពុំអាចនឹងខ្វះបាន ។

## ២.ចំណោទបញ្ហា

របាយការណ៍សិក្សាស្រាវជ្រាវនៅក្នុងការិយាល័យស្ថិតិសេដ្ឋកិច្ចតាមវិស័យរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនេះ គឺធ្វើការសិក្សាថាតើរចនាសម្ព័ន្ធគ្រប់គ្រងរបស់ការិយាល័យស្ថិតិសេដ្ឋកិច្ចតាមវិស័យមានលក្ខណ:យ៉ាងដូចម្តេច? តើដំណើរការនៃការប្រមូលទិន្នន័យរបស់ការិយាល័យ

នេះប្រព្រឹត្តទៅដោយវិធីណាខ្លះ? តើការគ្រប់គ្រងរបស់ការិយាល័យនេះមានប្រសិទ្ធិភាព និង មាន អត្ថប្រយោជន៍អ្វីខ្លះដល់សេដ្ឋកិច្ចជាតិនាពេលបច្ចុប្បន្ន និងពេលអនាគត ។

## ៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃរបាយការណ៍ស្រាវជ្រាវនេះគឺផ្តោតសំខាន់ទៅលើប្រតិបត្តិការនៅក្នុង ការិយាល័យ សេដ្ឋកិច្ចតាមវិស័យ នៃក្រសួងសេដ្ឋកិច្ច និងហរិញ្ញវត្ថុ។ គោលបំណងសំខាន់ៗនៃការ ស្រាវជ្រាវនេះមានដូចជា៖

- ស្វែងយល់ពីយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលទៅលើក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ស្វែងយល់អោយបានស៊ីជម្រៅលើការអនុវត្តន៍ជាក់ស្តែងពីប្រតិបត្តិការទិន្នន័យនៅក្នុង ការិយាល័យស្ថិតិសេដ្ឋកិច្ចតាមវិស័យ
- ស្វែងយល់ពីរចនាសម្ព័ន្ធ និងតួនាទីរបស់ការិយាល័យស្ថិតិសេដ្ឋកិច្ចតាមវិស័យ
- ស្វែងយល់ពីប្រសិទ្ធិភាពការងារ និងវិធីសាស្ត្រនៃការដោះស្រាយបញ្ហាប្រឈមរបស់ ការិយាល័យស្ថិតិសេដ្ឋកិច្ចតាមវិស័យ
- ធ្វើសេចក្តីសន្និដ្ឋាន និងផ្តល់ជាអនុសាសន៍ ដើម្បីធ្វើអោយប្រសើរឡើងនូវប្រតិបត្តិការ ទិន្នន័យរបស់ការិយាល័យស្ថិតិសេដ្ឋកិច្ចតាមវិស័យរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ៤. វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ

ដោយសារតែនៅក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានការបែងចែកចេញជានាយកដ្ឋានជា ច្រើនហើយនៅតាមនាយកដ្ឋាននីមួយៗមានការិយាល័យតូចៗតាមផ្នែកយ៉ាងច្រើនទៀតផងដែរ។ ដូចនេះហើយ ការសិក្សាស្រាវជ្រាវនេះនឹងធ្វើការផ្តោតជាសំខាន់ទៅលើតែ ការិយាល័យស្ថិតិសេដ្ឋ កិច្ចតាមវិស័យមួយតែប៉ុណ្ណោះ។ នៅក្នុងការិយាល័យនេះផងដែរ គឺមានការរៀបចំឡើងជាច្រើន វិស័យ ដែលរបាយការណ៍ស្រាវជ្រាវនេះផ្តោតជាលម្អិតខ្លាំង ទៅលើវិស័យវិនិយោគ។ វិស័យវិនិ យោគនេះផងដែរកំពុងតែមានសក្តានុពល និងមានការរីកលូតលាស់ឥតឈប់ឈរ សម្រាប់ប្រទេស កម្ពុជាដែលជាប្រទេសកំពុងអភិវឌ្ឍន៍។ ជាមួយគ្នានេះដែរ របាយការណ៍ស្រាវជ្រាវនេះបានសម្រាំង យកទិន្នន័យដោយផ្ទាល់ពីការិយាល័យស្ថិតិសេដ្ឋកិច្ចតាមវិស័យពីឆ្នាំ ២០១៥ រហូតដល់ឆ្នាំ២០១៦ ផងដែរ។

## ៥.វិធីសាស្ត្រនៃការស្រាវជ្រាវ

កម្មសិក្សាស្រាវជ្រាវនេះ គឺត្រូវការប្រើប្រាស់នូវប្រភពទិន្នន័យពីរប្រភេទផ្សេងគ្នាគឺ ទិន្នន័យបឋម (Primary Data) និងទិន្នន័យបន្ទាប់បន្សំ (Secondary Data) ដើម្បីចងក្រងជានិក្ខេបទនេះឡើងមកបាន។

ទិន្នន័យនេះជាឧបករណ៍ជំនួយយ៉ាងសំខាន់ដែលអាចយល់ដឹងបានកាន់តែច្បាស់ពីការអនុវត្តន៍ជាក់ស្តែងរបស់ការិយាល័យស្ថិតិតាមវិស័យរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មកលើកម្មសិក្សាស្រាវជ្រាវនេះ ។

➢ **ទិន្នន័យបឋម**

ទិន្នន័យបឋម (Primary Data) ដែលទទួលបានមានប្រភពមកពី៖

- ការធ្វើបទសំភាសន៍ជាមួយ នឹងប្រធានការិយាល័យ និងមន្ត្រីមួយចំនួនដែលធ្វើការនៅក្នុងការិយាល័យស្ថិតិសេដ្ឋកិច្ចតាមវិស័យដោយផ្ទាល់
- ការសង្កេតដោយផ្ទាល់លើសកម្មភាពប្រតិបត្តិការទាំងអស់របស់ការិយាល័យ
- បទពិសោធន៍នៃការចុះកម្មសិក្សាជាមួយការបំពេញការងារនៅក្នុងការិយាល័យសេដ្ឋកិច្ចតាម
  វិស័យ
- របាយការណ៍នានា ព្រមទាំងទិន្នន័យដែលការិយាល័យបានចងក្រងទុក គឺទទួលបានមកពីប្រធានការិយាល័យ និងមន្ត្រីដែលពាក់ព័ន្ធ

➢ **ទិន្នន័យបន្ទាប់បន្សំ**

ទិន្នន័យបន្ទាប់បន្សំ (Secondary Data) ដែលពាក់ព័ន្ធនឹងកម្មសិក្សាស្រាវជ្រាវនេះរួមមានដូចជា

- ឯកសារដែលទទួលបានពីប្រភពស្រាវជ្រាវតាមរយៈអ៊ីនធើណេត
- ឯកសារផ្សេងៗនៅបណ្ណាល័យ និងតាមបណ្ណាសាកលវិទ្យាល័យនានា

## ៦. អត្ថប្រយោជន៍នៃកម្មសិក្សាស្រាវជ្រាវ

ជាទូទៅកម្មសិក្សាស្រាវជ្រាវនេះ គឺអាចផ្តល់អត្ថប្រយោជន៍ជាច្រើនដូចជា៖

**ក. ចំពោះអ្នកស្រាវជ្រាវ**

- អាចពង្រីកចំណេះដឹងបន្ថែម និងយល់ដឹងលើទ្រឹស្តីដែលបានសិក្សាកន្លងមក
- ការពិនិត្យឃើញនូវការអនុវត្តន៍ជាក់ស្តែងពីវិធីសាស្ត្រនៃប្រតិបត្តិការទិន្នន័យរបស់ការិយាល័យ
- ការពិចារណា និងផ្សាភ្ជាប់ទ្រឹស្តី និងការអនុវត្តន៍ជាក់ស្តែង

- គំនិត ឬគន្លឹះក្នុងការគ្រប់គ្រងទិន្នន័យអោយមានប្រសិទ្ធិភាព
- បទពិសោធនៃកម្មសិក្សាអាចជួយដល់ការងារជាក់ស្តែង
- យល់ដឹងពីវិធីសាស្រ្តក្នុងការស្វែងរកដំណោះស្រាយ ពេលដែលជួបបញ្ហាប្រឈម
- បង្ហាញអោយសាធារណៈជនបានយល់ដឹងបានស៊ីជម្រៅនូវរចនាសម្ព័ន្ធគ្រប់គ្រង និងតួនាទីរបស់ក្រសួង ជាមួយនឹងការិយាល័យ

**ខ. ចំពោះការិយាល័យស្ថិតិសេដ្ឋកិច្ចតាមវិស័យ**

- ទទួលបានការផ្តល់ជាយោបល់ខ្លះៗសម្រាប់ការកែលម្អ

**គ. ចំពោះអ្នកស្រាវជ្រាវជំនាន់ក្រោយ**

- ផ្តល់ជាចំណេះដឹងទូទៅក្នុងការយល់ដឹងបន្ថែមលើវិស័យវិនិយោគ
- ជាឯកសារក្នុងការស្រាវជ្រាវនានា។

## ៧. រចនាសម្ព័ន្ធនៃកម្មសិក្សាស្រាវជ្រាវ

នៅក្នុងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ បានបែងចែកជាដំណាក់កាលដូចតទៅ៖

- ❖ ដំណាក់កាលទី១៖ កំណត់បញ្ហានៃការស្រាវជ្រាវ
- ❖ ដំណាក់កាលទី២៖ រំលឹកសង្ខេបទ្រឹស្តីដែលទាក់ទងនឹងបញ្ហា
- ❖ ដំណាក់កាលទី៣៖ សិក្សាពីរចនាសម្ព័ន្ធ តួនាទី និងការអនុវត្តន៍ជាក់ស្តែង
- ❖ ដំណាក់កាលទី៤៖ បញ្ហាប្រឈម ដំណោះស្រាយ និងផ្តល់ជាអនុសាសន៍។

# ជំពូកទី១

# រំលឹកទ្រឹស្តី

# ជំពូកទី១
# រំលឹកទ្រឹស្តី

## ១.១ និយមន័យការគ្រប់គ្រងទិន្នន័យ

ការគ្រប់គ្រងទិន្នន័យ គឺអាចសំដៅទៅលើរាល់សកម្មភាពទាំងឡាយ ដែលបានរួមបញ្ចូលជាមួយនឹងជំនាញ ទេពកោសល្យ និងប្រាជ្ញា ដើម្បីសម្រេចបាននូវចំនួនមួយដែលអាចយកជាការបានជាក់លាក់។ ការគ្រប់គ្រងទិន្នន័យនេះដែរ គឺបានមកពីពាក្យថា ការគ្រប់គ្រង+ទិន្នន័យ។

### ១.១.១ ការគ្រប់គ្រង

ការគ្រប់គ្រងមានន័យថា គឺជាដំណើរការធ្វើផែនការ ចាត់តាំង ដឹកនាំ និងត្រួតពិនិត្យ ទៅលើការប្រើប្រាស់ធនធានមនុស្សជាមួយនឹងទិន្នន័យ និងធនធានដទៃទៀត ដើម្បីសម្រេចគោលដៅអង្គភាព ។ចំពោះអ្នកគ្រប់គ្រងវិញ គឺជាអ្នកអនុវត្តន៍ ការងារនៅអង្គភាពមួយ ឬអង្គការចាត់តាំងមួយដោយរៀបចំជាប្រព័ន្ធរបស់មនុស្ស ដើម្បីសម្រេចគោលដៅជាក់លាក់មួយ ។ ក្នុងនោះផងដែរ មុខងារនៃការគ្រប់គ្រងមាន៤គឺ

1. ការធ្វើផែនការ
2. ការចាត់តាំង
3. ការដឹកនាំ
4. ការត្រួតពិនិត្យ។[1]

ក្នុងចំណោមមុខងារទាំង៤នៃការគ្រប់គ្រង មុខងារដំបូងគេ និងសំខាន់ជាងគេនោះគឺផែនការមានន័យថាជាការមើលទៅមុខ ដើម្បីកំណត់គោលដៅ និងពិចារណាលើគ្រប់មធ្យោបាយទាំងអស់ដើម្បីសម្រេចបានគោលដៅនេះ។

ផែនការគឺជាត្រីវិស័យ ដែលបានបង្ហាញអំពីគោលដៅ រឺគោលបំណងរបស់អង្គការចាត់តាំងមួយ ហើយជាការបង្កើតយុទ្ធសាស្ត្រទូទៅដើម្បីប្រមូលផ្តុំ និងសម្របសម្រួលនូវរាល់សកម្មភាពទាំងអស់ផងដែរ។ ក្នុងការធ្វើផែនការមួយគឺត្រូវតែមានការយកចិត្តទុកដាក់ ទើបអាចកាត់បន្ថយនូវការរងឥទ្ធិពលនៃការប្រែប្រួល ហើយធ្វើឲ្យកម្រិតខ្វះខាយ និងគ្រោះថ្នាក់ថយចុះមកត្រឹមកម្រិតអប្បបរមា ព្រមទាំងអាចជួយសម្រួលដល់អ្នកគ្រប់គ្រងបានទៀតផង។

[1] សៀវភៅមូលដ្ឋានគ្រឹះគ្រប់គ្រង សាស្ត្រាចារ្យយ៉ក់ បញ្ញាតី ឆ្នាំ២០១៥-២០១៦ ទំព័រទី៥

ការចាត់តាំងមានន័យថា គឺជាការគ្រប់គ្រង ការរៀបចំ និងទំនាក់ទំនងរបស់មនុស្សរវាងការងារដែលគេត្រូវធ្វើ និងគ្រឿងសំភារៈសម្រាប់ធ្វើជាមួយនឹងការសំរបសំរួលនូវសិទ្ធិអំណាច ដើម្បីសម្រេចបាននូវគោលដៅមួយដែលបានកំណត់។ ជាទូទៅដំណើរការនៃការចាត់តាំងនេះ គឺមានការទាក់ទងនឹងសមាសធាតុ៣គឺ ការបែងចែកការងារ មធ្យោបាយប្រើប្រាស់ និងកម្មករ។ ប្រធានផ្នែក និងអ្នកគ្រប់គ្រងគួរតែយល់ឲ្យបានច្បាស់ថា៖

- តើមុខងាររគេជាអ្វី និងការងារអ្វីដែលគេត្រូវទទួលមកអនុវត្ត?
- តើកាតព្វកិច្ចរបស់គេត្រូវធ្វើអ្វីខ្លះ?
- តើសិទ្ធអំណាចប៉ុនណាដែលគេមាន?
- តើនរណា ជាចៅហ្វាយរបស់គេ?
- តើមាននរណារាយការណ៍អ្វីខ្លះមកឲ្យគេ?

ចំពោះការដឹកនាំគឺមានការទាក់ទងទៅនឹងការណែនាំនិយោជិក ឲ្យធ្វើសកម្មភាពស្របទៅតាមគោលដៅដែលបានកំណត់ទាំងអស់។ អ្នកគ្រប់គ្រងដែលមានប្រសិទ្ធភាពគួរតែមានចំណេះដឹងខាងផ្នែកបច្ចេកទេស និងជំនាញមួយពិតប្រាកដ ដូចជាផ្នែកគណនេយ្យ ផ្នែកគ្រប់គ្រងម៉ាឃិតទីង និងផ្នែកគ្រប់គ្រងបុគ្គលិកជាដើម។ ក្នុងនោះដែរ អ្នកគ្រប់គ្រងល្អម្នាក់គួរតែអនុវត្តឲ្យបាននូវចំនុចល្អមួយចំនួនដូចខាងក្រោម៖

- ត្រូវពិចារណាឲ្យបានគ្រប់ជ្រុងជ្រោយ លើសតិអារម្មណ៍
- ត្រូវដឹង និងទទួលស្គាល់នូវរាល់កំហុសរបស់ខ្លួនដែលបានធ្វើ
- ត្រូវទទួលស្គាល់នូវសមត្ថភាព និងការងារល្អៗដែលបានធ្វើឡើងដោយនិយោជិក
- ការរិះគន់ត្រូវមានលក្ខណៈស្ថាបនាកែលម្អ។

ការត្រួតពិនិត្យ គឺមានការទាក់ទងទៅនឹងការវាយតំលៃ រឺវិនិច្ឆ័យនូវរាល់លទ្ធផលដែលបានសម្រេច ហើយបន្ទាប់មកធ្វើការកែសម្រួលនូវរាល់សកម្មភាពខ្លះៗ ដើម្បីឲ្យទទួលបានជោគជ័យពេញលេញមួយ។ទិន្នន័យគឺជាការប្រមូលផ្តុំនូវពត៌មានសម្រាប់ធ្វើការពិចារណា ត្រួតពិនិត្យ និងប្រើសម្រាប់ការសម្រេច។

### ១.១.២ ទិន្នន័យ

ទិន្នន័យ គឺជាព័ត៌មានដែលមានរូបភាពជាតួលេខ។[2] ទិន្នន័យបានបែងចែកជា២ផងដែរគឺ ទិន្នន័យមានស្រាប់ (Existing Data) និងទិន្នន័យមិនទាន់មាន (Non Existing Data)។ ទិន្នន័យមានស្រាប់បានចែកចេញជា Access និង Non Access។ Access គឺជាទិន្នន័យដុល (Primary) ដែលបានមកដោយមិនមានការកែសម្រួលអ្វីឡើយ។ Non Access គឺជាទិន្នន័យដែលមានការកែច្នៃហើយ (Secondary)។ ចំពោះទិន្នន័យ ដែលមិនទាន់មាន គឺយើងអាចរៀបចំធ្វើការស្ទាបស្ទង់មតិ (Survey) បានផងដែរ។ទិន្នន័យមានបែងចែកជារយៈពេល ខ្លី មធ្យម ឬវែង។ រយៈពេលនេះអាចមានជា នាទី ម៉ោង ថ្ងៃ សប្តាហ៍ ត្រីមាស ឆមាស ឬឆ្នាំ។ ឧទាហរណ៍ ដូចជា ទិន្នន័យលើអាកាសធាតុ គឺគេមើលទៅតាម ថ្ងៃ រីឯទិន្នន័យលើកំណើនសេដ្ឋកិច្ច គឺគេមើលទៅតាមឆ្នាំ។ ទិន្នន័យត្រូវបានប្រមូលតាមរយៈ ការធ្វើជំរឿន ការធ្វើអង្កេត និងការទទួលបានទិន្នន័យរដ្ឋបាលពីប្រភពរដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាល។ ក្នុងនោះដែរជំរឿនមាន៣ប្រភេទគឺ ជំរឿនប្រជារាស្ត្រ ជំរឿនកសិកម្ម និងជំរឿនក្នុងសហគ្រាស។ អង្កេតគឺជាការប្រមូលទិន្នន័យតាមបែបវិទ្យាសាស្ត្រ ពីបុគ្គល គ្រួសារ សហគ្រាស ឬអង្គភាពចាត់តាំងផ្សេងទៀត ដែលអង្គភាព ជ្រើសរើសគំរូ តែប៉ុណ្ណោះត្រូវបានសម្ភាសន៍ ។ មន្ត្រីស្ថិតិ គឺជាមន្ត្រីរាជរដ្ឋាភិបាល ដែលមានសិទ្ធិអំណាចក្នុង ការធ្វើសកម្មភាពស្ថិតិផ្លូវការ ។

ទិន្នន័យដែលយកមកប្រើប្រាស់នាពេលសព្វថ្ងៃនេះភាគច្រើនគឺជាទិន្នន័យសេរីវេលាកាល។ ទិន្នន័យសេរីកាលនេះមានលក្ខណៈ៥ គឺ និន្នាការ រដូវកាល ខួប ប្រែប្រួល និងថេរ។[3] ជាមួយគ្នានេះដែរ ទិន្នន័យមានលក្ខណៈនិន្នាការបានបែងចែកចេញជា២ ដែលមានដូចជា៖




[2]ច្បាប់ស្តីពីស្ថិតិ ជំពូកទី១ មាត្រាទី២ ចំនុចឈ ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០០៥

[3] ប្លង់មេរៀនការព្យាករណ៍ធុរកិច្ច របស់លោកសុខដារ៉ា ឆ្នាំ២០១៦-២០១៧ ទំព័រទី៥

និន្នាការវិជ្ជមានគឺវាមានការកើនឡើងនៅក្នុងន័យកើនទៅលើរហូត។ ក្នុងន័យនេះគឺ ទិន្នន័យមានការឡើងដោយឥតឈប់ឈរ។




និន្នាការអវិជ្ជមានគឺ មានការថយចុះជាលំដាប់យ៉ាងខ្លាំងបើប្រៀបធៀបនឹងចំនុចដំបូង។




ទិន្នន័យមានលក្ខណៈវដ្តរកាលគឺមានការផ្លាស់ប្តូរ និងមានលក្ខណៈសារឡើងវិញ ក្នុងរយៈពេលមួយដែលត្រូវគ្នា។



ទិន្នន័យខួបមានចលនារលក ឡើង និងចុះ ក្នុងរយៈពេលវែង និងមានការប្រែប្រួល។




ទិន្នន័យប្រែប្រួលមានការប្រែប្រួលឥតឈប់ឈរ ដោយមានការឡើងចុះ ពីមួយពេលទៅមួយពេល តាមដែលអាចទៅរួច។




ទិន្នន័យថេរគឺមានការប្រែប្រួលដែរ ប៉ុន្តែវាប្រែប្រួលតិចតួចបំផុត ស្ទើរតែមិនមានការផ្លាស់ប្តូរ។

## ១.២ អំពីស្ថិតិ

ស្ថិតិគឺជាទិន្នន័យដែលបានមកដោយការប្រមូល ការកែច្នៃ ការចងក្រង ការវិភាគ ការបោះពុម្ពនិងការផ្សព្វផ្សាយលទ្ធផលនៃចម្លើយតាមការប្រមូលស្ថិតិឬពីប្រភពទិន្នន័យរដ្ឋបាល។[4] ប្រព័ន្ធស្ថិតិជាតិ គឺជាសមាហរណកម្មនៃទិន្នន័យស្ថិតិថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន និងហេដ្ឋារចនាសម្ព័ន្ធស្ថិតិ រួមបញ្ចូលទាំងទិន្នន័យស្ថិតិផ្លូវការ កម្មវិធីស្ថិតិជាតិ រចនាសម្ព័ន្ធស្ថិតិ ទិន្នន័យស្ថិតិផ្លូវការ និង

[4] ច្បាប់ស្តីពីស្ថិតិ ជំពូកទី១ មាត្រាទី២ ចំនុចក ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០០៥

កម្មវិធីស្ថិតិជាតិ រចនាសម្ព័ន្ធស្ថិតិ និងអង្គភាពស្ថិតិ ក្នុងក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលព្រមទាំង មន្ត្រីស្ថិតិ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងទៀត។ ស្ថិតិគ្រឹះ គឺជាស្ថិតិផ្លូវការស្តីពីសេដ្ឋកិច្ច សង្គមកិច្ច បរិស្ថាន និងប្រជាសាស្រ្ត ដែលជាស្ថិតិមានចរិតទាក់ទងនឹងផ្នែកជាច្រើនកម្រិតជាតិ មូលដ្ឋាន ដែលជាតម្រូវការរបស់រាជរដ្ឋាភិបាលក្នុងការរៀបចំគោលនយោបាយកម្មវិធី និងការវាយតម្លៃក៏ដូចជាការប្រើប្រាស់ដ៏ទូលាយរបស់សហគមន៍ជាតិនិងអន្តរជាតិ។ ស្ថិតិតាមវិស័យ គឺជាស្ថិតិដែលប្រមូលដោយបណ្តាក្រសួងស្ថាប័នរាជរដ្ឋាភិបាលសម្រាប់តម្រូវការផ្ទៃក្នុងផ្ទាល់ខ្លួន និងគោលដៅធ្វើរបាយការណ៍។[5]ស្ថិតិផ្លូវការដែលបានចាត់តាំង គឺជាស្ថិតិដែលបានផលិតដោយក្រសួងស្ថាប័នដែលកំណត់ដោយរាជរដ្ឋាភិបាលដើម្បីបម្រើសំណូមពរព័ត៌មានស្ថិតិរបស់អ្នកធ្វើគោលនយោបាយ ក្នុងការរៀបចំ វាយតំលៃគោលនយោបាយ និងកម្មវិធីសេដ្ឋកិច្ច សង្គមកិច្ចដើម្បីឆ្លើយតបទៅនឹងកិច្ចអភិវឌ្ឍសេដ្ឋកិច្ចសង្គមកិច្ចរបស់ប្រទេស ក៏ដូចជាបម្រើសេចក្តីត្រូវការព័ត៌មានរបស់អ្នកធ្វើសេចក្តីសម្រេចចិត្ត និងអ្នកស្រាវជ្រាវក្នុងសហគមន៍ជាតិនិងអន្តរជាតិដ៏ទូលំទូលាយផងដែរ។

## ១.៣ ការធ្វើវិនិយោគ

យើងធ្វើវិនិយោគដើម្បីបង្កើនប្រាក់ (Make more Money) ។ យើងធ្វើវិនិយោគដើម្បីអោយមានការប្រសើរឡើងដល់ដំណើរការរបស់ក្រុមហ៊ុន។

ទ្រឹស្តីវិនិយោគបានចែងថា គ្មានផលចំណេញណាមួយដែលបានមកដោយពុំមានការដាក់ទុនជាដំបូងនោះទេ ។ ទោះបីជាមានទ្រឹស្តី Arbitrage ចែងថាគេអាចទទួលបានផលចំណេញដោយពុំចាំបាច់ដាក់ទុនក៏ដោយ ប៉ុន្តែនាពេលបច្ចុប្បន្ននេះអ្នកធ្វើប្រតិបត្តិការបែបនេះមានការលំបាកនឹងឆ្លៀតយកចំណេញណាស់ ដោយសារបញ្ញាបច្ចេកវិទ្យាទំនើប និងពត៌មានដែលទទួលបានឥតខ្ចោះពីទីផ្សារ ។ ដូចនេះមានតែការធ្វើវិនិយោគទេដែលអាចធ្វើអោយគេទទួលបានផលចំណេញ ។

### ១.៣.១ អ្វីជាការវិនិយោគ ?

ការអោយនិយមន័យខ្លះៗដល់ការវិនិយោគមានដូចជា៖

- វិនិយោគគឺជាការ (ដាក់ទុន) ផ្តល់ប្រភពធនធាននាពេលបច្ចុប្បន្នដោយសង្ឃឹមថានឹងទទួលបានមកវិញនូវប្រភពធនធានកើនឡើង ឬធ្វើឲ្យដំណើរការរបស់ក្រុមហ៊ុនកាន់តែកើនឡើងបន្តបន្ទាប់នាពេលអនាគត[6] ។

[5] ច្បាប់ស្តីពីស្ថិតិ ជំពូកទី១ មាត្រាទី២ ចំនុចឃ ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០០៥

[6] សៀវភៅមូលដ្ឋានគ្រឹះវិនិយោគ សាស្ត្រាចារ្យ ឈាងហ៊ុយ ឆ្នាំ២០១៥-២០១៦ ទំព័រទី១

- ការវិនិយោគគឺជាការប្រើប្រាស់ ឬការចំណាយមូលនិធិដោយរំពឹងថានឹងទទួលបានចំណូល ឬការកើនឡើងជាទុន (Increase in Capital) អំពីវិនិយោគនោះនាពេលអនាគត។ គេអាចបកស្រាយម្យ៉ាងទៀតថា ការវិនិយោគគឺជាការចំណាយសាច់ប្រាក់ ឬប្រភពផ្សេងៗទៀតក្នុងពេលបច្ចុប្បន្ន ហើយសង្ឃឹមថាទទួលបានប្រាក់ចំណេញនាពេលអនាគត ។
- ការវិនិយោគគឺជាការប្រើប្រាស់ដើម្បីបង្កើនសាច់ប្រាក់ (The use of Money for making more Money) ។ ឧទាហរណ៍៖ ប្រសិនបើអ្នកដាក់សាច់ប្រាក់ក្នុងធនាគារសន្សំ ក្នុងករណីនេះគេបានចាប់ទុកថាអ្នកបានធ្វើការវិនិយោគ ព្រោះថាអ្នកនឹងធ្វើការបង្កើនប្រាក់របស់អ្នកតាមរយៈការធ្វើវិនិយោគនេះ ដោយអ្នកត្រូវទទួលបានការប្រាក់តាមកាលបរិច្ឆេទ ដែលបានព្រមព្រៀងទុកជាមុន ។

បញ្ហាបីសំខាន់ដែលទាក់ទិននឹងការវិនិយោគគឺ បញ្ហាពេលវេលា ហានិភ័យ និងធនលាភ។ ដូចយើងបានដឹងហើយថាការដាក់ទុនវិនិយោគដែលធ្វើឡើងនាពេលបច្ចុប្បន្នគឺត្រូវបានកំណត់ចំនួនមួយដែលច្បាស់លាស់ ប៉ុន្តែបញ្ហាប្រាក់ចំណេញគឺត្រូវការប៉ាន់ស្មានមិនប្រាកដ ពោលគឺមានហានិភ័យ ។

### ១.៣.២ ប្រភេទនៃការវិនិយោគ

មូលនិធិដែលត្រូវបានយកមកធ្វើការវិនិយោគគឺបានមកពីទ្រព្យដែលលមានស្រាប់ ប្រាក់កំចី ការសន្សំការបោះផ្សាយលក់ភាគហ៊ុន សញ្ញាប័ណ្ណ និងប្រភពផ្សេងៗទៀត ។ ជាមួយនឹងប្រភពទុនដែលខ្លួនមាននោះ អ្នកវិនិយោគអាចប្រើប្រាស់តាមមធ្យោបាយជាច្រើនយ៉ាងដើម្បីទទួលបានធនលាភត្រលប់មកពីវិនិយោគវិញ តាមការរំពឹងទុកជាមួយមូលនិធិដែលបានដាក់ទុន ។

គេបែងចែកប្រភេទវិនិយោគជាពីរគឺ៖ វិនិយោគពិត (Real Investment) និង វិនិយោគបែបហិរញ្ញវត្ថុ (Financial Investment) ។ វិនិយោគពិត គឺជាការដាក់ទុនវិនិយោគទៅលើ Real Estate ជាមួយប្រភពធនធានដែលខ្លួនមានក្រៅពីយកប្រភពធនធានទាំងនោះទៅដាក់ទុនលើទីផ្សារហិរញ្ញវត្ថុដោយទិញភាគហ៊ុន សញ្ញាប័ណ្ណ ឬផលិតផលហិរញ្ញវត្ថុដទៃទៀត បុគ្គលទាំងអស់អាចជ្រើសរើសការវិនិយោគរបស់ខ្លួនលើទ្រព្យសម្បត្តិដូចជា សង់សណ្ឋាគារ ឬផ្ទះសំណាក់ សំរាប់ជួល ការទិញដីរាប់ហិចតាដើម្បីសង់ ផ្ទះល្វែង ឬដើម្បីលក់ចេញទៅវិញដើម្បីប្រាក់ចំណេញ សង់រោងចក្រសំរាប់ផលិតកម្ម ទិញរថយន្តក្រុងសំរាប់បំរើសេវាឈ្នួល។ល។ ចំណែកឯការវិនិយោគបែបហិរញ្ញវត្ថុវិញ តាមន័យវិនិយោគ គឺសំដៅទៅលើការដាក់ទុនលើឧបករណ៍ហិរញ្ញវត្ថុ ដូចជា ភាគហ៊ុន សញ្ញាប័ណ្ណក្រុមជាដើម។

### ១.៣.៣ ការវិនិយោគផ្ទាល់ពីបរទេស

ការវិនិយោគផ្ទាល់ពីបរទេស គឺជាការវិនិយោគមួយដែលបង្កើតឡើង ដោយសហគ្រាសមិនមែននៅក្នុងស្រុក ឬសហការជាមួយនឹងសហគ្រាសនៅក្នុងស្រុក ក្រោមការគ្រប់គ្រងដោយជនជាតិបរទេសតាមមធ្យោបាយបង្កើត ពង្រីកសហគ្រាស និងការចូលរួមរបស់សហគ្រាស ដើម្បីផ្តល់លទ្ធភាពដល់អ្នកវិនិយោគអនុវត្តរយៈពេលយូរ និងអនុភាពពិតលើការគ្រប់គ្រងសហគ្រាសនោះ។

ការវិនិយោគផ្ទាល់ពីបរទេសគឺអាស្រ័យទៅតាមបណ្តាប្រទេសនីមួយៗដែលស្ថិតនៅ។ ប្រទេស ខ្លះបានកំណត់អត្ថន័យនៃការវិនិយោគផ្ទាល់ពីបរទេសដោយផ្អែកទៅលើបរិមាណទុនដែលវិនិយោគិនបានចុះបញ្ជីវិនិយោគ។ រីឯប្រទេសខ្លះទៀត បានកំណត់អត្ថន័យនៃការវិនិយោគផ្ទាល់ពីបរទេស ដោយគិតទៅលើលំហូរចេញ លំហូរចូលនៃមូលធនដែលបានវិនិយោគនៅក្នុងប្រទេសខ្លួន មានន័យថាលំហូរចូលដោយវិនិយោគិនបរទេស ដកនឹងលំហូរចេញវិនិយោគិនក្នុងស្រុកទៅវិនិយោគឯបរទេស។

#### ១.៣.៣.១ សារៈប្រយោជន៍នៃការវិនិយោគផ្ទាល់ពីបរទេស

ភាពរីកចម្រើននៃក្រុមហ៊ុនពហុសញ្ជាតិ និងសាជីវកម្មឆ្លងតំបន់ ធ្វើឲ្យផលិតផលសំបូរបែបត្រូវបានបង្កើតឡើង និងផ្សព្វផ្សាយពាសពេញសកលលោក។ ភាពរីកចម្រើនរបស់សាជីវកម្មនេះហើយ គឺបានឆ្លុះបញ្ចាំងឲ្យបានឃើញនូវសារៈប្រយោជន៍របស់ការវិនិយោគផ្ទាល់ពីបរទេស។ លើសពីនេះទៅទៀត ការវិនិយោគផ្ទាល់ពីបរទេស បានធ្វើឲ្យមានសម្ព័ន្ធមេត្រីភាព រវាងវិនិយោគិនបរទេស និងប្រទេសជាម្ចាស់ស្រុក ហើយមានប្រយោជន៍អោយគ្នាទៅវិញទៅមក ជាមួយនឹងការជួយឲ្យមានការរីកចម្រើនខាងផ្នែកសេដ្ឋកិច្ចដល់ប្រទេសទាំងពីរ។

ចំពោះវិនិយោគិនបរទេស សារៈសំខាន់ដែលចាត់ទុកជាកត្តាកំណត់នៃការវិនិយោគផ្ទាល់ពីបរទេសនោះគឺ គុណសម្បត្តិខាងសហគ្រិនភាពឧស្សាហកម្ម បច្ចេកវិទ្យា ធនធានហិរញ្ញវត្ថុ ។ល។ ក្រៅពីនេះ ជំនាញឯកទេស បទពិសោធន៍ បច្ចេកវិទ្យា និងដើមទុនរបស់ពួកគេកាន់តែត្រូវបានពង្រីកយ៉ាងទូលំទូលាយ។ ភាពគ្រប់គ្រាន់ខាងវត្ថុធាតុដើម លទ្ធភាពពង្រីកវិសាលភាពទីផ្សារ ការរកបាននូវកម្លាំងពលកម្មធូរថ្លៃ ទទួលបាននូវការលើកទឹកចិត្តផ្នែកពន្ធគយ ពីសំណាក់ប្រទេសជាម្ចាស់ស្រុក។ ដោយសារតែផលប្រយោជន៍ទាំងនេះហើយ ទើបធ្វើឲ្យវិនិយោគិនបរទេស ខិតខំស្វែងរកទីតាំងថ្មី ក្នុងគោលបំណងបោះទុននៅប្រទេសក្រៅ។

ផលប្រយោជន៍របស់ម្ចាស់ស្រុក គឺទទួលបានធនធានហិរញ្ញវត្ថុ ជំនាញការងារ ចំនេះដឹងនៃការប្រើប្រាស់បច្ចេកវិទ្យាទំនើប បទពិសោធន៍ខាងផ្នែកសហគ្រិនភាព ការកសាងសមត្ថភាពការងារដល់ប្រជាជននាពេលអនាគត។ ផលប្រយោជន៍ទាំងនេះបានចែកចេញជា៧ចំនុចសំខាន់ៗគឺៈ

បង្កើតការងារថ្មី បង្កើនចំណូល បង្កើនលទ្ធភាពនៃការវិនិយោគក្នុងស្រុក ទទួលបាននូវបច្ចេកវិទ្យាទំនើប បង្កើនវិជ្ជាជីវៈដល់បុគ្គលិក កម្មករ បង្កើនការនាំចេញ បង្កើតសមត្ថភាពប្រកួតប្រជែងរវាងក្រុមហ៊ុនក្នុងស្រុក និងបង្កើនសមត្ថភាពប្រជែងឈ្នះនៃក្រុមហ៊ុនក្នុងស្រុកក្នុងក្របខណ្ឌអន្តរជាតិ។ ជាការពិត ការហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេសកាន់តែច្រើន ការងារក៏អាចកើតមានការកើនឡើងកាន់តែច្រើនផងដែរ ហើយនិកម្មភាពកាន់តែត្រូវបានធានាចំពោះប្រទេសជាម្ចាស់ស្រុក។

**១.៣.៣.២ កត្តាទាក់ទាញវិនិយោគផ្ទាល់ពីបរទេស**

ការទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស គឺជាកម្មវត្ថុសំខាន់មួយ និងមានភាពស្មុកស្មាញមួយសម្រាប់ប្រទេសក្រីក្រ និងប្រទេសកំពុងអភិវឌ្ឍន៍ ដោយគេត្រូវឆ្លើយតបជាចាំបាច់នូវសំនួរដែលថា ហេតុអ្វីបានជាទីផ្សារថ្មីមានសារៈសំខាន់ និងចាំបាច់ចំពោះវិនិយោគិនពីបរទេស? ហើយការវិនិយោគផ្ទាល់ពីបរទេសបានផ្តល់ជាផលប្រយោជន៍អ្វីខ្លះ?

នៅក្នុងឆ្នាំ១៩៨៩ សមាគមន៍ពាណិជ្ជករអាមេរិក បានធ្វើការអង្កេត និងស្រាវជ្រាវនៅប្រទេសប្រេស៊ីលអំពី កត្តាដែលធ្វើឲ្យក្រុមហ៊ុនពហុសញ្ជាតិទៅបណ្តាក់ទុននៅប្រទេសនោះ។ លក្ខណៈវិនិច្ឆ័យទាំងនោះរួមមាន៖

- **លក្ខណៈទីផ្សារក្នុងស្រុក**

ជាកត្តាមួយដែលមានសារៈសំខាន់បំផុតចំពោះការទាក់ទាញអារម្មណ៍វិនិយោគិនបរទេសឲ្យពួកគេមកបណ្តាក់ទុនវិនិយោគនៅក្នុងប្រទេសរបស់ខ្លួន។ ទំហំទីផ្សារ និងការរីកចម្រើនខាងផ្នែកសេដ្ឋកិច្ច គឺជាលក្ខណៈវិនិច្ឆ័យបន្ថែមទៀត ដែលវិនិយោគិនប្រើប្រាស់ដើម្បីសម្រេចថា តើកន្លែងណាមួយ ដែលមានសក្តានុពលសមរម្យសម្រាប់ការវិនិយោគរបស់ពួកគេ។ កត្តាធនធានធម្មជាតិ និងតំបន់ភូមិសាស្ត្ររបស់ម្ចាស់ស្រុក ក៏មានសារៈសំខាន់ផងដែរចំពោះ បញ្ហាជ្រើសរើសទីតាំងរបស់វិនិយោគិន ព្រោះវាមានឥទ្ធិពលដល់ការផ្គត់ផ្គង់វត្ថុធាតុដើម សម្រាប់ផលិតកម្ម និងការវេចខ្ចប់ទៅកាន់ទីផ្សារ ពិសេសទាក់ទងក្នុងការចំណាយលើការដឹកជញ្ជូន ដែលមានឥទ្ធិពលដល់ការប្រកួតប្រជែងនៃផលិត ផលនៅលើទីផ្សារ។

- **លទ្ធភាពចូលទៅកាន់ទីផ្សារ**

ច្បាប់ គោលនយោបាយ បទបញ្ញត្តិ ប្រកាសក្នុងស្រុក ជាបញ្ហាមួយដែលអ្នកវិនិយោគទាំងអស់ បានពិចារណា ព្រោះថា បើប្រទេសនោះជាប្រទេសដែលប្រកាន់ទីផ្សារផែនការ ពោលគឺរដ្ឋជាអ្នកគ្រប់គ្រង ហើយដាក់កំហិតលើសេរីភាពរបស់បណ្តាក្រុមហ៊ុនឯកជន ក្នុងដំណើរការអាជីវកម្មរបស់ពួកគេ ប្រទេសនោះមិនមែនជាចំណាត់អារម្មណ៍របស់ពួកអ្នកវិនិយោគឡើយ ។ តែបើជា

ប្រទេសប្រកាន់ទីផ្សារសេរី ព្រមទាំងបើកចំហាទីផ្សារវិញ ប្រទេសទាំងនោះគឺជាទីចាប់អារម្មណ៍របស់អ្នកវិនិយោគបរទេសដែលមិនមានការដាក់កំហិតមិនសមហេតុផល ប្រកួតដោយសេរី និងយុត្តិធម ។

- **កត្តាកម្លាំងពលកម្ម**

ជាកត្តាទាក់ទាញមួយ ដែលអ្នកវិនិយោគសម្លឹងមើល គឺស្វែងរកកម្លាំងពលកម្មមានជំនាញសមស្រប និងកម្រិតថ្លៃឈ្នួលទាប ព្រោះពួកគេរំពឹងដល់កម្រិត ចំណាយនាពេលអនាគត ។ ភាគច្រើនអ្នកវិនិយោគតែងបណ្តាក់ទុន នៅប្រទេសកំពុងអភិវឌ្ឍ ដើម្បីឆក់ឱកាសយកផលប្រយោជន៍ពីការប្រើប្រាស់កម្លាំងពលកម្ម និងចំណាយថ្លៃឈ្នួលទាប ។

- **លទ្ធភាពនៃការដកដើមទុនវិនិយោគ**

វិនិយោគិនបរទេស មានការយកចិត្តទុកដាក់ខ្លាំងណាស់លើច្បាប់ទាំងឡាយណា ដែលប៉ះពាល់ដល់ការដកប្រាក់ទុន និងប្រាក់ចំណេញ ពីប្រទេសម្ចាស់ស្រុកដែលពួកគេធ្វើទៅតាមវិធីផ្សេងៗព្រមទាំងច្បាស់ទម្លាប់សុាំញ៉ាំ ដែលតម្រូវអោយមានការអនុញ្ញាតពីធនាគារជាដើម។ ប្រទេសណា ដែលមានកំហិត លើសកម្មភាពដកទុន ការបែងចែកប្រាក់ចំណេញរបស់ពួកគេធ្ងន់ធ្ងរពេកប្រទេសនោះមិនមែនជាការចាប់អារម្មណ៍របស់អ្នកវិនិយោគទេ។

- **អត្រាពន្ធ និងការលើទឹកចិត្ត**

គន្លឹះសំខាន់ក្នុងការសម្រេចចិត្តបោះទុនវិនិយោគ ទាក់ទងនឹងប្រព័ន្ធពន្ធដារ ដែលមានផលប៉ះពាល់ទៅដល់ដំណើរការប្រតិបត្តិការរបស់ក្រុមហ៊ុន។ ពន្ធគឺជាប្រភពដ៏ធ្ងន់ធ្ងរមិនត្រឹមតែសំដៅលើអត្រាពន្ធប៉ុណ្ណោះទេ គឺយកពន្ធលើភាគលាភផងដែរ ។ ប្រទេសម្ចាស់ស្រុក ត្រូវកំណត់ពន្ធដារអោយមាន កម្រិតទាបដែលអាចទទួលយកបាន ដើម្បីទាក់ទាញអ្នកវិនិយោគអោយកាន់តែច្រើន ។

- **ស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច**

គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងប្រសិទ្ធិភាពនៃការគ្រប់គ្រងនយោបាយ ជាទំនុកចិត្តរបស់អ្នកវិនិយោគបរទេសដែលបំរុងដាក់ទុនមក ។ ប្រទេសដែលបានចាត់ចែងដំណើរការសេដ្ឋកិច្ចបានល្អ មិនបង្កើតមន្ទិលសង្ស័យពីអ្នកវិនិយោគឡើយ ព្រោះអ្នកវិនិយោគទាំងនោះមិនចង់មានការប្រថុយប្រថាន នឹងការបាត់បង់ទ្រព្យរបស់គេពីការវិនិយោគទេ។

- **ហេដ្ឋារចនាសម្ព័ន្ធទ្រទ្រង់ និងផ្គត់ផ្គង់របស់ប្រទេសម្ចាស់ស្រុក**

ប្រទេសម្ចាស់ស្រុកត្រូវមានហេដ្ឋារចនាសម្ព័ន្ធដូចជា ផ្លូវថ្នល់ ស្ពាន កំពង់ផែ ចំណតអាកាសយានដ្ឋាន បណ្ដាញទូរគមនាគមន៍ សេវាថាមពលអគ្គិសនី ប្រព័ន្ធផ្គត់ផ្គង់ទឹក ។ល។ ព្រោះវាមានឥទ្ធិពលយ៉ាងខ្លាំងទៅលើតម្លៃ ប្រសិទ្ធភាពផលិតផល និងការដឹកជញ្ជូន ។ នៅពេលអ្នកវិនិយោគមើលឃើញយ៉ាងនេះហើយ ពួកគេនឹងមកវិនិយោគ ព្រោះវាមានភាពងាយស្រួល និងមានការចំណាយថ្លៃដើមទាបក្នុងផលិតកម្ម ដើម្បីជាការប្រកួតប្រជែង ជាមួយនឹងទីផ្សារអន្តរជាតិ ។

# ជំពូកទី២

# ស្ថានភាពទូទៅនៅក្នុង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

# ជំពូកទី២

# ស្ថានភាពទូទៅនៅក្នុងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## ២.១ ប្រវត្តិទូទៅរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (Ministry of Economy and Finance) មានតួនាទីជាអ្នកគ្រប់គ្រងនូវគោលនយោបាយហិរញ្ញវត្ថុ និងសេដ្ឋកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្រសួងនេះត្រូវបានបង្កើតឡើងសារជាថ្មីជាផ្លូវការនៃរដ្ឋធម្មនុញ្ញទី២នៅក្នុងឆ្នាំ១៩៩៣។ ក្នុងនោះផងដែរគឺមានផ្លាស់ប្តូររដ្ឋមន្ត្រីចំនួន៣រូប[7] ដែលមានដូចជា៖

| ឈ្មោះ | យកការិយាល័យ | អនុញ្ញាតឱ្យការិយាល័យ |
|---|---|---|
| សម រង្ស៊ី | ថ្ងៃទី 24 ខែកញ្ញាឆ្នាំ 1993 | ថ្ងៃទី 24 ខែតុលាឆ្នាំ 1994 |
| គាត ឈន់ | ថ្ងៃទី 24 ខែតុលាឆ្នាំ 1994 | ថ្ងៃទី 24 ខែកញ្ញាឆ្នាំ 2013 |
| អូនព័ន មុនីរ័ត្ន | ថ្ងៃទី 24 ខែកញ្ញាឆ្នាំ 2013 | បិតថេររហូតដល់បច្ចុប្បន្ន |

### ២.១.១ ប្រវត្តិនិមិត្តសញ្ញានៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

[7] https://en.wikipedia.org/wiki/Ministry_of_Economy_and_Finance_(Cambodia) ចូលទស្សនាថ្ងៃទី ៩ ខែកក្កដា ឆ្នាំ ២០១៧

ប្រវត្តិនៃរូបហង្សនេះ បានចាប់កំណើតនៅក្នុងរជ្ជកាលព្រះបាទអង្គឌួង កំឡុងឆ្នាំ១៨៩៧ ទ្រង់បានចេញរាជបញ្ជាឲ្យមន្ត្រីបោះប្រាក់បាតសម្រាប់ចាយជាបឋម។ នៅជុំវិញតែមមានដាក់ពាក្យថា «ព្រះនគរក្រុងកម្ពុជាធិបតី» ដែលមានព្រះពុទ្ធសករាជ និងមហាសករាជ។ នៅចំផ្ទៃកណ្តាលមានរូបប្រាសាទអង្គរវត្ត និងនៅផ្ទៃម្ខាងទៀតមានរូបហង្សជាតំណាង។ រូបហង្សនេះ គឺតំនាងឲ្យនាមព្រះសំអាង ហង្ស ដែលជាចាងហ្វាងម្នាក់បានទៅរៀនសូត្រនៅប្រទេសថៃ បានចេះវិជ្ជាបោះប្រាក់នេះឯង។ ដោយហេតុដូចនេះហើយទើបយើងឃើញរូបហង្សនេះ ត្រូវបានយកមកជារូបតំណាងឲ្យក្រសួងសេដ្ឋកិច្ច និង ហារិញ្ញវត្ថុ នារជ្ជកាលព្រះបាទ នរោត្តម សីហនុ ក្នុងសម័យសាធារណរដ្ឋខ្មែរ (លន់ ណុល) រហូតមកដល់ពេលបច្ចុប្បន្ននេះ។[8] ប្រភពមួយទៀត គេបានបកស្រាយថា រូបហង្សដែលឈរនៅកណ្តាល គឺតំណាងឲ្យសេដ្ឋកិច្ច និង ហិរញ្ញវត្ថុរបស់ជាតិទាំងមូល។ ចំណែករូបគួរស្រូវ គឺតំណាងឲ្យកសិកម្មប្រទេសកម្ពុជាដែលប្រជាជនខ្មែរប្រមាណ៨០% គឺជាកសិករ។[9]

### ២.១.២ ទស្សនៈវិស័យ និងបេសកម្មរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ទស្សនៈវិស័យ និងបេសកម្មរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គឺសំដៅធ្វើយ៉ាងណា ធានានូវកំណើន និងមានការអភិវឌ្ឍន៍ប្រកបដោយចីរភាព។ ក្នុងន័យនេះដែលមានន័យថា គឺក្រសួងបានអះអាងក្នុងការធ្វើឲ្យមានការកើនឡើងនូវក្នុងវិស័យហិរញ្ញវត្ថុរបស់ជាតិ។ ចំពោះការអភិវឌ្ឍន៍ដោយចីរភាពវិញ គឺជាការរិះរកមធ្យោបាយគ្រប់បែបយ៉ាងដើម្បីឲ្យប្រទេសមានការរីកចម្រើនជានិរន្តទៅពេលខាងមុខផងដែរ។

មិនតែប៉ុណ្ណោះក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបានបំពេញមុខងារជាសេនាធិការឲ្យរាជរដ្ឋាភិបាល លើបេសកកម្មដឹកនាំ និងគ្រប់គ្រងលើវិស័យហិរញ្ញវត្ថុទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងគោលដៅអភិវឌ្ឍសេដ្ឋកិច្ច និងលើកតម្កើងជីវភាពរបស់ប្រជាជន ដោយឈរលើគោលការណ៍សេដ្ឋកិច្ចទីផ្សារ និងសមធម៌សង្គម។ នៅក្នុងបេសកកម្មនេះដែរ ត្រូវបានធ្វើឡើងតាមរយៈការរៀបចំ និងអនុវត្តអោយបានត្រឹមត្រូវនូវគោលនយោបាយ ក្របខណ្ឌច្បាប់ និងបទបញ្ជាទាំងឡាយ ដែលមានការទាក់ទងទៅនឹងម៉ាក្រូសេដ្ឋកិច្ច ហិរញ្ញវត្ថុសាធារណៈ ទ្រព្យសម្បត្តិរដ្ឋ កិច្ចការវិនិយោគ និងឧស្សាហកម្មហិរញ្ញវត្ថុ ព្រមទាំងច្បាប់និងបទបញ្ជាផ្សេងៗទៀតផងដែរ។

### ២.១.៣ រចនាសម្ព័ន្ធនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

រចនាសម្ព័ន្ធគ្រប់គ្រងត្រូវបានបែងចែកជា ៥ ថ្នាក់: រដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គលេខាធិការ និងអគ្គលេខាធិការរង។ពួកគេទទួលខុសត្រូវលើការគ្រប់គ្រងក្នុងការចែកចាយនិងការបែងចែកថវិកាដើម្បីបង្កើតគោលនយោបាយលើការអនុវត្ត និងលើកកម្ពស់គោលនយោបាយដែលមានស្រាប់ក្នុងការបន្ថែមផ្នែកដែលត្រូវបានជ្រើសរើសនិងមន្ទីរដែលបានពង្រីកនៅតាមសាខាខេត្ត។ កម្រិតនៃអំណាចក្នុងការអនុម័តថវិកា និងការអនុវត្តគោលនយោបាយថវិកា

[8] http://swiftnewsdaily.com/archieves/15001 ចូលទស្សនាថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០១៧

[9] http://youtu.be/tB4Fgtr4Dmc ចូលទស្សនាថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០១៧

និងថវិកាត្រូវបានផ្អែកលើថ្នាក់បឋមសិក្សានិងអនុវិទ្យាល័យនៃតួលេខរដ្ឋបាល។ ការិយាល័យរដ្ឋបាលសំខាន់ៗស្ថិតនៅរាជធានីភ្នំពេញខណ: ដែលសាខាខេត្តស្ថិតនៅតាមរាជធានីនៃខេត្តនីមួយៗ។

យោងតាមអនុក្រឹត្យលេខ ៨៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអនុក្រឹត្យលេខ ៩៥ អនក្រ.បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការដំឡើងវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រចនាសម្ព័ន្ធស្ថាប័នរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានដូចខាងក្រោម៖

អង្គការលេខរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



អគ្គលេខាធិការដ្ឋាន អគ្គធិការដ្ឋាន អគ្គនាយកដ្ឋាន នាយកដ្ឋាន ក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ[10]៖

**អគ្គលេខាធិការដ្ឋាន៖**

[10] (www.mef.gov.kh n.d.) ចូលទស្សនានៅថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ២០១៧

- នាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ
- នាយកដ្ឋានបុគ្គលិក
- នាយកដ្ឋាននីតិកម្ម
- នាយកដ្ឋានព័ត៌មានវិទ្យា
- មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានីខេត្ត

**អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ**

- នាយដ្ឋានគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងសារពើពន្ធ
- នាយកដ្ឋានស្ថិតិ
- នាយកដ្ឋានសមាហរណកម្មសេដ្ឋកិច្ច និងអាស៊ាន

**អគ្គនាយកដ្ឋានថវិកា៖**

- នាយកដ្ឋានកិច្ចការទូទៅ
- នាយកដ្ឋានថវិកានីយកម្ម
- នាយកដ្ឋានហិរញ្ញកិច្ច
- នាយកដ្ឋានវិនិយោគ

**អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ៖**

- នាយកដ្ឋានគ្រប់គ្រងរដ្ឋបាល និងបច្ចេកទេស
- នាយកដ្ឋានគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលរាជធានី ខេត្ត
- នាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលក្រុង ស្រុក
- នាយកដ្ឋានគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលឃុំ សង្កាត់

**អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ៖**

- នាយកដ្ឋានរដ្ឋបាល បុគ្គលិក និងផែនការ
- នាយកដ្ឋានគ្រប់គ្រងលទ្ធកម្មទំនិញ
- នាយកដ្ឋានគ្រប់គ្រងលទ្ធកម្មសំណង់និងសេវា
- នាយកដ្ឋានគ្រប់គ្រងលទ្ធកម្មរដ្ឋបាលថ្នាក់ក្រោមជាតិ
- នាយកដ្ឋានត្រួតពិនិត្យនិងដោះស្រាយវិវាទ

**អគ្គនាយកដ្ឋានគយនិងរដ្ឋាករ៖**

- នាយកដ្ឋានរដ្ឋបាល និងគ្រប់គ្រង
- នាយកដ្ឋាន ផែនការ បច្ចេកទេស និងកិច្ចការអន្តរជាតិ
- នាយកដ្ឋានកិច្ចការច្បាប់ សវនកម្ម និងទំនាក់ទំនងសាធារណៈ
- នាយកដ្ឋានបង្ការ និងបង្ក្រាបបទល្មើស
- នាយកដ្ឋានរដ្ឋាករ
- នាយកដ្ឋានរបបគយ

- នាយកដ្ឋានគ្រប់គ្រងតំបន់រួចពន្ធ
- លេខាធិការដ្ឋាន
- ថ្នាក់មូលដ្ឋាន

**អគ្គនាយកដ្ឋានពន្ធដារ៖**

- នាយកដ្ឋានបុគ្គលិក និងរដ្ឋបាលហិរញ្ញវត្ថុ
- នាយកដ្ឋានច្បាប់ វិវាទ និងស្ថិតិ
- នាយកដ្ឋានសេវាអ្នកជាប់ពន្ធ និងបំណុលពន្ធ
- នាយកដ្ឋានត្រួតពិនិត្យ
- នាយកដ្ឋានព័ត៌មានវិទ្យា
- នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ
- នាយកដ្ឋានសវនកម្មសហគ្រាស
- ថ្នាក់មូលដ្ឋាន

**អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ៖**

- អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ
- នាយកដ្ឋានសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ
- នាយកដ្ឋានចំណូលពីទ្រព្យសម្បត្តិរដ្ឋ
- នាយកដ្ឋានចំណូលសាធារណៈ
- នាយកដ្ឋានសហគ្រាសសាធារណៈ

**អគ្គនាយកដ្ឋានរតនាគារជាតិ៖**

- នាយកដ្ឋានរដ្ឋបាល និងបុគ្គលិក
- នាយកដ្ឋានចំណូលចំណាយថវិកា
- នាយកដ្ឋានគណនេយ្យ
- នាយកដ្ឋានគ្រប់គ្រងបេឡា និងបំណុល
- នាយកដ្ឋានគ្រប់គ្រងរតនាគារថ្នាក់មូលដ្ឋាន និងសរុបស្ថិតិ
- នាយកដ្ឋានព័ត៌មានវិទ្យា
- អធិការកិច្ចរតនាគារ
- ថ្នាក់មូលដ្ឋាន

**អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ៖**

- នាយកដ្ឋានធានារ៉ាប់រង និងសោធន
- នាយកដ្ឋានទីផ្សារ និងស្ថាប័នហិរញ្ញវត្ថុ
- នាយកដ្ឋានគ្រប់គ្រងអាជីវកម្មភ្នាល់ និងប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- នាយកដ្ឋានគ្រប់គ្រងអាជីវកម្មអចលនវត្ថុ បញ្ចាំ និងប្រាក់ភោគដោយអនុប្បទាន

**អគ្គាធិការដ្ឋានៈ**

- នាយកដ្ឋានរដ្ឋបាល ផែនការ និង សិក្សាស្រាវជ្រាវបណ្តឹង
- នាយកដ្ឋានអធិការកិច្ចហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ជាតិ
- នាយកដ្ឋានអធិការកិច្ចហិរញ្ញវត្ថុរដ្ឋបាលថ្នាកក្រោមជាតិ

**អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងៈ**

- នាយកដ្ឋានសវនកម្មផ្ទៃក្នុងថ្នាក់កណ្តាល
- នាយកដ្ឋានសវនកម្មផ្ទៃក្នុងថ្នាក់មូលដ្ឋាន
- នាយកដ្ឋានសវនកម្មបច្ចេកវិទ្យាព័ត៌មាន

**វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

- នាយកដ្ឋានបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុ
- នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ
- នាយកដ្ឋានស្រាវជ្រាវ និងអភិវឌ្ឍ

**អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍**

- នាយកដ្ឋានកិច្ចការទូទៅ
- នាយកដ្ឋានត្រួតពិនិត្យផ្ទៃក្នុងនិងគ្រប់គ្រងទិន្នន័យ
- នាយកដ្ឋានដោះស្រាយផលប៉ះពាល់ទី១
- នាយកដ្ឋានដោះស្រាយផលប៉ះពាល់ទី២
- នាយកដ្ឋានដោះស្រាយផលប៉ះពាល់ទី៣

**អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល**

- នាយកដ្ឋានសហប្រតិបត្តិការទ្វេភាគី
- នាយកដ្ឋានសហប្រតិបត្តិការពហុភាគី
- នាយកដ្ឋានគ្រប់គ្រងបំណុល
- នាយកដ្ឋានកិច្ចការទូទៅ

អគ្គនាយកដ្ឋាន ដឹកនាំដោយអគ្គនាយកមួយរូប និងអមដោយនាយករងមួយចំនួនជាជំនួយ។នាយកដ្ឋាននីមួយៗ ដឹកនាំដោយប្រថានមួយរូប ដែលអមដោយអនុប្រធានមួយចំនួនជាជំនួយការ ។ លេខាធិការដ្ឋាន ដឹកនាំដោយប្រថាមួយរូប មានឋានៈស្មើអនុប្រធាននាយកដ្ឋានដែលអមដោយអនុប្រធានមួយចំនួន មានឋានៈស្មើប្រធានការិយាល័យជាជំនួយការ ។ ការិយាល័យនីមួយៗដឹកនាំដុយប្រធានមួយរូបដែលអមដោយអនុប្រធានមួយចំនួនជាជំនួយការ ។

### ២.១.៤ តួនាទី និងមុខងាររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបានបំពេញមុខងារជាសេនាធិការអោយរដ្ឋាភិបាលលើបេសកម្ម ដឹកនាំ និងគ្រប់គ្រងលើវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៃព្រះរាជាណាចក្រកម្ពុជា ក្នុង

គោលដៅអភិវឌ្ឍសេដ្ឋកិច្ច និងលើកតម្កើងជីវភាពប្រជាជន ដោយឈរលើគោលការណ៍សេដ្ឋកិច្ចទីផ្សារ និងសមធមិសង្គម ។

បេសកម្មនេះត្រូវធ្វើឡើងតាមរយៈការរៀបចំ និងអនុវត្តឲ្យបានត្រឹមត្រូវនូវគោលនយោបាយក្របខណ្ឌច្បាប់ និងបទបញ្ញត្តិទាំងឡាយ ដែលទាក់ទងម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ ដូចជាទ្រព្យសម្បត្តិ កិច្ចការវិនិយោគ និងឧស្សាហកម្មហិរញ្ញវត្ថុ ព្រមទាំងច្បាប់ និងបទបញ្ញាដែលពាក់ព័ន្ធផ្សេងៗ ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានមុខងារ និងតួនាទីដូចតទៅ ៖

- រៀបចំ អនុវត្តនិងតាមដានការអនុវត្តន៍គោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរបស់រដ្ឋាភិបាល
- គ្រប់គ្រង និងសម្របសម្រួលកិច្ចការកែទម្រង់រចនាសម្ព័ន្ធសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ពង្រឹងអភិបាលកិច្ចល្អ ទៅលើអ្វីដែលជាប់ពាក់ព័ន្ធនឹងការគ្រប់គ្រងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ
- វិភាគតាមដាន និងព្យាករណ៍ស្ថានភាពសេដ្ឋកិច្ចរយៈពេលខ្លី មធ្យម និងរយៈពេលវែង និងដាក់ចេញនូវវិធានការដើម្បីតម្រង់ទិស និងកែលម្អការគ្រប់គ្រងសេដ្ឋកិច្ច
- សហការជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធ ដើម្បីដឹកនាំ និងចូលរួមក្នុងការរៀបចំនូវគោលនយោបាយយុទ្ធសាស្ត្ររាជរដ្ឋាភិបាលទៅលើកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងកិច្ចសមាហរណកម្មកម្ពុជា ទៅក្នុងសេដ្ឋកិច្ចពិភពលោក ពិសេស កិច្ចការសមាហរណកម្មសេដ្ឋកិច្ចកម្ពុជាក្នុងក្របខណ្ឌអាស៊ាន
- កសាងប្រព័ន្ធហិរញ្ញវត្ថុឲ្យឯកភាពទូទាំងប្រទេស ហើយធានាអនុវត្តប្រព័ន្ធនេះអោយបានត្រឹមត្រូវតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងច្បាប់ហិរញ្ញវត្ថុគ្រប់គ្រងឆ្នាំនីមួយៗ ព្រមទាំងច្បាប់ពាក់ព័ន្ធ និងបទបញ្ញាដទៃទៀត
- ធ្វើការបែងចែក និងបែងចែកឡើងវិញ នូវផលទុនជាតិតាមរយៈការប្រមូលចំណូល និងកម្មវិធីនីយកម្ម នៃចំនាយសាធារណៈ
- រៀបចំ និងកសាងសេចក្តីព្រាងច្បាប់និងបទបញ្ញាផ្សេងៗ សម្រាប់គ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាលក្ខណៈប្រចាំឆ្នាំនីមួយៗ ឬជាលក្ខណៈអចិន្ត្រៃយ៍
- រៀបចំនិងគ្រប់គ្រងថវិការដ្ឋ
- រៀបចំនិងអនុវត្តគោលនយោបាយចំណូលថវិកាជាតិ
- ប្រមូលចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ បង់ចូលបេឡាថវិការដ្ឋ ធ្វើតារាងតុល្យភាព និងវិភាគគណនីនៃប្រតិបត្តិការរបស់រដ្ឋ

- គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
- ចូលរួមកសាង និងអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រគៀគរហិរញ្ញប្បទាននៅក្រៅប្រទេស និងទទួលបន្ទុកគ្រប់គ្រងបំណុលសាធារណៈនៃបណ្តាក្រសួងស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណ៍ៈរដ្ឋបាល អង្គភាពដទៃទៀត និងដៃគូរឯកជនសាធារណៈ
- ទទួលបន្ទុកដឹកនាំ រៀបចំជម្រុញអនុវត្ត តាមដានការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល
- វិភាគ គ្រប់គ្រង និងតាមដានការវិវត្តនៃវិស័យហិរញ្ញវត្ថុ ព្រមទាំងចូលរួមរៀបចំព្រមទាំងអនុវត្តក្របខណ្ឌគ្រប់គ្រងហានិភ័យនៃហិរញ្ញវត្ថុ ដើម្បីធានាស្ថេរភាពហិរញ្ញវត្ថុ
- អភិវឌ្ឍ គ្រប់គ្រង និងត្រួតពិនិត្យកិច្ចការឧស្សាហកម្មហិរញ្ញវត្ថុ រួមមានការធានារ៉ាប់រង និងសោធន ទីផ្សារនិងស្ថាប័នហិរញ្ញវត្ថុ
- ចូលរួមរៀបចំ អនុវត្តគោលនយោបាយ ក្របខណ្ឌនៃការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម
- គ្រប់គ្រង និងត្រួតពិនិត្យអាជីវកម្មល្បែងភ្នាល់គ្រប់ប្រភេទ
- ធ្វើអធិការកិច្ចលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមក្រសួង ស្ថាប័ន ឫអង្គការសាធារណៈប្រហាក់ប្រហែលអង្គភាពសាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលអនុវត្តប្រតិបត្តិការថវិការដ្ឋ
- បំពេញមុខងារបេឡាករ និងគណនេយ្យករសាធារណៈរបស់រដ្ឋាភិបាល ព្រមទាំងរៀបចំគោលការណ៍ និងបទបញ្ញាគណនេយ្យករសាធារណៈ
- បំពេញមុខងារសវនកម្មផ្ទៃក្នុង
- បណ្តុះបណ្តាល ធ្វើវិក្រឹតការជាប្រចាំនូវជំនាញសេដ្ឋកិច្ច ហិរញ្ញវត្ថុ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ដល់មន្ត្រីក្រសួងសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នពាក់ព័ន្ធនានា
- អនុវត្តការងារគ្រប់គ្រងហិរញ្ញវត្ថុ សម្រាប់ការអភិវឌ្ឍន៍ តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

### ២.១.៥ គោលនយោបាយរបស់រដ្ឋាភិបាលចំពោះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គោលដៅជាយុទ្ធសាស្ត្ររបស់រដ្ឋាភិបាលនីតិកាលទី៤ គឺការបន្តទាក់ទាញទុនវិនិយោគឯកជន ទាំងក្រៅប្រទេស ទាំងក្នុងស្រុកតាមរយៈការបន្តពង្រឹងបរិស្ថានអំណោយផលដល់ការវិនិយោគ

និងធុរៈកិច្ច ការបន្តកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការជំរុញធ្វើពិធីកម្មឧស្សាហកម្ម ការលើកស្ទួយសហគ្រាសធុនតូច និងមធ្យម និងការធ្វើទំនើបកម្មសហគ្រាស ការបន្តពង្រឹងក្របខណ្ឌគតិយុត្ត ការបន្តអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស និងកិច្ចសម្រួលពាណិជ្ជកម្ម និងការបន្តពង្រីកច្រកចូលទៅកាន់ទីផ្សារអន្តរជាតិ ព្រមទាំងពង្រឹងភាពជាដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជន ។

ក្នុងគោលដៅនេះរដ្ឋាភិបាលបានសម្រេចបានសមិទ្ធផល សំខាន់ៗយ៉ាងច្រើនជាអាទិ៍ ការកែលំអក្របខណ្ឌគតិយុត្ត ការកែលំអកិច្ចសម្រួលពាណិជ្ជកម្ម រួមមានការកាត់បន្ថយចំណាយធុរៈកិច្ច ការកំណត់កម្រៃ និងស្តង់ដានៃសេវាកម្មសាធារណៈ ក៏ដូចជាការកាត់បន្ថយ និងសម្រួលនីតិវិធីរដ្ឋបាល ព្រមទាំងការពង្រីកទីផ្សារអន្តរជាតិ តាមរយៈការចូលរួមក្នុងតំបន់ពាណិជ្ជកម្ម និងកិច្ចព្រមព្រៀងអនុគ្រោះពាណិជ្ជកម្ម ។ ទន្ទឹមនឹងនេះដែរ តំបន់សេដ្ឋកិច្ចពិសេសចំនួន៨ បានដំណើរការហើយបានទាក់ទាញការវិនិយោគពីប្រភពថ្មី និងក្នុងវិស័យថ្មីៗ រួមមានរោងចក្រកែច្នៃម្ហូបអាហារ រោងចក្រផ្គុំដំឡើង រោងចក្រគ្រឿងអេឡិចត្រូនិច ជាដើម ។ លើសពីនេះភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងវិស័យឯកជនត្រូវពង្រឹងបន្ថែម និងលើកកម្ពស់ថែមទៀត តាមរយៈកិច្ចដំណើរការប្រកបដោយ ប្រសិទ្ធិភាពនៃ « **វេទិការសារាចរដ្ឋាភិបាល ផ្នែកឯកជន** » និងយន្តការពាក់ព័ន្ធ ។ ជាតួលេខ បើគិតតែការវិនិយោគផ្ទាល់ពីបរទេស កម្ពុជាទទួលបានក្នុងទំហំជាមធ្យមប្រមាណ ៧០០ លានដុល្លារក្នុងមួយឆ្នាំជាមួយនឹងការបង្កើតការងារថ្មីជាមធ្យមក្នុងមួយឆ្នាំប្រមាណ២សែនកន្លែង ។ទន្ទឹមនឹងនេះ ការនាំចេញរបស់កម្ពុជាមានការកើនឡើងជាបន្តបន្ទាប់ ហើយនៅឆ្នាំ២០១២ សម្រេចបាន ៥៥០០ លានដុល្លារ ខណៈមុខទំនិញនាំចេញ ក៏មានចំនួនកាន់តែច្រើនជាងមុន ។[11]

ទោះជាយ៉ាងនេះក្តី ការអភិវឌ្ឍន៍វិស័យឯកជនកម្ពុជានៅបន្តជួបប្រទះ បញ្ហាប្រឈមមួយចំនួន ពិសេសប្រសិទ្ធិភាពនៃប្រព័ន្ធឡជីស្ទីក និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រ ចំណាយធុរៈកិច្ចនៅតែខ្ពស់នៅឡើយ បើធៀបជាមួយនឹងប្រទេសក្នុងតំបន់ ផលិតភាព និងសមត្ថភាព ជំនាញរបស់ផលិតករនៅមិនទាន់ឆ្លើយតបនឹងសេចក្តីត្រូវការរបស់ទីផ្សារ ភាពចំបាច់ក្នុងការពង្រឹងសមត្ថភាពរបស់សហគ្រាសធុនតូច និងមធ្យម ព្រមទាំងភាពចំបាច់ក្នុងការពង្រឹងក្របខណ្ឌគតិយុត្ត និង ស្ថាប័ន ។

នៅលើមូលដ្ឋាននេះរដ្ឋាភិបាលនីតិកាលទី៥ ដាក់ចេញជាគោលដៅជាយុទ្ធសាស្ត្រពីរគឺៈ (១) ការបន្តជំរុញអភិវឌ្ឍវិស័យឯកជនអោយកាន់តែមានភាពរស់រវើក និងមានជីវភាពខ្លាំងថែមទៀត ក្នុងតួនាទីជាក្បាលម៉ាស៊ីននៃកំនើនសេដ្ឋកិច្ច (២)ការប្រែក្លាយកម្ពុជាអោយទៅជាគោលដៅ

[11] សៀវភៅយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣ នីតិកាលទី៥ ចុះខែកញ្ញាឆ្នាំ២០១៣ ទំព័រទី៧៤

វិនិយោគប្រកប ដោយភាពទាក់ទាញ និងភាពប្រកួតប្រជែងនៅក្នុងតំបន់ ពិសេសក្នុងក្របខណ្ឌសហគមន៍សេដ្ឋកិច្ចអាស៊ាន ។

ដើម្បីសម្រេចគោលដៅនេះរាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើះ

1. ការជំរុញលើកទឹកចិត្តការវិនិយោគក្នុងវិស័យឧស្សាហកម្មទំនើប ដែលមានតំលៃបន្ថែមខ្ពស់ ក្នុងទិសដៅលើកម្ពស់ពិពិធកម្មមូលដ្ឋានផលិតកម្ម ។
2. ការជំរុញលើកទឹកចិត្តការវិនិយោគនៅទីជនបទ ដែលនឹងចូលរួមដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ ការកាត់បន្ថយគម្លាតរវាងទីក្រុង និងជនបទក៏ដូចជាការលើកស្ទួយជីវភាពរបស់ប្រជាជន និងកាត់បន្ថយចំណាក់ស្រុក ពីជនបទមកទីក្រុង និងចំណាកស្រុករកការងារធ្វើនៅក្រៅប្រទេស ។
3. ការបន្តធ្វើទំនើបកម្មសហគ្រាសក្នុងស្រុក និងការលើកកម្ពស់គំនិតច្នៃប្រឌិត ព្រមទាំងការផ្សារភ្ជាប់គ្នារវាងសហគ្រាស និងឧស្សាហកម្មក្នុងស្រុក ជាមួយនឹងគំរោងវិនិយោគមកពីក្រៅប្រទេស ក្នុងគោលដៅស្រូបយកបច្ចេកវិទ្យា ចំណេះដឹង ចំណេះធ្វើ បង្កើនផលិតភាព បង្កើនភាពទាក់ទាញ និងភាពប្រកួតប្រជែងរបស់កម្ពុជា ។
4. ការបន្តពង្រឹងបរិស្ថានអនុគ្រោះ សម្រាប់ការវិនិយោគ និងធុរៈកិច្ចតាមរយៈការបន្តកែលំអក្របខណ្ឌគតិយុត្ត ធ្វើការពិចារណាកម្មរបបលើកទឹកចិត្តសម្រាប់គម្រោងវិនិយោគការបន្តពង្រឹងក្របខណ្ឌអភិបាលកិច្ច និងប្រសិទ្ធិភាពនៃស្ថាប័នសាធារណៈ រួមទាំងពង្រឹងយន្តការ «**ច្រកចេញ ចូល**» នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។
5. ការបន្តកែលំអ កិច្ចសំរួលពាណិជ្ជកម្មតាមរយៈការកែសម្រួលតម្រង់បែបបទ នីតិរដ្ឋបាល និងយន្តការនៃការដឹកជញ្ជូនឆ្លងកាត់ព្រំដែន ការកាត់បន្ថយចំណាយធុរៈកិច្ច ព្រមទាំងការពង្រឹងកិច្ចសម្របសម្រួលអន្តរស្ថាប័ន។
6. ការបង្កើតការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ព្រមទាំងកែលម្អសេវានិងមធ្យោបាយសម្រាប់សម្រួល និងគាំទ្រដល់កិច្ចដំណើរការធុរកិច្ច រួមទាំងការបន្តពង្រឹង និងអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេស។
7. ការបន្តពង្រឹងអភិបាលកិច្ចសាជីកម្ម សម្រាប់ភាពរឹងមាំ និងភាពធំធាត់របស់វិស័យឯកជន និងសម្រាប់លើកកម្ពស់វប្បធម៌គណនេយ្យភាពចំពោះសង្គម។
8. ការបន្តពង្រឹងប្រសិទ្ធភាពនៃយន្តការ វេទិការាជរដ្ឋាភិបាល ផ្នែកឯកជន ក្នុងការដោះស្រាយបញ្ហាប្រឈមនានា ដែលវិស័យឯកជនជួបប្រទះហើយបន្ថែមលើនេះ លើកកម្ពស់

ឲ្យទៅជាយន្តការសម្រាប់ការពិភាក្សាផ្តល់ជម្រើស និងអនុសាសន៍គោលនយោបាយនានា ដើម្បីបង្កើនតួនាទីរបស់វិស័យឯកជន ជាតួអង្គក្នុងកិច្ចការអភិវឌ្ឍន៍។

9. ការពង្រឹងសេវាថែទាំការវិនិយោគដើម្បីដោះស្រាយបញ្ហារបស់វិនិយោគិនឲ្យទាន់ពេលវេលា។

10. ការពង្រឹងយន្តការតាមដានត្រួតពិនិត្យការអនុវត្តគម្រោងវិនិយោគដើម្បីធានាការអនុវត្តត្រឹមត្រូវតាមគោលការណ៍ និងលក្ខខណ្ឌកំណត់។

## ២.២ តួនាទី ភារកិច្ច របស់នាយកដ្ឋានស្ថិតិ និងការិយាល័យក្រោមឱវាទ

ដោយអនុលោមតាមប្រកាសលេខ ៣១៨ សហវ.ប្រក ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ នាយកដ្ឋានស្ថិតិ និងការិយាល័យក្រោមឱវាទ មានភារកិច្ចដូចខាងក្រោម៖

នាយកដ្ឋានស្ថិតិ បំពេញមុខងារជាសេនាធិការឲ្យអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ លើការងារស្ថិតិ ក្រោមបាវចនា "ចងក្រង វិភាគ និងផ្សព្វផ្សាយ" មានភារកិច្ចដូចជា៖

- រៀបចំ បង្កើត និងគ្រប់គ្រងប្រព័ន្ធទិន្នន័យរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយថែទាំប្រព័ន្ធ និងធ្វើបច្ចុប្បន្នកម្មទិន្នន័យជាប្រចាំ
- ប្រមូលផ្តុំ ចងក្រង និងធ្វើសំយោគទិន្នន័យចាំបាច់នានា រួចវិភាគទិន្នន័យ និងវិភាគនិន្នាការថ្មីៗ នៃសូចនាករសេដ្ឋកិច្ច និងហិរញ្ញវត្ថុសំខាន់ៗ
- ទទួលបន្ទុកចងក្រង វិភាគ និងរៀបចំរបាយការណ៍អំពីតារាងប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋ និងស្ថិតិហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល
- ទទួលបន្ទុកបោះពុម្ព និងផ្សព្វផ្សាយទិន្នន័យស្ថិតិសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈព្រឹត្តិបត្រប្រចាំខែ និងតាមរយៈគេហទំព័រ
- រៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រ ដើម្បីបង្កើតស្ថិតិថ្មីៗ ទៅតាមតម្រូវការចាំបាច់
- រៀបចំ និងអនុវត្តកម្មវិធីសិក្សាស្រាវជ្រាវ និងវិភាគស្ថិតិពាក់ព័ន្ធផ្សេងៗ
- ទទួលបន្ទុកការងាររៀបចំផ្លាស់ប្តូរ ពីកាប្រើប្រាស់ទម្រង់របាយការណ៍តារាងប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋទៅការប្រើប្រាស់ទម្រង់របាយការណ៍ ស្ថិតិហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាលតាមស្តង់ដារអន្តរជាតិ
- ទទួលបន្ទុកសម្របសម្រួលជាមួយក្រសួងស្ថាប័នជាតិ និងអន្តរជាតិនានាអំពីការងារស្ថិតិ
- ទទួលបន្ទុកតាមដានតម្លៃទំនិញ សេវា សម្ភារៈ និងបរិក្ខារសម្រាប់បម្រើឲ្យការងារគ្រប់គ្រងលទ្ធកម្មសាធារណៈ

- ទទួលបន្ទុកតាមដានតម្លៃប្រេងក្នុងស្រុក តម្លៃប្រេងនាំចូល និងតម្លៃប្រេងនៅទីផ្សារអន្តរជាតិប្រចាំសប្តាហ៍ និងរៀបចំរបាយការណ៍
- ចុះសង្កេត និងវាយតម្លៃដល់ទីកន្លែង អំពីការវិវត្តនៃទិន្នន័យ និងសូចនាករសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ចូលរួមការងាររៀបចំថវិកា សម្រាប់រៀបចំច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងប្រចាំឆ្នាំ បំពេញតួនាទី និងភារកិច្ចផ្សេងៗទៀត តាមការចាត់តាំងរបស់អគ្គនាយក នៃអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ ឬថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

  នាយកដ្ឋានស្ថិតិមានការិយាល័យក្រោមឱវាទចំនួន៤ ដូចខាងក្រោម៖

- ការិយាល័យស្ថិតិហិរញ្ញវត្ថុសាធារណៈ
- ការិយាល័យស្ថិតិម៉ាក្រូសេដ្ឋកិច្ច
- ការិយាល័យស្ថិតិវិស័យហិរញ្ញវត្ថុ និងពាណិជ្ជកម្ម
- ការិយាល័យស្ថិតិសេដ្ឋកិច្ចតាមវិស័យ

ក្នុងដើមឆ្នាំ២០១៧នេះ នាយកដ្ឋានស្ថិតិ និងការិយាល័យក្រោមឱវាទ កំពុងបំពេញការងារ និងភារកិច្ច ដូចខាងក្រោម៖[12]

| ប្រភេទការងារ ឬ កិច្ចការ | ចំនួនមន្ត្រីទទួលបន្ទុក | ឈ្មោះ និងតួនាទី |
|---|---|---|
| នាយកដ្ឋានស្ថិតិ | | |
| -ការពិនិត្យ និងដឹកនាំការងាររួមក្នុងនាយកដ្ឋាន | ០១ | លោក ឆូវ សុមេធា ប្រធាននាយកដ្ឋាន |
| -ជំនួយការប្រធាននាយកដ្ឋាន ទទួលបន្ទុកការិយាល័យស្ថិតិហិរញ្ញវត្ថុសាធារណៈ | ០១ | លោក ហាប់ ចាន់ធា អនុប្រធាននាយកដ្ឋាន |
| -ជំនួយការប្រធាននាយកដ្ឋាន ទទួលបន្ទុកការិយាល័យស្ថិតិ ម៉ាក្រូសេដ្ឋកិច្ច | ០១ | លោក សុខ ខន អនុប្រធាននាយកដ្ឋាន |
| -ជំនួយការប្រធាននាយកដ្ឋាន ទទួលបន្ទុកការិយាល័យស្ថិតិវិស័យហិរញ្ញវត្ថុ និងពាណិជ្ជកម្ម | ០១ | លោក ឃឹម សុភា អនុប្រធាននាយកដ្ឋាន |
| -ជំនួយការប្រធាននាយកដ្ឋាន ទទួលបន្ទុកការិយាល័យស្ថិតិសេដ្ឋកិច្ច | ០១ | លោក ឃឹម ហ្សាដាណេ អនុប្រធាននាយកដ្ឋាន |

[12] (www.mef.gov.kh n.d.) ចូលទស្សនានៅថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ២០១៧

| | | |
|---|---|---|
| ការងារស្រង់ថ្លៃទំនិញ និងសេវាលើទីផ្សារ (Market Prices)<br>• ចុះប្រមូល និងរៀបចំរបាយការណ៍ស្រង់ថ្លៃទំនិញ និងសេវាលើទីផ្សារភ្នំពេញ និងតាមបណ្តាលខេត្ត ប្រចាំត្រីមាស ឆមាស និងឆ្នាំ<br>• រៀបចំតារាងថ្លៃទំនិញ និងសេវាលើទីផ្សារសម្រាប់ រាជធានីភ្នំពេញ និងតាមបណ្តាលខេត្ត ប្រចាំត្រីមាស ឆមាស និងឆ្នាំ<br>• ចងក្រងថ្លៃទំនិញ-សេវាប្រចាំខែ សម្រាប់គេហទំព័រក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១០ រូប | **ក្រុមការងារនាយកដ្ឋាន៖**<br>លោក ឆូវ សុមេធា ប្រធាននាយកដ្ឋាន<br>លោក សុខ ខន អនុប្រធានាយកដ្ឋាន<br>លោក ស្រៀង ចន្ទី ប្រធានការិយាល័យ<br>កញ្ញា វ៉ាន់ អជីត្តា អនុប្រធានការិយាល័យ<br>លោក យន សារ៉ែន មន្ត្រី<br>លោក ឌឿ សុខលាភ មន្ត្រី<br>លោក នី សុផានិត មន្ត្រី<br>លោក ឆៃ ពុទ្ធី មន្ត្រី<br>លោក ជា សុខឃីមរាជ មន្ត្រីជាប់កិច្ចសន្យា<br>លោក ស្រេង សោភ័ណរស្មី មន្ត្រីជាប់កិច្ចសន្យា |
| **-ការងាររៀបចំព្រឹត្តិបត្រស្ថិតិសេដ្ឋកិច្ច និងហិរញ្ញវត្ថុប្រចាំត្រីមាស (BULLETIN)**<br>• ចងក្រង វិភាគ និងផ្សព្វផ្សាយស្ថិតិទិន្នន័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុប្រចាំត្រីមាស<br>• ផលិតព្រឹត្តបត្រសេដ្ឋកិច្ច និងហិរញ្ញវត្ថុប្រចាំត្រីមាស<br>• សិក្សាពីវិវត្តស្ថានភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុរយៈពេលខ្លី | ១២ រូប | **ក្រុមការងារនាយកដ្ឋានស្ថិតិ៖**<br>លោក ឃឹម ហ្វាដាណោ អនុប្រធាននាយកដ្ឋាន<br>លោក ស្រៀង ចន្ទី ប្រធានការិយាល័យ<br>លោកស្រី ឃុន មារតី អនុប្រធានការិយាល័យ<br>លោក ហេង បណ្ឌូល មន្ត្រី<br>លោក យន សារ៉ែន មន្ត្រី<br>លោក ឌឿ សុខលាភ មន្ត្រី<br>លោក នី សុផានិត មន្ត្រី<br>លោក ឆៃ ពុទ្ធី មន្ត្រី<br>លោក អឿន វិច្ឆ័រ មន្ត្រីជាប់កិច្ចសន្យា<br>លោក យ៉ន សម្បត្តិ មន្ត្រីជាប់កិច្ចសន្យា<br>លោក ស្រេង សោភ័ណរស្មី មន្ត្រីជាប់កិច្ចសន្យា |

| | | |
|---|---|---|
| | | លោក ផល្លា នរិន្ទរស្មី មន្ត្រីជាប់កិច្ចសន្យា |
| **-ការងាររៀបចំ និងអភិវឌ្ឍឃ្លាំងផ្ទុកទិន្នន័យ (MEF Database)**<br>• ចងក្រងស្ថិតិទិន្នន័យគ្រប់វិស័យ<br>• រៀបចំ និងអភិវឌ្ឍន៍កម្មវិធី (MEF Database application)<br>• ធ្វើបច្ចុប្បន្នភាព និងផ្សព្វផ្សាយស្ថិតិទិន្នន័យជាប្រចាំ<br>• បណ្តុះបណ្តាលស្តីពីការប្រើប្រាស់ MEF Database | ១១ រូប | **ក្រុមការងារនាយកដ្ឋានស្ថិតិ៖**<br>លោក យឹម ហ្វាដាណោ អនុប្រធាននាយកដ្ឋាន<br>លោក ស្រៀង ចន្ទី ប្រធានការិយាល័យ<br>លោក ហេង បណ្ឌូល មន្ត្រី<br>លោក យន សារ៉ែន មន្ត្រី<br>លោក ឌឿ សុខលាភ មន្ត្រី<br>លោក នី សុផានិត មន្ត្រី<br>លោក ឆៃ ពុទ្ធី មន្ត្រី<br>លោក អឿន វិច្ឆរ មន្ត្រីជាប់កិច្ចសន្យា<br>លោក យ៉ន សម្បត្តិ មន្ត្រីជាប់កិច្ចសន្យា<br>លោក ស្រេង សោភ័ណរស្មី មន្ត្រីជាប់កិច្ចសន្យា<br>លោក ផល្លា នរិន្ទរស្មី មន្ត្រីជាប់កិច្ចសន្យា |
| **-ការងារសម្របសម្រួលការចុះតាមដាន និងពិគ្រោះយោបល់លើទិន្នន័យស្ថិតិ និងការវិវត្តស្ថានភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅ បណ្តាខេត្តគោលដៅ**<br>• ចងក្រង និងបច្ចុប្បន្នភាពស្ថិតិទិន្នន័យគ្រប់វិស័យ<br>• រៀបចំរបាយការណ៍សង្ខេបស្តីពីការវិវត្តស្ថានភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុប្រចាំឆមាស និងឆ្នាំ | ០៧ រូប | **ក្រុមការងារនាយកដ្ឋានស្ថិតិ៖**<br>លោក យឹម ហ្វាដាណោ អនុប្រធាននាយកដ្ឋាន<br>លោក ស្រៀង ចន្ទី ប្រធានការិយាល័យ<br>លោក ហេង បណ្ឌូល មន្ត្រី<br>លោក យន សារ៉ែន មន្ត្រី<br>លោក ឌឿ សុខលាភ មន្ត្រី<br>លោក នី សុផានិត មន្ត្រី<br>លោក ឆៃ ពុទ្ធី មន្ត្រី |
| ការិយាល័យស្ថិតិហិរញ្ញវត្ថុសាធារណ: | | |
| -ក្តាប់រួមនិងទទួលបន្ទុកគ្រប់គ្រងប្រតិបត្តិការ និងការងារប្រចាំថ្ងៃរបស់ការិយាល័យ ស្ថិតិហិរញ្ញវត្ថុសាធារណ:<br>-ត្រួតពិនិត្យ ផ្ទៀងផ្ទាត់ទិន្នន័យ TOFE/GFS | ០១ | លោកស្រី ហាង់ វិសុទ្ធ ប្រធានការិយាល័យ |

| | | |
|---|---|---|
| -ការងាររៀបចំតារាងប្រតិបត្តិការហិញ្ញវត្ថុរដ្ឋ(TOFE)<br>• ចងក្រង និងវិភាគទិន្នន័យជាធាតុចូល TOFE<br>• តាមដាននិងវិភាគបំណុល<br>• តាមដាននិងវិភាគការសន្សំ<br>• ត្រួតពិនិត្យសង្គតិភាពទិន្នន័យជាមួយ BOP<br>• រៀបចំទិន្នន័យ Loans Grant និងទិន្នន័យ account ពី NBC<br>• ពង្រីកវិសាលភាព TOFE<br>• រៀបចំតារាងតុល្យភាព និងរៀបចំ PASS ដែលទទួលបានពីរតនាគារជាតិ<br>• ចេញរបាយការណ៍ប្រចាំខែ | ០៣ | លោកស្រី ហាង់ វិសុទ្ធ ប្រធានការិយាល័យ<br>លោកស្រី សែម សំណាង អនុប្រធានការិ.<br>លោក ស្រេង សោភ័ណរស្មី មន្ត្រីជាប់កិច្ចសន្យា |
| -រៀបចំតារាងទិន្នន័យចំណូល ចំណាយ និងអត្ថបទធាតុចូលសម្រាប់របាយការណ៍និន្នាការសេដ្ឋកិច្ច (Flash Report)និង Bulletin ប្រចាំខែ | ០១ | លោក ស្រេង សោភ័ណរស្មី មន្ត្រីជាប់កិច្ចសន្យា |
| -ការងាររៀបចំស្តង់ដារស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល (GFS)<br>• ប្រមូល ចងក្រង និងវិភាគទិន្នន័យសម្រាប់ធាតុចូល GFS<br>• បន្សុីគណនី COA ជាមួយលេខកូដ GFS<br>• ត្រួតពិនិត្យសង្គតិភាពទិន្នន័យជាមួយគណនីម៉ាក្រូសេដ្ឋកិច្ចដ៏ទៃទៀត<br>• ពង្រីកវិសាលភាពទិន្នន័យ GFS<br>• ចេញរបាយការណ៍ប្រចាំខែ | ០២ | លោកស្រី ហាង់ វិសុទ្ធ ប្រធានការិយាល័យ<br>លោក យ៉ន សម្បត្តិ មន្ត្រីជាប់កិច្ចសន្យា |
| ការិយាល័យស្ថិតិម៉ាក្រូសេដ្ឋកិច្ច | | |

| | | |
|---|---|---|
| -ការងាររៀបចំរបាយការណ៍និន្នាការសេដ្ឋកិច្ច-សង្គម (FLASH REPORT)<br>• សម្របសម្រួល ប្រមូល និងចងក្រងទិន្នន័យពីការិយាល័យពាក់ព័ន្ធ<br>• រៀបចំ និងវិភាគទិន្នន័យតាមវិស័យ ដូចជា៖ ការវិវត្តនៃថ្លៃទំនិញប្រើប្រាស់ វិស័យហិរញ្ញវត្ថុ ពាណិជ្ជកម្ម ការអនុវត្តថវិកា វិនិយោគឯកជន ទេសចរណ៍ និងវិស័យសំណង់ និងនិន្នាការថ្លៃទំនិញសំខាន់លើទីផ្សារអន្តរជាតិដូចជា ថ្លៃប្រេងឆៅ ថ្លៃអង្ករ និងថ្លៃកៅស៊ូ<br>• ចេញរបាយការណ៍ប្រចាំខែ | ០៥ រូប | លោក សុខ ខន អនុប្រធាននាយកដ្ឋាន<br>លោក អឿន វិច្ឆរ មន្ត្រីជាប់កិច្ចសន្យា<br>លោក ផល្លា នរិន្ទរស្មី មន្ត្រីជាប់កិច្ចសន្យា<br>លោក នី សុផានិត មន្ត្រី<br>លោក ផៃ ពុទ្ធី មន្ត្រី |
| -ការងាររៀបចំរបាយការណ៍ការវិវត្តថ្លៃទំនិញប្រើប្រាស់នៅរាជធានីភ្នំពេញ (CPI)<br>• សម្របសម្រួល ប្រមូល និងចងក្រងទិន្នន័យ<br>• វិភាគ និងព្យាករណ៍អតិផរណា<br>• សិក្សាស្ថានភាពអតិផរណាប្រទេសជាតិខាង និងការ វិវត្តនៃសន្ទស្សន៍ថ្លៃម្ហូបអាហារសកល<br>• ចេញរបាយការណ៍ប្រចាំខែ | ០២ រូប | លោក សុខ ខន អនុប្រធាននាយកដ្ឋាន<br>លោក នី សុផានិត មន្ត្រី |
| | | |
| ការិយាល័យស្ថិតិវិស័យហិរញ្ញវត្ថុ និងពាណិជ្ជកម្ម | | |
| - ប្រមូល ចងក្រង និងផ្សព្វផ្សាយទិន្នន័យពាណិជ្ជកម្មអន្តរជាតិរបស់កម្ពុជា ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ។<br>- រៀបចំរបាយការណ៍ដែលជាធាតុចូលសម្រាប់ Bulletin, Flash Report, MEF database និងសម្រាប់ថ្នាក់ដឹកនាំ។<br>- រៀបចំ និងផ្តល់ទិន្នន័យពាណិជ្ជកម្មទៅតាមតម្រូវនាយកដ្ឋានពាក់ព័ន្ធ។ | ២ រូប | លោក ហាក់ សុផល ប្រធានការិយាល័យ<br>លោក យន សារ៉ែន មន្ត្រី |
| - ប្រមូល ចងក្រង និងផ្សព្វផ្សាយទិន្នន័យរូបិយវត្ថុរបស់កម្ពុជា ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ។<br>- រៀបចំរបាយការណ៍ដែលជាធាតុចូលសម្រាប់ Bulleting, Flash Report, MEF data base និង សម្រាប់ថ្នាក់ដឹកនាំ។<br>- រៀបចំ និងផ្តល់ទិន្នន័យរូបិយវត្ថុទៅតាមតម្រូវនាយកដ្ឋានពាក់ព័ន្ធ។ | ២ រូប | លោក ហាក់ សុផល ប្រធានការិយាល័យ<br>លោក ជា សុខឃីមរាជ មន្ត្រី |
| - រៀបចំ និងចងក្រងទិន្នន័យ REEF ប្រចាំខែ ត្រីមាស និងឆ្នាំ | ៣ រូប | កញ្ញា វ៉ាន់ អជីត្តា អនុប្រធានការិយាល័យ |

| | | |
|---|---|---|
| - សិក្សាស្រាវជ្រាវ និងរៀបចំរបាយការណ៍ REER ប្រចាំត្រីមាស និងឆ្នាំ | | លោក ជា សុខឃីមរាជ មន្ត្រី<br>លោក យន សារ៉ែន មន្ត្រី |
| - រៀបចំរបាយការណ៍និន្នាការថ្លៃប្រេងប្រចាំត្រីមាស ឆមាស និងឆ្នាំ<br>- សម្របសម្រួលប្រមូល និងចែកចាយទិន្នន័យរវាង NBC និងអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុជាប្រចាំ | ១ រូប | លោក ជា សុខឃីមរាជ មន្ត្រី |
| ២.៥.ការិយាល័យស្ថិតិសេដ្ឋកិច្ចតាមវិស័យ | | |
| -ក្តាប់រួម និងគ្រប់គ្រងដឹកនាំការងារប្រចាំថ្ងៃរបស់ការិយាល័យ | ០១ រូប | លោក ស្រៀង ចន្ទី ប្រធានការិយាល័យ |
| -ការងាររៀបចំរបាយការណ៍ទិន្នន័យស្ថិតិតាមវិស័យ ដូចជា៖ កសិកម្ម, សំណង់, វិនិយោគឯកជន, ទេសចរណ៍, ឧស្សាហកម្ម និងសិប្បកម្ម សម្រាប់ធាតុចូលរបាយការណ៍ប្រចាំខែ/ត្រីមាស, ព្រឹត្តបត្រស្ថិតិសេដ្ឋកិច្ច និងហិរញ្ញវត្ថុប្រចាំត្រីមាស (Bulletin), និងរបាយការណ៍ FLASH ប្រចាំខែ<br>-សម្របសម្រួល ប្រមូល និងចងក្រងទិន្នន័យស្ថិតិតាមវិស័យដូចជា៖ ថាមពលអគ្គីសនី, ពាណិជ្ជកម្មអន្តរជាតិ, ពលកម្មនិងការងារបណ្តុះបណ្តាលវិជ្ជាជីវៈ, ប្រៃសណីយ៍និងទូរគមនាគមន៍, និងការដឹកជញ្ជូន<br>-ផ្តល់ប្រឹក្សាយោបល់លើស្ថិតិតាមវិស័យ និងផ្តល់ការបណ្តុះបណ្តាលការងារពាក់ព័ន្ធស្ថិតិសេដ្ឋកិច្ច និងសង្គមកិច្ច។ | ០៦ រូប | លោក ឃឹម ហ្វាដាណោ អនុប្រធាននាយកដ្ឋាន (ទទួលបន្ទុក)<br>លោក ស្រៀង ចន្ទី ប្រធានការិយាល័យ<br>លោកស្រី យុន មារតី អនុប្រធានការិ.<br>លោក ហេង បណ្ឌូល មន្ត្រី<br>លោក ឌឿ សុខលាភ មន្ត្រី<br>លោក សុខ បូហ៊ីម មន្ត្រី |

# ជំពូកទី៣

# ការគ្រប់គ្រងទិន្នន័យ
# របស់ការិយាល័យស្ថិតិ
# សេដ្ឋកិច្ចតាមវិស័យ

# ជំពូកទី៣
# ការគ្រប់គ្រងការិយាល័យស្ថិតិសេដ្ឋកិច្ចតាមវិស័យ

## ៣.១ ភារកិច្ចរបស់ការិយាល័យស្ថិតិសេដ្ឋកិច្ចតាមវិស័យ

នៅក្នុងការិយាល័យនីមួយៗតែងតែមានភារកិច្ចដែលត្រូវបំពេញទៅតាមការបែងចែក និង តាម សមត្ថភាពជំនាញផងដែរ។ ចំពោះការិយាល័យស្ថិតិសេដ្ឋកិច្ចតាមវិស័យមានតួនាទីដូចខាងក្រោម៖

- បង្កើត និងអនុវត្តយន្តការសម្របសម្រួល ដើម្បីប្រមូលទិន្នន័យពីក្រសួង ស្ថាប័នពាក់ព័ន្ធនានាដែលទទួលបន្ទុកផលិតស្ថិតិតាមវិស័យ ដែលមានជាអាទិ៍ វិស័យកសិកម្ម ឧស្សាហកម្ម និងសេវាកម្ម និងអនុវិស័យនីមួយៗ នៃសេដ្ឋកិច្ច និងសង្គមកិច្ច ដូចជាវិស័យកាត់ដេរ វិស័យសំណង់ និងអចលនទ្រព្យ វិស័យទេសចរណ៍ វិស័យរ៉ែ និងថាមពល វិស័យអប់រំ និងវិស័យសុខាភិបាល
- ចងក្រង និងវិភាគទិន្នន័យដែលប្រមូលបាន រួចរាយការណ៍អំពីនិន្នាការថ្មីៗ នៃសូចនាករសំខាន់ៗទាក់ទងនឹងទិន្នន័យ និងស្ថិតិខាងលើ ជូនថ្នាក់ដឹកនាំ និងរៀបចំរបាយការណ៍ជាធាតុចូល សម្រាប់ព្រឹត្តិបត្រប្រចាំខែ
- ចូលរួមរៀបចំគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ តាមរយៈកិច្ចសហការផ្តល់ទិន្នន័យជាធាតុចូល និងប្រឹក្សាយោបល់
- ទទួលបន្ទុកអង្កេត និងរៀបចំតារាងថ្លៃទីផ្សារនៃទំនិញ និងសេវាប្រចាំ សម្រាប់ប្រើប្រាស់ក្នុងការធ្វើលទ្ធកម្មសាធារណៈ
- ទទួលបន្ទុកតាមដានតម្លៃប្រេងក្នុងស្រុក តម្លៃប្រេងនាំចូល និងតម្លៃប្រេងនៅទីផ្សារអន្តរជាតិប្រចាំសប្តាហ៍ និងរៀបចំរបាយការណ៍រៀបចំ និងអនុវត្តកម្មវិធីការងារ និងផែនការសកម្មភាព របស់ការិយាល័យផ្ទាល់ ដើម្បីធានានិរន្តភាពការងារ។

### ៣.១.១ ដំណើរការងារជាក់ស្តែង

#### ៣.១.១.១ ការសម្របសម្រួល និងការរក្សាទំនាក់ទំនង

ជាធម្មតា រាល់ស្ថាប័ននីមួយៗមិនងាយស្រួលក្នុងការចែករំលែកឯកសារនោះឡើយ ដូចនេះហើយទើបតម្រូវអោយមាន ការប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមកមិនថាតែ នៅក្នុងស្ថាប័នឬតាមស្ថាប័នផ្សេងៗនោះឡើយ ។ ក្នុងនោះដែរការទំនាក់ទំនង គឺជាកត្តាសំខាន់មួយនៅក្នុងការធ្វើកិច្ចសហប្រតិបត្តិការការងារ ដែលមិនអាចមើលរំលងបានឡើយ ។ នៅក្នុងខ្សែសង្វាក់នៃប្រព័ន្ធការងារ ពួកគេតែងគិតថាវាជារឿងដែលត្រូវធ្វើមុនគេបង្អស់ មិនថាក្នុងស្ថាប័នតែមួយ ឬអន្តរស្ថាប័ននោះឡើយ ។ ក្នុងនោះដែរ ការិយាល័យស្ថិតិសេដ្ឋកិច្ចតាមវិស័យ បាននឹងបន្តធ្វើការសម្របសម្រួលជាមួយនឹងក្រសួងចំនួន១១បន្ថែមទៀតផងដែរដើម្បីប្រមូល ចងក្រង រៀបចំនូវរាល់របាយការណ៍

ខ្លីៗ និងជាពិសេសរៀបចំកម្រងទិន្នន័យមូលដ្ឋាន សំដៅធ្វើឲ្យនាយកដ្ឋានស្ថិតិមានទិន្នន័យកាន់តែសំបូរបែប ដើម្បីឆ្លើយតបទៅនឹងតម្រូវការប្រើប្រាស់ទិន្នន័យជាប្រចាំ និងជាធាតុចូលដ៏សំខាន់សម្រាប់ ព្រឹត្តប័ត្រសេដ្ឋកិច្ច ក៏ដូចជារបាយការណ៍និន្នាការសេដ្ឋកិច្ច និងសង្គមផងដែរ។ នៅក្នុងន័យនេះដែរ ការិយាល័យស្ថិតិសេដ្ឋកិច្ចតាមវិស័យបានទទួលរបាយការណ៍ពីបណ្ដាក្រសួង រួមមានរបាយការណ៍៖

- ស្ថិតិវិនិយោគ
- ស្ថិតិសំណង់
- ស្ថិតិទេសចរណ៍
- ស្ថិតិកសិកម្ម
- ស្ថិតិឧស្សាហកម្ម និងសិប្បកម្ម
- ស្ថិតិរ៉ែ និងថាមពល
- ស្ថិតិការងារចុះជញ្ជីយានយន្ត
- ស្ថិតិការងារពាណិជ្ជកម្ម
- ស្ថិតិការងារបណ្តុះបណ្តាលវិជ្ជាជីវៈ
- ស្ថិតិតារាងវឌ្ឍភាពការសាងសង់ ជួសជុល ថែទាំរចនាសម្ព័ន្ធរូបវន្ត
- ស្ថិតិលទ្ធផលការងារប្រៃសណីយ៍ និងទូរគមនាគមន៍។[13]

### ៣.១.១.២ ការប្រមូលទិន្នន័យ

ស្ថិតក្នុងដំណាក់កាលនេះ មុនពេលដែលប្រមូលទិន្នន័យបានពីប្រភពណាមួយនោះ ត្រូវមានការអនុញ្ញាតត្រឹមត្រូវពីថ្នាក់លើដែលជាអ្នកគ្រប់គ្រងជាមុនសិន។ យោងតាមដំណើរការការងារនៅក្នុងការិយាល័យមានលក្ខណៈវិមជ្ឈការ ហេតុនេះហើយយើងត្រូវធ្វើសំណើរទៅថ្នាក់លើ និងប្រាប់ពីកម្មវត្ថុជាមុនសិន ទើបអាចទទួលបានទិន្នន័យទាំងនោះ ។ នៅក្នុងការធ្វើនោះផងដែរ គឺតម្រូវឲ្យមានការអនុញ្ញាតពីលោកប្រធានការិយាល័យ បន្ទាប់មកត្រូវយកសំណើរនោះបញ្ជូនបន្តទៅសុំការឯកភាពប្រធាននាយកដ្ឋាន ក្រោយពីទទួលបានការអនុញ្ញាតហើយ ត្រូវបញ្ជូនទៅលោកប្រធានអគ្គនាយកដ្ឋានទៀត ហើយជាចុងក្រោយយើងយកសំណើរនោះទៅសុំការឯកភាពពីរដ្ឋមន្ត្រី ។ ក្រោយពីមានការសម្រេចពីលោករដ្ឋមន្ត្រីទើបអាចសំណើរនោះទៅស្ថាប័ន ឬផ្នែកដែលពាក់ព័ន្ធ ដើម្បីទទួលនូវទិន្ន័យដែលយើងចង់បាន ។

ប្រភពទិន្នន័យដែលយើងប្រមូលយក ចែកចេញជាបីប្រភេទគឺ៖

[13] របាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៥របស់ការិយាល័យស្ថិតិសេដ្ឋកិច្ចតាមវិស័យ ទំព័រទី១

- ទិន្នន័យផ្ទាល់នៅក្នុងស្ថាប័នផ្ទាល់ (Secondary Data)
- ទិន្នន័យក្រៅស្ថាប័ន (Secondary Data)
- ទិន្នន័យដែលត្រូវការប្រមូលតាមមូលដ្ឋាន (Primary Data)

**ក. ទិន្នន័យផ្ទាល់នៅក្នុងស្ថាប័នផ្ទាល់**

វាជាប្រភេទនៃទិន្ន័យដែលមានស្រាប់នៅក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមិនចាំបាច់ធ្វើការស្នើសុំទៅកាន់ក្រសួងផ្សេងៗនោះឡើយ។ ដោយដំណើរការនៃការប្រមូលទិន្នន័យនេះត្រូវធ្វើសំណើរពីថ្នាក់ក្រោមរហូតដល់ការសម្រេចពីរដ្ឋមន្រ្តី ហើយបញ្ជូនទៅផ្នែកដែលពាក់ព័ន្ធដើម្បីទទួលបានទិន្នន័យ ។

**ខ. ទិន្នន័យក្រៅស្ថាប័ន**

វាជាប្រភេទទិន្ន័យដែលមិនមាននៅក្នុងក្រសួងសេដ្ឋកិច្ចនោះទេ ដែលយើងត្រូវយកមកពីស្ថាប័នផ្សេងៗ ។ ដោយដំណើរការនៃការប្រមូលទិន្នន័យត្រូវធ្វើសំណើរពីថ្នាក់ក្រោមរហូត ដល់ការសម្រេចពីរដ្ឋមន្រ្តី ហើយធ្វើការបញ្ជូនទៅកាន់ស្ថាប័នណាមួយដែលយើងចង់ប្រមូលទិន្នន័យ ។

**គ. ទិន្នន័យដែលត្រូវការប្រមូលតាមមូលដ្ឋាន**

នៅក្នុងនេះផងដែរយើងអាចនិយាយបានថាវាខុសពីប្រភេទនៃទិន្នន័យទាំងពីខាងលើពោលគឺជាទិន្នន័យដែលត្រូវការចុះទៅប្រមូលដោយផ្ទាល់នៅតាមមូលដ្ឋាន ។ ដោយដំណើរការនៃការប្រមូលទិន្នន័យត្រូវធ្វើសំណើរពីថ្នាក់ក្រោមរហូតដល់ការសម្រេចពីរដ្ឋមន្រ្តី ហើយត្រូវជ្រើសរើសយកតំបន់ណាមួយមកធ្វើជា គំរូ (Sample) ដោយប្រើវិធីសាស្ត្រសម្ភាសន៍ ឬធ្វើជាកំរងសំនួរ ចុះទៅតាមមូលដ្ឋាន រួចបង្កើតជាទិន្នន័យ ។

## ៣.២ ទិន្នន័យវិនិយោគឯកជនក្នុងស្រុក

ចំពោះទិន្នន័យវិនិយោគឯកជននៅក្នុងរបស់ប្រទេសកម្ពុជាយើងត្រូវបានបែងចែកជា៤ វិស័យធំៗគឺ កសិកម្ម ឧស្សាហកម្ម សេវាកម្ម និងទេសចរណ៍ ។

ខាងក្រោមនេះគឺជាទិន្នន័យវិនិយោគឯកជនក្នុងស្រុករបស់ការិយាល័យស្ថិតិសេដ្ឋកិច្ចតាមវិស័យដែលទទួលបានមកពី បានពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (The Council for the Development of Cambodia)។ ទិន្នន័យនេះជាទិន្នន័យប្រចាំឆ្នាំដែលស្តីពីចំនួនទឹកប្រាក់ នៃការវិនិយោគរបស់ វិស័យនីមួយៗនៅក្នុងប្រទេសកម្ពុជាដែលចាប់គិតពីឆ្នាំ២០១៥ ដល់ឆ្នាំ ២០១៦ (គិតជាលានដុល្លារ)៖

| | **2015** | **2016** |
|---|---|---|
| **Agriculture** | **460.95** | **386.12** |
| Agriculture | 25.84 | 0.00 |
| Agro-Industry | 259.81 | 275.69 |

| | | |
|---|---|---|
| Animal farming | | 0.00 |
| Fishery | | 0.00 |
| Flour | | 0.00 |
| Plantation | | 29.77 |
| Rice mill | 72.78 | 26.01 |
| Rubber | 102.52 | 54.65 |
| **Industries** | **630.41** | **1,020.92** |
| Animal meal | 2.33 | 0.00 |
| Bag | 2.62 | 24.99 |
| Bicycle | 0.00 | 0.00 |
| Building Material | 10.77 | 5.82 |
| Car | | 0.00 |
| Cement | | 497.26 |
| Chemical | | 3.42 |
| Drinking Water | 93.49 | 5.11 |
| Electronics | 6.07 | 5.79 |
| Energy | | 12.50 |
| Fertilizer | | 0.00 |
| Food Processing | | 14.09 |
| Garment | 225.33 | 174.99 |
| Glove | | 2.21 |
| Household Goods | | 0.00 |
| Medical Supplies | | 0.00 |
| Medical Chemical | | 0.00 |
| Medical Instrument | 2.17 | 0.00 |
| Metal | 3.76 | 35.61 |
| Mining | | 109.17 |
| Other Industries | 49.09 | 49.06 |
| Packaging | | 2.82 |
| Paper | 48.88 | 0.00 |
| Petroleum | 2.75 | 0.00 |
| Plastic | | 0.00 |
| Leather Processing | 12.04 | 0.00 |
| Mechanic Assembly | 6.23 | 0.00 |
| Motor | 4.34 | 2.54 |
| Shoes | 151.19 | 73.36 |
| Sock | | 0.00 |
| Textile | | 0.00 |
| Tobacco | 4.74 | 0.00 |

| | | |
|---|---|---|
| Toy | 4.63 | 0.00 |
| Wood Processing | | 2.21 |
| **Services** | **2,729.07** | **444.09** |
| Construction | | 2.13 |
| Engineering | | 0.00 |
| Health Services | 29.33 | 0.00 |
| Infrastructure | 2,337.10 | 190.00 |
| Services | 0.22 | 0.00 |
| Shopping Mall | | 210.96 |
| Telecommunication | 353.22 | 41.00 |
| Transportation | | 0.00 |
| Water Supply | 9.20 | 0.00 |
| **Tourism** | **98.63** | **1,398.23** |
| Hotel | 71.45 | 324.70 |
| Tourism | 27.18 | 521.89 |
| Tourism Center | | 551.64 |
| **Total** | **3,919.06** | **3,249.36** |

### ៣.២.១ ក្រាហ្វិចក្នុងឆ្នាំ ២០១៥




តាមតារាង និងក្រាហ្វិចខាងលើបានបង្ហាញអោយឃើញថាក្នុងឆ្នាំ២០១៥ ការវិនិយោគឯកជនក្នុងស្រុកមានចំនួន ៣៩១៩.០៦ លានដុល្លារដែលក្នុងនោះរួមមាន វិស័យកសិកម្មមានចំនួន ៤៦០.៩៥ លានដុល្លារ ស្មើនឹង១២% នៃការវិនិយោគសរុបប្រចាំឆ្នាំ ។ វិស័យឧស្សាហកម្មមានចំនួន ៦៣០.៤១ លានដុល្លារ ស្មើនឹង១៦% នៃការវិនិយោគសរុប ។ វិស័យសេវាកម្មមានចំនួន

២៧២៩.០៧ លានដុល្លារ ស្មើនឹង៧០% នៃការវិនិយោគសរុប ។ វិស័យទេសចរណ៍មានចំនួន ៩៨.៦៣ លានដុល្លារ ស្មើនឹង២% នៃការវិនិយោគសរុប ។

### ៣.២.២ ក្រាហ្វិចក្នុងឆ្នាំ២០១៦




តាមរយៈតារាង និងក្រាហ្វិចខាងលើបានបង្ហាញអោយដឹងថាក្នុងឆ្នាំ២០១៦ ការវិនិយោគក្នុងស្រុកសរុបមានចំនួន ៣២៩៩.៣៦ លានដុល្លារ ក្នុងឆ្នាំនេះទិន្នន័យមានការថយចុះ ២០.៨០% បើធៀបនឹងឆ្នាំ២០១៥ ។ វិស័យកសិកម្មមានចំនួន ៣៨៦.១២ ស្មើនឹង១២% នៃការវិនិយោគសរុប ដែលមានការថយចុះប្រមាណ ១៦.២៣% បើធៀបនឹងឆ្នាំ២០១៥ ដែលការធ្លាក់ចុះនេះបណ្តាលមកពីការចុះនៃការវិនិយោគមួយចំនួន ហើយអ្វីដែលជាកត្តាចំបងនោះគឺ ក្នុងឆ្នាំ២០១៦នោះ កម្ពុជាក៏បានបាត់បង់ការវិនិយោគលើកសិកម្មក្នុងស្រុក ដែលមានចំនួន២៥.៨៤ លានដុល្លារ កាលពីឆ្នាំ២០១៥ ។ វិស័យឧស្សាហកម្មមានចំនួន ១០២០,៩២ លានដុល្លារ ស្មើនឹង ៣១% នៃការវិនិយោគសរុបប្រចាំឆ្នាំ ដែលមានការកើនឡើងប្រមាណ ៦១.៩៤% បើធៀបនឹងឆ្នាំ២០១៥ មូលហេតុនៃការកើនឡើងនៃទិន្នន័យបណ្តាលមកពី កម្ពុជាទទួលបាននូវការវិនិយោគថ្មីមួយចំនួនដែលមិនមានក្នុងឆ្នាំ២០១៥ ដូចជា ស៊ីម៉ង់ ៤៩៧.២៦ លានដុល្លារ , សារធាតុគីមី ៣.៤២ លានដុល្លារ , ថាមពល ១២.៥០ លានដុល្លារ , ខ្សែសង្វាក់ម្ហូបអាហារ ១៤.០៩ លានដុល្លារ , ស្រោមដៃ ២.២១ លានដុល្លារ , អាជីវកម្មរ៉ែ , ការវិចខ្ចប់ ២.៨២ , ការកែច្នៃឈើ ២.២១ លានដុល្លារ ។ វិស័យសេវាកម្ម មានចំនួន ៤៤៤.០៩ លានដុល្លារ ស្មើនឹង១៤% នៃការវិនិយោគសរុបប្រចាំឆ្នាំ ដែលមានការថយចុះចំនួន ៨៣.៧២% បើធៀបនឹងឆ្នាំ២០១៥ មូលហេតុចំបងនៃការថយចុះនេះបណ្តាលមកពីបាត់បង់លើការ

វិនិយោគមួយចំនួនដែលមានក្នុងឆ្នាំ២០១៥ មានដូចជា សេវាកម្មសុខភាព ២៩.៣៣ លានដុល្លារ , សេវាផ្គត់ផ្គង់ទឹក ៩.២០ លានដុល្លារ , និងការថយចុះយ៉ាងច្រើនលើផ្នែកហេដ្ឋារចនាសម្ព័ន្ធ ចំនួន ២១៤ លានដុល្លារ ។ វិស័យទេសចរណ៍ មានចំនួន១៣៩៨.២៣ លានដុល្លារ ស្មើនឹង ៤៣% នៃការវិនិយោគសរុបប្រចាំឆ្នាំ ដែលមានការកើនឡើងចំនួន ១២៩៩.៦ លានដុល្លារបើធៀបនឹងឆ្នាំ ២០១៥ ។

## ៣.៣ ទិន្នន័យការវិនិយោគឯកជនពីបរទេស

ខាងក្រោមនេះដែរគឺជាតារាងទិន្នន័យ វិនិយោគឯកជនពីបរទេសរបស់ការិយាល័យស្ថិតិសេដ្ឋកិច្ចតាមវិស័យដែលទទួលបានពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (The Council for the Development of Cambodia)។ ទិន្នន័យនេះជាទិន្នន័យប្រចាំឆ្នាំដែលស្ដីពីចំនួនទឹកប្រាក់ នៃការ វិនិយោគរបស់ប្រទេសនីមួយៗមកលើប្រទេសកម្ពុជាដែលចាប់គិតពីឆ្នាំ២០១០ ដល់ឆ្នាំ ២០១៦[14] (គិតជាលានដុល្លារ)៖

| | | 2010 | 2011 | 2012 | 2013 | 2014 | 2015 | 2016 |
|---|---|---|---|---|---|---|---|---|
| Regions | Country | | | | | | | |
| **Africa** | | **0** | **0** | **7.70** | **0** | **0** | **11.36424** | **5.073649** |
| | Republic of Seychelles | | | 7.70 | | | 11.36 | 5.07 |
| | | | | | | | | |
| **America** | | **42.61** | **144.41** | **11.24** | **11.80** | **14.56** | **5.85** | **17.09** |
| | Canada | 6.64 | | 5.90 | 7.27 | | 2.69 | 5.66 |
| | United States | 35.97 | 144.41 | 5.34 | 4.53 | 14.56 | 3.16 | 11.43 |
| | | | | | | | | |
| **Asean** | | **321.37** | **880.02** | **289.57** | **338.99** | **102.18** | **205.29** | **330.95** |
| | Singapore | 37.18 | 13.76 | 82.67 | 54.55 | 36.63 | 26.78 | 103.77 |
| | Brunei | | | | 4.25 | | 4.48 | 8.09 |
| | Vietnam | 114.73 | 630.95 | 85.92 | 241.53 | 15.45 | 89.34 | 81.29 |
| | Thailand | 2.04 | | 120.87 | 31.87 | 25.38 | 22.37 | 130.83 |
| | Malaysia | 167.42 | 235.32 | 0.12 | 5.90 | 24.14 | 62.33 | 6.97 |
| | Indonesia | | | | 0.88 | 0.57 | | |
| | | | | | | | | |
| **Cambodia** | | **391.16** | **1,930.12** | **907.08** | **3,267.44** | **582.15** | **3,135.08** | **941.60** |
| | Cambodia | 391.16 | 1,930.12 | 907.08 | 3,267.44 | 582.15 | 3,135.08 | 941.60 |

[14] ការិយាល័យស្ថិតិសេដ្ឋកិច្ចតាមវិស័យ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០១៧

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| **Europe** | | **41.64** | **2,237.89** | **44.69** | **95.24** | **109.81** | **115.06** | **39.77** |
| | Russia | | | | 3.16 | | | |
| | United Kingdom | | | 24.63 | 84.38 | 86.77 | 115.06 | 35.77 |
| | Austria | | | | 3.02 | | | |
| | Belgium | 1.63 | | | 2.01 | 4.55 | | |
| | France | | | 3.18 | 2.67 | 3.60 | | |
| | Germany | | | | | 3.09 | | |
| | England | 10.52 | 2,237.89 | 12.36 | | | | |
| | Luxembourg | | | 1.48 | | 8.40 | | |
| | Spain | | | | | | | |
| | Netherland | | | 3.03 | | | | |
| | Switzerland | | | | | | | |
| | Denmark | 29.48 | | | | | | 4.00 |
| | Italy | | | | | 3.39 | | |
| **Others & Other Asia** | | **1,893.99** | **1,819.91** | **1,016.48** | **769.47** | **945.71** | **445.99** | **1,914.88** |
| | China | 683.89 | 1,191.51 | 263.59 | 431.48 | 681.62 | 240.14 | 731.37 |
| | Korea | 1,026.59 | 146.20 | 280.75 | 81.82 | 65.15 | 8.48 | 20.16 |
| | India | | 6.36 | 3.01 | | 3.33 | | 20.00 |
| | Taiwan | 102.11 | 83.30 | 97.23 | 89.52 | 34.25 | 46.49 | 40.17 |
| | Hong Kong | 29.61 | 331.17 | 117.48 | 111.36 | 100.95 | 109.12 | 319.96 |
| | Japan | | 6.15 | 212.33 | 24.59 | 3.44 | 38.87 | 773.75 |
| | Australia | 49.73 | 24.96 | 1.04 | 2.89 | 17.75 | | |
| | Israel | 2.06 | | | 3.26 | | | |
| | Mauritius | | 8.53 | | | | 2.34 | |
| | Macau | | 0.91 | | | | | |
| | Mongolia | | | | | | | 4.33 |
| | Pakistan | | | | | | 0.55 | |
| | Unknown | | | | 3.37 | | | |
| | Turkey | | | | 2.65 | | | |
| | Samoa | | 3.74 | 41.05 | 18.52 | 39.21 | | 5.15 |
| | North Korea | | 17.06 | | | | | |
| **Total** | | **2,690.76** | **7,012.36** | **2,276.76** | **4,482.95** | **1,754.41** | **3,918.63** | **3,249.36** |

### ៣.៣.១ ការបកស្រាយទិន្នន័យ

- វិនិយោគឯកជនពីទ្វីបអាហ្វ្រិច មកលើប្រទេសកម្ពុជា មានតែ សាធារណៈរដ្ឋសីស្វែល មួយប៉ុណ្ណោះ ដែលឆ្នាំ២០១២មានចំនួនទឹកប្រាក់ $៧ ៧០០ ០០០ , នៅក្នុងឆ្នាំ២០១៥មានចំនួនទឹកប្រាក់ $១១ ៣៦៤ ២៤០, និងនៅក្នុងឆ្នាំ២០១៦ មានចំនួនទឹកប្រាក់ $៥ ០៧៣ ៦៤៩។ ចំណែកឯឆ្នាំ ២០១០ ២០១១ ២០១៣ និង ២០១៤ ពុំមានការធ្វើវិនិយោគនោះទេ ។
- វិនិយោគឯកជនពីទ្វីបអាមេរិច មានពីរប្រទេសគឺ កាណាដា និងសហរដ្ឋអាមេរិច ដែលមានចំនួនទឹកប្រាក់សរុបក្នុងឆ្នាំ២០១០ មានចំនួន $៤២ ៦១០ ០០០ , ក្នុងឆ្នាំ២០១១ មានចំនួន $១៨៤ ៤១០ ០០០ , ក្នុងឆ្នាំ២០១២ មានចំនួន $១១ ២៤០ ០០០ , ក្នុងឆ្នាំ២០១៣ មានចំនួន $១១ ៨០០ ០០០ , ក្នុងឆ្នាំ២០១៤ មានចំនួន $១៤ ៥៦០ ០០០ , នៅក្នុងឆ្នាំ២០១៥ មានចំនួន $៥ ៨៥០ ០០០ និងនៅក្នុងឆ្នាំ ២០១៦ មានចំនួន $១៧ ០៩០ ០០០ ដែលនេះបានបញ្ជាក់ថាមានការវិនិយោគយ៉ាងច្រើនមកលើប្រទេសកម្ពុជាយើង
- វិនិយោគឯកជនពីប្រទេសដែលជាសមាជិកអាស៊ាន មានចំនួន៦ប្រទេសគឺ សិង្ហបុរី ព្រុយណេ វៀតណាម ថៃ ម៉ាឡេស៊ី និងឥណ្ឌូណេស៊ី ដែលមានចំនួនទឹកប្រាក់សរុប ក្នុងឆ្នាំ២០១០ មានចំនួន $៣២១ ៣៧០ ០០០ ,ក្នុងឆ្នាំ២០១១ មានចំនួន $៨៨០ ០២០ ០០០ ,ក្នុងឆ្នាំ២០១២ មានចំនួន $២៨៩ ៥៧០ ០០០ ,ក្នុងឆ្នាំ២០១៣ មានចំនួន $៣៣៨ ៩៩០ ០០០ , ក្នុងឆ្នាំ២០១៤ មានចំនួន $១០២ ១៨០ ០០០ ,នៅក្នុងឆ្នាំ២០១៥ មានចំនួន $២០៥ ២៩០ ០០០ និងនៅក្នុងឆ្នាំ ២០១៦ មានចំនួន $៣៣០ ៩៥០ ០០០
- វិនិយោគឯកជនពីទ្វីបអឺរ៉ុប មានចំនួន១៣ប្រទេសគឺ រុស្ស៊ី ចក្រភពអង់គ្លេស អូស្រ្តាលី ប៊ែលហ្ស៊ិក បារាំង អាឡឺម៉ង់ អង់គ្លេស លុកសេមបឺក អេស្ប៉ាញ ហូឡង់ ស្វីស ដាណឺម៉ាក និងអ៊ីតាលី ដែលមានចំនួនទឹកប្រាក់សរុប ក្នុងឆ្នាំ២០១០ មានចំនួន $៤១ ៦៤០ ០០០ , ក្នុងឆ្នាំ២០១១ មានចំនួន $២ ២៣៧ ៨៩០ ០០០ , ក្នុងឆ្នាំ២០១២ មានចំនួន $៤៤ ៦៩០ ០០០ , ក្នុងឆ្នាំ២០១៣ មានចំនួន $៩៥ ២៤០ ០០០ , ក្នុងឆ្នាំ២០១៤ មានចំនួន $១០៩ ៨១០ ០០០ , នៅក្នុងឆ្នាំ២០១៥ មានចំនួន $១១៥ ០៦០ ០០០ និងនៅក្នុងឆ្នាំ ២០១៦ មានចំនួន $៣៩ ៧៧០ ០០០
- វិនិយោគឯកជនពីទ្វីបអឺរ៉ុប និងផ្សេងៗទៀត មានដូចជា ចិន កូរ៉េ ឥណ្ឌា តៃវ៉ាន់ ហុងកុង ជប៉ុន អូស្រ្តាលី អ៊ីរ៉ាក់ Mauritius ម៉ាកាវ ម៉ុងហ្គោល ប៉ាគីស្ថាន ទូគី Samoa និង កូរ៉េខាង

ត្បូង ដែលមានចំនួនទឹកប្រាក់សរុប ក្នុងឆ្នាំ២០១០មានចំនួន $១ ៨៩៣ ៩៩០ ០០០ ,ក្នុងឆ្នាំ ២០១១ មានចំនួន $១ ៨១៩ ៩១០ ០០០ ,ក្នុងឆ្នាំ២០១២ មានចំនួន $១ ០១៦ ៨៨០ ០០០ , ក្នុងឆ្នាំ២០១៣ មានចំនួន $៧៦៩ ៤៧០ ០០០ ,ក្នុងឆ្នាំ២០១៤ មានចំនួន $៩៤៥ ៧១០ ០០០ ,នៅក្នុងឆ្នាំ២០១៥ មានចំនួន $៤៤៥ ៩៩០ ០០០ និងនៅក្នុងឆ្នាំ ២០១៦មានចំនួន $១ ៩១៤ ៨៨០ ០០០។

ជារួមមក ទិន្នន័យលើការវិនិយោគឯកជនពីបរទេសសរុបប្រចាំឆ្នាំ នៅក្នុងឆ្នាំ២០១០ មានចំនួន $២ ៦៩០ ៧៦០ ០០០ , នៅក្នុងឆ្នាំ២០១១ មានចំនួន $៧ ០១២ ៣៦០ ០០០ , នៅក្នុងឆ្នាំ២០១៣ មានចំនួន $២ ២៧៦ ៧៦០ ០០០ , នៅក្នុងឆ្នាំ២០១៤ មានចំនួន $៤ ៤៨២ ៩៥០ ០០០ នៅក្នុងឆ្នាំ២០១៥ មានចំនួន $៣ ៩១៨ ៦៣០ ០០០ និងនៅក្នុងឆ្នាំ២០១៦ មានចំនួន ៣ ២៤៩ ៣៦០ ០០០ ។

មិនតែប៉ុណ្ណោះ ខាងក្រោមនេះគឺជាតារាងទិន្នន័យដែលបញ្ជាក់ពីចំនួនថវិកាដែលមានការវិនិយោគពីប្រទេសមួយចំនួននៅក្នុងតំបន់អាស៊ីមកលើប្រទេសកម្ពុជាយើង។ ក្នុងនោះដែរ មានដូចជា
ប្រទេសចិន ប្រទេសកូរ៉េ ប្រទេសថៃ ប្រទេសតៃវ៉ាន់ ប្រទេសហុងកុង និងប្រទេសជប៉ុន ដែលបានដកស្រង់មកជាប្រចាំខែ ចាប់ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៦ ដោយគិតជាលានដុល្លារ។

### ៣.៣.២ ការវិភាគទិន្នន័យផ្ទាល់លើការវិនិយោគឯកជនបរទេស



តាមរយៈការបង្ហាញនូវក្រាបខាងលើ យើងឃើញថាទិន្នន័យវិនិយោគឯកជនពីបរទេសមកលើប្រទេសកម្ពុជា មានលក្ខណៈប្រែប្រួលខ្លាំងគួរឲ្យមានការកត់សម្គាល់។ ជាក់ស្តែង ក្នុងកំឡុងពេល៧ឆ្នាំមកនេះ គឺមានការកើនឡើង ក៏ដូចជាមានការថយចុះផងដែរ។ ក្នុងកំឡុងឆ្នាំ២០១០ដល់ ២០១១ មានការកើនឡើងយ៉ាងខ្លាំងនៃការចូលមកវិនិយោគពីបរទេស ពោលគឺកើនឡើងប្រមាណជាងមួយកន្លះ ស្មើនឹងទឹកប្រាក់ប្រមាណ៤ ៣២២ ០០០ ០០០ដុល្លារ បើធៀបទៅនឹងឆ្នាំ២០១០។ ប៉ុន្តែជាអកុសល្យ វាមានការថយចុះទៅវិញក្នុងឆ្នាំ២០១២ ប្រមាណ៣៥% បើធៀបនឹងឆ្នាំ២០១០។ ដោយឡែក ក្នុងឆ្នាំ២០១៣ មានការកើនឡើងមកវិញយ៉ាងល្អ បន្ទាប់ពីការធ្លាក់ចុះកាលពីឆ្នាំ ២០១២។ ចំពោះឆ្នាំ២០១៤វិញ គឺមានការថយចុះយ៉ាងធ្ងន់ធ្ងរ ដោយសារតែមានការបាត់បង់នូវការមកវិនិយោគពីបណ្តាប្រទេសនានាខាងលើ ក៏ដូចជាការថយចុះនូវវិនិយោគិនដែលធ្លាប់វិនិយោគផងដែរ។ ការធ្លាក់ចុះនេះផងដែរមានប្រមាណជាទឹកប្រាក់ ២ ៧២៨ ០០០ ០០០ ដុល្លារ ដែលជាចំនួនមួយដ៏ធំ។ រីឯឆ្នាំ២០១៥វិញ មានការកើនឡើងជាងឆ្នាំ២០១៤ ទ្វេដង ស្មើនឹងទឹកប្រាក់ប្រមាណ ២ ១៦៤ ០០០ ០០០ដុល្លារ។ ក្នុងឆ្នាំ ២០១៦ ទិន្នន័យវិនិយោគមានចំនួន ៣ ២៤៤ ៣៦០ ០០០ ដុល្លារ ។ ទិន្នន័យនេះមានការថយចុះប្រមាណ ១៧.០៧% បើធៀបទៅនឹងឆ្នាំចាស់២០១៥ ដែលបណ្តាលមកពី បំរែបំរួលនៃការវិនិយោគពីបរទេសនៅតាមបណ្តាប្រទេសមួយចំនួន។ ក្នុងនោះរួមមានដូចជា ទ្វីបអាហ្វ្រិចមានចំនួន ៥ ០៧៣ ៦៤៩ ដុល្លារ គឺមានការថយចុះ៥៥.៣៥% ធៀបទៅនឹងឆ្នាំ២០១៥។ ទ្វីបអាមេរិច មានចំនួន ១៧ ០៩០ ០០០ ដុល្លារ មានការកើនឡើង ១៩២.១៣% បើធៀបនឹងឆ្នាំ២០១៥។ ប្រទេសដែលជាសមាជិកអាស៊ានមានចំនួន ៣៣០ ៩៥០ ០០០ ដុល្លារ មានការកើនឡើងប្រមាណ ៦១.២១% បើធៀបនឹងឆ្នាំ២០១៥។ វិនិយោគិនក្នុងប្រទេសកម្ពុជាមានចំនួន ៩៤១,៦ លានដុល្លារ មានការថយចុះប្រមាណ ២៣២.៩៥% បើធៀបនឹងឆ្នាំ២០១៥ ។ ទ្វីបអឺរ៉ុប មានចំនួន ៣៩,៧៧ លានដុល្លារ មានការថយចុះចំនួន ១៨៩.៣១% បើធៀបនឹងឆ្នាំ២០១៥ ។ ទ្វីបអាស៊ី និងបណ្តាប្រទេសផ្សេងៗទៀត មានចំនួន១៩១៤.៨៨ លានដុល្លារ ដែលមានការកើនឡើងចំនួន ៣២៩.៣៥% បើធៀននឹងឆ្នាំ២០១៥ ។

## ៣.៤ ទិសដៅឆ្នាំ២០១៧ របស់ការិយាល័យស្ថិតិសេដ្ឋកិច្ចតាមវិស័យ

នៅក្នុងឆ្នាំ២០១៧នេះ ដើម្បីបង្កើនប្រសិទ្ធិភាពក្នុងការចងក្រង វិភាគ និងផ្សព្វផ្សាយការងារស្ថិតិ នាយកដ្ឋានស្ថិតិមានផែនការ និងទិសដៅ៖

- ❖ បន្តការពង្រីកប្រមូល និងចងក្រងទិន្នន័យស្ថិតិគ្រប់វិស័យពាក់ព័ន្ធអោយកាន់តែទូលំទូលាយ និងមានប្រសិទ្ធិភាព
- ❖ ពន្លឿន និងចេញជារបាយការណ៍សេដ្ឋកិច្ច និងហិរញ្ញវត្ថុបានទាន់ពេលវេលាកំណត់ ៖
  - របាយការណ៍ប្រតិបត្តិការណ៍ហិរញ្ញវត្ថុរដ្ឋ ប្រចាំខែ និងត្រូវបានចេញផ្សាយលើគេហទំព័រក្រសួងមិនលើសពី២សប្តាហ៍ បន្ទាប់ពីរបាយការណ៍បានបញ្ចប់រួចរាល់
  - របាយការណ៍ប្រតិបត្តិការណ៍ហិរញ្ញវត្ថុរដ្ឋាភិបាល ប្រចាំខែ និងត្រូវបានចេញផ្សាយលើគេហទំព័រក្រសួងមិនលើសពី២សប្តាហ៍ បន្ទាប់ពីរបាយការណ៍បានបញ្ចប់រួចរាល់
  - របាយការណ៍និន្នាការសេដ្ឋកិច្ចសង្គម ប្រចាំខែ នឹងត្រូវបានចេញផ្សាយលើគេហទំព័រក្រសួងមិនលើសពី២សប្តាហ៍បន្ទាប់ពីរបាយការណ៍
  - ព្រឹត្តិបត្រស្ថិតិសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រចាំត្រីមាស និងត្រូវបានបោះពុម្ពផ្សាយជាសាធារណៈ និងចេញផ្សាយលើគេហទំព័រក្រសួង (នៅត្រីមាសបន្ទាប់)
  - របាយការណ៍វិវត្តន៍ថ្លៃទំនិញ ប្រើប្រាស់នៅរាជធានីភ្នំពេញ (CPI) ជាប្រចាំខែ នឹងត្រូវបានចេញផ្សាយលើគេហទំព័ររបស់ក្រសួងជាប្រចាំ ។
- ❖ ពង្រឹងសមត្ថភាពវិភាគស្ថិតិ និងតាមដានស្ថានភាពសេដ្ឋកិច្ចតាមវិស័យមានដូចខាងក្រោម
  - ចេញរបាយការណ៍តាមដាន និងវាយតម្លៃពាណិជ្ជកម្មក្រៅប្រទេស
  - ចេញរបាយការណ៍វិស័យទេសចរណ៍ជាប្រចាំខែ និងរបាយការណ៍ស្ថិតិវិស័យទេសចរណ៍នៅខេត្តចំនួន ១២
  - ចេញរបាយការណ៍វិស័យសំណង់ និងវិនិយោគឯកជន ជាប្រចាំខែ និងរបាយការណ៍ស្វែងយល់ពីការកត់ត្រាទិន្នន័យពាណិជ្ជកម្មអន្តរជាតិ ត្រូវបានរៀបចំឡើង
  - ចេញរបាយការណ៍ស្តីពីស្ថានភាពរូបិយវត្ថុកម្ពុជាជាប្រចាំខែ
  - ចេញរបាយការណ៍វិស័យកសិកម្ម ជាប្រចាំត្រីមាស
  - ចេញរបាយការណ៍វិស័យឧស្សាហកម្ម និងសិប្បកម្មជាប្រចាំខែ
- ❖ ពង្រឹង និងបង្កើនប្រសិទ្ធិភាពនៃការគ្រប់គ្រងទិន្នន័យ
  - បន្តធ្វើបច្ចុប្បន្នភាពទិន្នន័យក្នុងឃ្លាំងផ្ទុកទិន្នន័យ MEF Database និងសិក្ខាសាលាផ្សព្វផ្សាយ វគ្គបណ្តុះបណ្តាលក្នុងគោលដៅ តាមដានស្ថានភាពម៉ាក្រូសេដ្ឋកិច្ច

និងហិរញ្ញវត្ថុ ត្រូវបានផ្សព្វផ្សាយទៅអ្នកប្រើប្រាស់ នៃអគ្គនាយកដ្ឋានពាក់ព័ន្ធមួយចំនួន និងដល់ក្រសួង ឬស្ថាប័ន ផ្តល់ទិន្នន័យក្នុងគោលបំណង ប្រសិទ្ធិភាពប្រមូលទិន្នន័យ

- ចេញរបាយការណ៍វាយតម្លៃប្រសិទ្ធិភាព នៃការប្រើប្រាស់ Database
- អភិវឌ្ឍប្រព័ន្ធប្រមូលការងារ និងគ្រប់គ្រងទិន្នន័យ
- វគ្គបណ្តុះបណ្តាល និងដកស្រង់បទពិសោធន៍លើការគ្រប់គ្រងប្រព័ន្ធស្ថិតិ (Database Management) នៅក្នុងប្រទេសជប៉ុនក្នុងគោលដៅបង្កើនសមត្ថភាពនៃការអភិវឌ្ឍន៍ និងការគ្រប់គ្រងទិន្នន័យ
- បន្តរៀបចំយន្តការសម្របសម្រួលទិន្នន័យជាមួយក្រសួង ឬស្ថាប័នពាក់ព័ន្ធ

❖ បង្កើនប្រសិទ្ធិភាព និងភាពស័ក្តិសិទ្ធិ នៃស្តង់ដារស្ថិតិហិរញ្ញវត្ថុ សម្រាប់ការប្រើប្រាស់

- របាយការណ៍ត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ស្ថិតិហិរញ្ញវត្ថុ
- ស្តង់ស្ថិតិប្រតិបត្តិការហិរញ្ញវត្ថុ TOFE ថ្នាក់ក្រោមជាតិ

❖ ពង្រឹង និងពង្រីកការរៀបចំ GFS និងបង្កើនការផ្សព្វផ្សាយ ដើម្បីបង្កើនប្រសិទ្ធិភាព នៃស្តង់ដារស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល សំរាប់ការប្រើប្រាស់ប្រកបដោយគណនេយ្យភាព និងភាពស័ក្តិសិទ្ធិ

- ស្ថិតិតាមស្តង់ដារ GFS ត្រូវបានត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ដោយជំនាញការ GFS របស់ IMF
- វគ្គបណ្តុះបណ្តាលផ្នែកគណនេយ្យហិរញ្ញវត្ថុ ដើម្បីបង្កើនសមត្ថភាពមន្ត្រីក្នុងការរៀបចំស្តង់ដាស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល
- ទិន្នន័យប្រតិបត្តិការ ហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ ត្រូវបានសិក្សាបញ្ចប់ បន្សល់ទុកទម្រង់ GFS ថ្នាក់ជាតិ (សាកល្បងទិន្នន័យឆ្នាំ ២០១៦)

❖ បន្តចុះស្រង់ថ្លៃទំនិញ និងសេវាលើទីផ្សារនៅរាជធានីភ្នំពេញជាប្រចាំខែ និងនៅតាមបណ្តាខេត្តគោលដៅប្រចាំឆមាស

❖ បន្តចុះតាមដាន និងពិគ្រោះយោបល់លើទិន្នន័យស្ថិតិ និងការវិវត្តស្ថានភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រចាំឆមាស និងឆ្នាំ នៅតាមបណ្តាលរាជធានី ខេត្ត

❖ សិក្សាលទ្ធភាព ការរៀបចំសន្ទស្សន៍ ដូចជា Consumer Confidence Index និង Business Confidence Index។[15]

## ៣.៥ សារៈសំខាន់របស់ការិយាល័យស្ថិតិសេដ្ឋកិច្ចតាមវិស័យ

ការិយាល័យស្ថិតិសេដ្ឋកិច្ចតាមវិស័យ បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងប្រព័ន្ធសេដ្ឋកិច្ចជាតិនាពេលបច្ចុប្បន្ននេះ ដែលមានដូចជា៖

- តាមដាននៅរាល់ស្ថានភាពនៃកំណើន និង តំហយចុះនូវរាល់វិស័យដែលពាក់ព័ន្ធ
- ធ្វើការចងក្រង និងរក្សាទុកនូវរាល់ទិន្នន័យដែលពាក់ព័ន្ធ ដើម្បីទុកជាឯកសារ
- វិភាគទិន្នន័យដើម្បីស្វែងរកដំណោះស្រាយ
- សហការជាមួយស្ថាប័នដែលពាក់ព័ន្ធ ដើម្បីចេញជាគោលនយោបាយ ក្នុងការកែសម្រួលអោយការអភិវឌ្ឍន៍មានប្រសិទ្ធិភាព
- សម្រេចនូវគោលដៅជាយុទ្ធសាស្រ្តរបស់រដ្ឋាភិបាល អោយទទួលបានជោគជ័យ
- ពង្រឹងនូវប្រសិទ្ធិភាពការងាររបស់ក្រសួងដែលពាក់ព័ន្ធ។

## ៣.៦ បញ្ហាប្រឈម

ជាទូទៅនៅក្នុងអង្គភាព ឬអង្គការចាត់តាំងនីមួយៗតែងតែជួបប្រទះនឹងបញ្ហាប្រឈមណាមួយដែលជៀសមិនផុតនោះឡើយ ។ សំរាប់ការិយាល័យស្ថិតិសេដ្ឋកិច្ចតាមវិស័យក៏ដូចគ្នាដែរ បញ្ហាប្រឈមដែលការិយាល័យស្ថិតិសេដ្ឋកិច្ចតាមវិស័យជួបប្រទះកន្លងមកគឺមានដូចខាងក្រោម៖

- កង្វះមន្រ្តីទទួលបន្ទុកលើការងារដែលកំពុងត្រូវបានពង្រីក និងអនុវត្តបន្ថែម
- កង្វះខាតប្រព័ន្ធគ្រប់គ្រងទិន្នន័យ និងសំភារៈប្រើប្រាស់(ចាស់ៗ)
- មន្រ្តីទទួលបន្ទុកវិស័យនីមួយៗនៅមានកម្រិត ដោយសារមិនមានសញ្ញាបត្រស្ថិតិ រឺជំនាញពាក់ព័ន្ធនឹងការអភិវឌ្ឍស្ថិតិឲ្យកាន់តែសំបូរបែប
- កង្វះខាតកិច្ចសហការ និងភាពជាដៃគូររវាងនាយកដ្ឋានស្ថិតិ និងស្ថាប័នស្ថិតិដទៃទៀត ក្នុងការសម្របសម្រួលផ្នែកទទួល និងផ្តល់ទិន្នន័យស្ថិតិតាមវិស័យឲ្យបានជាប់លាប់ និងទាន់ពេលវេលា[16]

[15] របាយការណ៍ស្តីពី វឌ្ឍនភាពសំខាន់ៗ នៃការអនុវត្តការងាររបស់នាយកដ្ឋានស្ថិតិ ប្រចាំឆ្នាំ២០១៦ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៤ ទំព័រទី៥

[16] របាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៥របស់ការិយាល័យស្ថិតិសេដ្ឋកិច្ចតាមវិស័យ ទំព័រទី២

- ទទួលបានទិន្នន័យដែលខុសពីតម្រូវការ (ខុសពីឆ្នាំដែលត្រូវការ )។

## ៣.៧ ដំណោះស្រាយ

ដំណោះស្រាយគឺជាកត្តាចំបាច់មួយរបស់ការិយាល័យស្ថិតិសេដ្ឋកិច្ចតាមវិស័យ ដែលត្រូវតែធ្វើដើម្បីលុបបំបាត់បញ្ហាប្រឈមទាំងអស់នោះដែលជៀសមិនផុត ។ សំរាប់វិធីសាស្រ្ត ក្នុងការដោះស្រាយបញ្ហាដែលកើតមានឡើងកន្លងមករបស់ការិយាល័យ សំរាប់ការដែលធ្វើការស្នើរសុំហើយមិនទទួលបានទិន្នន័យនោះគឺគ្រាន់តែធ្វើសំណើរសារឡើងវិញម្តងទៀតតែប៉ុណ្ណោះ ។ ម្យ៉ាងវិញទៀត ការដែលទទួលបានទិន្នន័យដែលខុសពីតម្រូវការ (ឧទាហរណ៍ ការិយាល័យស្ថិតិសេដ្ឋកិច្ចតាមវិស័យធ្វើការស្នើរសុំទិន្នន័យវិនិយោគក្នុងឆ្នាំ២០១៥ត្រីមាសទី២ ប៉ុន្តែការទទួលបាននោះគឺទិន្នន័យក្នុងឆ្នាំ២០១៥
ត្រីមាសទី១វិញ)ហេតុដូចនេះហើយការិយាល័យគឺមានតែយកទិន្នន័យចាស់នោះមកប្រើប្រាស់ប៉ុណ្ណោះ ។សំរាប់ភាពយឺតយ៉ាវនៃការទទួលបានទិន្នន័យ គឺការិយាល័យត្រូវស្នើរសុំការពន្លឿននៃការផ្តល់អោយ និងធ្វើការពន្យាពេលនៃការចងក្រង និងវិភាគ។ចំពោះការខ្វះខាតមន្រ្តីដែលទទួលបន្ទុកការងារនោះ គឺលោកប្រធាននាយកដ្ឋានបានដាក់សំណើសុំបន្ថែមចំនួនមន្រ្តីដើម្បីជំរុញការងារឲ្យមានភាពរលូន។ ដោយសារតែមន្រ្តីមួយចំនួននៅក្នុងការិយាល័យមានចំណេះដឹង និងសញ្ញាបត្រនៅមានកម្រិត ទើបមានការចូលរួមជាវគ្គបណ្តុះបណ្តាលខ្លីៗ មិនថានៅក្នុងស្រុក និងក្រៅស្រុកជាដើម។ ទោះជាយ៉ាងណាក៏ដោយ បញ្ហាខ្លះក៏ពុំទាន់មានដំណោះស្រាយនៅឡើយដែរ។

## ៣.៨ ចំនុចខ្លាំង

ការិយាល័យសេដ្ឋកិច្ចស្ថិតិតាមវិស័យ មានចំណុចខ្លាំងជាច្រើន ទើបធ្វើអោយមានប្រសិទ្ធិភាពក្នុងដំនើរការការងារ យ៉ាងច្បាស់លាស់ និងត្រឹមត្រូវទៅតាមនិតិវិធី ។ ចំណុចខ្លាំងទាំងនោះមានដូចជា៖

- ការិយាល័យបានកំណត់តួនាទី និងភារកិច្ចយ៉ាងច្បាស់លាស់
- ការគ្រប់គ្រងរាល់ប្រតិបត្តិការមានប្រសិទ្ធិភាពល្អ
- មន្រ្តីមានបទពិសោធន៍ និងមានសមត្ថភាពគ្រប់គ្រាន់
- បំពេញការងារបានត្រឹមត្រូវ និងតាមការកំណត់ទុក
- ប្រើប្រាស់ទិន្នន័យដែលទទួលបានប្រកបដោយប្រសិទ្ធិភាព
- មន្រ្តីមានទំនាក់ទំនងល្អជាមួយស្ថាប័នផ្សេងៗសម្រាប់ការទទួលយកទិន្នន័យ

- ដំណើរការនៃការងារគឺធ្វើទៅតាមនីតិវិធីដែលបានចែងទុក
- មានការជុំរុញ និងលើកទឹកចិត្តពីថ្នាក់លើក្នុងការបំពេញភារកិច្ច
- ធានាបាននូវសុវត្ថិភាពក្នុងការរក្សាទុកទិន្នន័យទាំងពីរប្រភេទ(Hard Copy & Soft Copy)
- រក្សាអធ្យាក្រឹតនូវចំនួនទិន្នន័យដោយគ្មានការលំអៀង ឫខ្លែងបន្លំ
- ធ្វើការតាមដានយ៉ាងជាប់លាប់ចំពោះទិន្នន័យនូវរាល់វិស័យដែលមានស្រាប់ បានកំណត់នូវគោលដៅយ៉ាងច្បាស់ដើម្បីបង្កើននូវទិន្នន័យពីវិស័យផ្សេងៗអោយមានភាពសំបូរបែបនៃទិន្នន័យ ដែលជាតម្រូវការពីស្ថាប័នផ្សេងៗ និងបង្កើនប្រសិទ្ធិភាពនៃការងារ។

## ៣.៩ ចំនុចខ្សោយ

ដោយឡែក ភាពខ្សោយមួយចំណែកតូចដែលជាការរាំងដល់ការងារនោះមានដូចជា ៖

- វិធីសាស្រ្ត ឬរូបមន្តនៃការវិភាគទិន្នន័យនៅមានកម្រិត និងមិនទាន់ឆ្លើយតប ទៅនឹងអ្វីដែលចង់បាននៅឡើយ
- ការប្រើប្រាស់នូវប្រព័ន្ធបច្ចេកវិទ្យាមិនទាន់មានភាពខ្លាំងក្លា និងមិនសូវមានទំនើបកម្ម
- ប្រើប្រាស់នូវប្រភពធនធានមិនទាន់អស់ពីលទ្ធភាព

ចំនួនមន្រ្តីបំរើការនៅមានចំនួនតិច៕

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ១.សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការស្រាវជ្រាវអំពី ដំណើរការនៃការគ្រប់គ្រងទិន្នន័យរបស់ការិយាល័យស្ថិតិសេដ្ឋកិច្ចតាមវិស័យ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុរួចមក យើងទទួលបានទិន្នន័យ និងពត៌មានយ៉ាងច្រើនយកមកធ្វើការប្រៀបធៀបពីការអនុវត្តន៍ជាក់ស្តែង ជាមួយនឹងអ្វីដែលបានសិក្សាកន្លងមក ដើម្បីស្វែងរកចំណុចអវិជ្ជមានព្រមទាំងធ្វើការវាយតម្លៃជារួមមួយថា តើការអនុវត្តន៍ទទួលបានជោគជ័យកម្រិតណាដែរ?

ដោយផ្អែកលើលទ្ធផលដែលសម្រេចបាន យើងអាចសន្និដ្ឋានបានថា ការិយាល័យស្ថិតិសេដ្ឋកិច្ចតាមវិស័យ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុពិតជាអនុវត្តការងារប្រកបដោយប្រសិទ្ធិភាពស្របទៅតាមភារកិច្ច និងតួនាទីរបស់ខ្លួនដែលរដ្ឋាភិបាលបានដាក់ជូនយ៉ាងពិតប្រាកដ។ ប្រសិទ្ធិភាពនេះបណ្តាលមកពី មន្ត្រីគ្រប់ផ្នែក បានបំពេញតួនាទីរបស់ខ្លួនបានត្រឹមត្រូវទៅតាមអ្វីដែលរដ្ឋាភិបាលក៏ដូចជាថ្នាក់លើបានដាក់ជូន មានការសហការយ៉ាងល្អ រវាងមន្ត្រីនៅក្នុងផ្នែកផ្សេងៗ ដែលបណ្តាលអោយដំណើរការនៃការងារមានភាពរលូន និងមានប្រសិទ្ធិភាព ដែលអាចបំពេញបាននូវគ្រប់បេសកម្មបានសម្រេចតាមកាលបរិច្ឆេទ។ ចំពោះការគ្រប់គ្រងទិន្នន័យរបស់ការិយាល័យសេដ្ឋកិច្ចស្ថិតិតាមវិស័យនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុក្នុងការប្រមូលចងក្រង និងវិភាគ គឺបានបំពេញយ៉ាងត្រឹមត្រូវទៅតាម បទបញ្ញត្តិ និងគោលការណ៍ដែលបានចែងទុកយ៉ាងត្រឹមត្រូវ និងច្បាស់លាស់ ។

ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ គ្មានអ្វីដែលល្អឥតខ្ចោះនោះឡើយ គឺតែងតែមានកង្វះខាត និងកំហុសឆ្គងដោយប្រការណាមួយដោយជៀសមិនផុត ដូចគ្នាទៅនឹងការិយាល័យសេដ្ឋកិច្ចតាមវិស័យ ក៏មានចំណុចខ្សោយ និងចំណុចខ្លាំងរបស់ខ្លួនដែរ ។ យ៉ាងណាមិញ ចំណុចខ្សោយទាំងនោះគ្រាន់តែជាចំណុចតូចមួយដែលស្ថិតនៅចន្លោះចំណុចខ្លាំងជាច្រើននៅក្នុងដំណើរការការងារប្រចាំថ្ងៃប៉ុណ្ណោះ។

## ២ អនុសាសន៍

ក្នុងការសិក្សាស្រាវជ្រាវ អស់រយៈពេល៣ខែ ដោយបានចុះកម្មសិក្សា តាមរយៈគេហទំព័រ និងប្រភពខាងក្រៅផ្សេងៗទៀតនោះ យើងសង្កេតឃើញថា ការគ្រប់គ្រងទិន្នន័យរបស់ការិយាល័យសេដ្ឋកិច្ចស្ថិតិតាមវិស័យ គឺមានលក្ខណៈល្អប្រសើរច្រើន ប៉ុន្តែការិយាល័យក៏គួរតែស្វែងរកដំណោះ

ស្រាយសំរាប់បញ្ហាប្រឈមមួយចំនួន ដែលជាកង្វះខាត ដែលអាចធ្វើអោយដំណើរការនៃការងារកាន់តែមានភាពប្រសើរឡើង ។ ដោយផ្អែកលើចំណុចខ្សោយខាងលើ យើងខ្ញុំក៏មានយោបល់មួយចំនួនក្នុងន័យស្ថាប័នា ដើម្បីប្រសិទ្ធិភាព និងការអភិវឌ្ឍន៍ ដែលមានដូចជា៖

- ការិយាល័យគួរតែដាក់តួនាទី ឬភារកិច្ចទៅអោយមន្ត្រីអោយចំទៅនឹងជំនាញ នឹងបទពិសោធន៍របស់ពួកគេ (ប្រើប្រាស់ធនធានអោយអស់ពីប្រសិទ្ធិភាព)
- ខិតខំប្រឹងប្រែងក្នុងការធ្វើសហាប្រតិបត្តិការជាមួយស្ថាប័នផ្សេងៗ ដើម្បីប្រមូលទិន្នន័យអោយបានច្រើនវិស័យ យកមកធ្វើការចងក្រង និងវិភាគ
- សិក្សាបន្ថែមលើការប្រើប្រាស់លើបច្ចេកវិទ្យាទំនើប ដើម្បីប្រសិទ្ធិភាពក្នុងការគ្រប់គ្រងទិន្នន័យ
- ផ្តល់អោយមន្ត្រីបានសិក្សាវគ្គបណ្តុះបណ្តាលអោយកាន់តែច្រើន ដើម្បីពង្រឹងសមត្ថភាព៕

# ឯកសារយោង

# ឯកសារយោង


1. សាស្ត្រាចារ្យ ឈាង ហ៊ុយ ឆ្នាំ២០១៥-២០១៦ «សៀវភៅមូលដ្ឋានគ្រឹះវិនិយោគ»
2. សាស្ត្រាចារ្យ យ៉ក់ បញ្ញាតី ឆ្នាំ២០១៥-២០១៦ «សៀវភៅមូលដ្ឋានគ្រឹះគ្រប់គ្រង»
3. លោក សុខដារ៉ា ឆ្នាំ២០១៦-២០១៧ «ប្លង់មេរៀនការព្យាករណ៍ធុរកិច្ច»
4. សៀវភៅយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣ នីតិកាលទី៥ ចុះខែកញ្ញា ឆ្នាំ២០១៣
5. របាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៥របស់ការិយាល័យស្ថិតិសេដ្ឋកិច្ចតាមវិស័យ
6. របាយការណ៍ស្តីពី វឌ្ឍនភាពសំខាន់ៗ នៃការអនុវត្តការងាររបស់នាយកដ្ឋានស្ថិតិ ប្រចាំឆ្នាំ ២០១៦ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៤
7. ច្បាប់ស្តីពីស្ថិតិ
8. ទិន្នន័យផ្ទាល់ពីការិយាល័យស្ថិតិសេដ្ឋកិច្ចតាមវិស័យ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ


## ការដកស្រង់ពីគេហទំព័រ


**1.** www.mef.gov.kh n.d. ចូលមើលថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ២០១៧

**2.** https://en.wikipedia.org/wiki/Ministry_of_Economy_and_Finance_(Cambodia) ចូលទស្សនាថ្ងៃទី ៩ ខែកក្កដា ឆ្នាំ២០១៧

**3.** http://swiftnewsdaily.com/archieves/15001 ចូលទស្សនាថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០១៧

4. http://youtu.be/tB4Fgtr4Dmcចូលទស្សនាថ្ងៃទី១៥ខែកក្កដាឆ្នាំ២០១៧

# ឧបសម្ព័ន្ធ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ...០៤៨......សហវ.សន

ខុទ្ទកាល័យ ក.ស.ហ.វ.
ចូលថ្ងៃទី...[illegible]/..៤../..១៧..ម៉ោង..........
លេខៈ..[illegible]..៨១៤..............

*រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៧*

**គោរពជូន**

**ឯកឧត្តមបណ្ឌិតទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**កម្មវត្ថុ** ÷ របាយការណ៍ចុះតាមដាន និងពិភាក្សាលើទិន្នន័យស្ថិតិសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមបណ្តាខេត្តគោលដៅសម្រាប់ឆ្នាំ២០១៦។

**យោង** ÷ ចំណារឯកភាពចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៧ លើលិខិតលេខ០១៥ សហវ.សត ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៧ របស់នាយកដ្ឋានស្ថិតិ។

**ភ្ជាប់ជូន**÷ តារាងស្ថិតិសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមបណ្តាខេត្តគោលដៅចំនួន១៥ ខេត្ត (១៥ ច្បាប់) ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមគោរពជម្រាបជូន **ឯកឧត្តមបណ្ឌិតទេសរដ្ឋមន្ត្រី** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា នាយកដ្ឋានស្ថិតិ នៃអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ បានចុះបេសកកម្មតាមដាន និងពិភាក្សាលើទិន្នន័យស្ថិតិសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតាមបណ្តាខេត្តគោលដៅចំនួន១៥[1] ព្រមទាំងការសង្កេតស្ថានភាពសេដ្ឋកិច្ចជាក់ស្តែង ដើម្បីធ្វើបច្ចុប្បន្នភាព និងពង្រីកវិសាលភាពទិន្នន័យសម្រាប់ឆ្លើយតបនឹងតម្រូវការអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ ក្នុងការវាយតម្លៃស្ថានភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុឆ្នាំ២០១៦ និងការព្យាករណ៍នៅឆ្នាំបន្តបន្ទាប់ ព្រមទាំងប្រើប្រាស់ជាធាតុចូលសម្រាប់ការសិក្សាលម្អិត និងស៊ីជម្រៅលើវិស័យនានានៃសេដ្ឋកិច្ច។ ការចុះបេសកកម្មនេះ ត្រូវបានអនុវត្តប្រចាំឆមាសនិងឆ្នាំ ជាមួយមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមន្ទីរអង្គភាពជំនាញលើវិស័យស្នូលទ្រទ្រង់កំណើនសេដ្ឋកិច្ចរបស់ខេត្ត។ តាមការសង្កេតជារួម វិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅក្នុង ឆ្នាំ២០១៦ មានស្ថានភាពល្អប្រសើរ បើប្រៀបធៀបនឹងឆ្នាំ២០១៥។ ប៉ុន្តែ ការចិញ្ចឹមសត្វនៅខេត្តបាត់ដំបង ព្រៃវែង សៀមរាប និងព្រះវិហារ មានការធ្លាក់ចុះ ខណៈខេត្តកំពត និងត្បូងឃ្មុំ មានកំណើនទាប ដែលកត្តានេះអាចនឹងប៉ះពាល់ដល់កំណើនតម្លៃប្រភេទអាហារសាច់។

## ១. ស្ថានភាពកសិកម្ម

**ស្ថានភាពកសិកម្មនៅខេត្តទាំង១៥ ក្នុងឆ្នាំ២០១៦ មានវឌ្ឍនភាពប្រសើរជាងឆ្នាំ២០១៥** យោងតាមកំណើនបរិមាណផលស្រូវ កៅស៊ូ និងផលផលជាពិសេសវារីវប្បកម្ម និងសមុទ្រ ទោះបីជួបប្រឈមនឹងការអូសបន្លាយភាពរាំងស្ងួតរហូតដល់ចុងខែឧសភា ក៏ដោយ។ សម្រាប់លទ្ធភាពស្រោចស្រពវិញ ការផ្គត់ផ្គង់ទឹកតាមរយៈប្រព័ន្ធធារាសាស្ត្រ នៅមិនទាន់

---

[1] ក). ខេត្តត្បូងឃ្មុំ ក្រចេះ និងស្ទឹងត្រែង, ខ). តាកែវ កំពត និងព្រះសីហនុ, គ). បាត់ដំបង ប៉ៃលិន និងបន្ទាយមានជ័យ, ឃ). កំពង់ចាម ព្រៃវែង និងស្វាយរៀង, និង ង). កំពង់ធំ សៀមរាប និងព្រះវិហារ។

គ្រប់គ្រាន់ សម្រាប់ប្រជាកសិករនៅផ្នែកខាងក្រោមនៃប្រឡាយមេ។ សង្កេតជារួម តម្លៃផលិតផលកសិកម្ម ដូចជាស្រូវ និង បន្លែមួយចំនួន នៅខេត្តបាត់ដំបង បន្ទាយមានជ័យ និងត្បូងឃ្មុំ បានធ្លាក់ចុះទាប។ រីឯ ការចិញ្ចឹមសត្វនៅខេត្តបាត់ដំបង ព្រៃវែង សៀមរាប និងព្រះវិហារ ក៏មានការធ្លាក់ចុះ ខណៈខេត្តកំពត និងត្បូងឃ្មុំ មានកំណើនទាប ដែលកត្តានេះអាចនឹង ប៉ះពាល់ដល់កំណើនតម្លៃប្រភេទអាហារសាច់។ តាមការសង្កេតពីមួយឆ្នាំទៅមួយឆ្នាំ តម្លៃជ្រូក និងមាន់រស់ដែលលក់ ចេញពីកសិដ្ឋានចិញ្ចឹមរបស់កសិករ មានតម្លៃទាបដែលជាមូលហេតុនៃការថមថយកំណើនផលិតកម្មសត្វ។

**២. ស្ថានភាពឧស្សាហកម្ម**

**តាមការសង្កេត ចំនួនសហគ្រាសចុះបញ្ជីនៅខេត្តទាំង ១៥ ក្នុងឆ្នាំ២០១៦ កន្លងទៅនេះ បានកើនឡើងខ្ពស់ជាងឆ្នាំ ២០១៥** ពិសេសគឺកំណើននៃការចុះបញ្ជីសហគ្រាសធុនតូចនិងមធ្យម ព្រមទាំងការរីកលូតលាស់នៃវិសាលភាពផ្គត់ផ្គង់រ៉ែ និងថាមពលដែលបានឆ្លុះបញ្ចាំងពីតម្រូវការប្រើប្រាស់របស់ប្រជាជនក្នុងស្រុក។

ក្រៅពីការវិនិយោគបន្ថែមលើរោងចក្រចំណីសត្វ ស៊ីម៉ងត៍ កែច្នៃផលិតផលកសិកម្ម និងរោងចក្រកែច្នៃក្រណាត់ កៅស៊ូ និងគ្រឿងដែក ក៏សង្កេតឃើញមានរោងចក្របង្គុំគ្រឿងបន្លាស់កុំព្យូទ័រនៅខេត្តបន្ទាយមានជ័យ ដែលឆ្លុះបញ្ចាំងពី ការធ្វើពិពិធកម្មមុខទំនិញនិងទីផ្សារបន្ថែម និងប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មឆ្នាំ២០១៥ -២០២៥ ផងដែរ។

ការផ្គត់ផ្គង់ថាមពលសម្រាប់ខេត្តទាំងអស់នេះ មានស្ថានភាពកាន់តែរឹងមាំនិងប្រសើរ ពោលគឺបានពង្រីកវិសាល ភាពស្ទើរគ្រប់ឃុំក្នុងខេត្ត ដើម្បីឆ្លើយតបនឹងកំណើនប្រើប្រាស់របស់ប្រជាជន ព្រមទាំងកំណើនរោងចក្រ និងសិប្បកម្ម។ ថ្លៃអគ្គិសនីសម្រាប់អ្នកប្រើប្រាស់នឹងមានការធ្លាក់ចុះជាបន្តបន្ទាប់នៅខេត្តត្បូងឃ្មុំ ក្រចេះ និងស្ទឹងត្រែង ដោយសារមានការ បើកឱ្យប្រើប្រាស់នូវស្ថានីយវារីអគ្គិសនីមួយចំនួននៅខេត្តស្ទឹងត្រែង។ ចំណែកឯអាជីវកម្មរ៉ែវិញ នៅខេត្តក្រចេះ និង ស្ទឹងត្រែង គឺជាខេត្តមានសក្តានុពលខ្ពស់លើរ៉ែថ្មម៉ាបដ៏កម្រ និងមានតម្លៃខ្ពស់ ដែលនឹងរំពឹងថានឹងផ្តល់ចំណូលជាច្រើន ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**៣. ស្ថានភាពទេសចរណ៍**

**សម្រាប់ឆ្នាំ២០១៦ កន្លងទៅនេះ ចំនួនភ្ញៀវទេសចរ (ភ្ញៀវជាតិ និងអន្តរជាតិ) និងសេវាកម្មទេសចរណ៍ ដូចជា សណ្ឋាគារនិងផ្ទះសំណាក់ និងភោជនីយដ្ឋានផងដែរ នៅតាមបណ្តាខេត្តចំនួន១៥ មានកំណើនគួរឱ្យកត់សម្គាល់** បើធៀប នឹងឆ្នាំ២០១៥។ កំណើននេះ ដោយសារ (ក).ការដាក់ចេញនូវគោលនយោបាយអភិវឌ្ឍវិស័យទេសចរណ៍ តាមរយៈការ កែច្នៃ កែលម្អ និងអភិវឌ្ឍតំបន់រមណីយដ្ឋានទេសចរណ៍ទាំងផ្នែកធម្មជាតិ ប្រវត្តិសាស្ត្រ វប្បធម៌ អេកូឡូស៊ី និងតំបន់ លំហែកាយ (ខ).ការរៀបចំកម្មវិធីផ្សេងៗដូចជា បុណ្យសមុទ្រ បុណ្យទន្លេ និងបុណ្យចំប៉ើង និង (គ). ការផ្សព្វផ្សាយបាន ទូលំទូលាយពីវិស័យទេសចរណ៍លើឆាកអន្តរជាតិ ស្របពេលដែលស្ថានភាពនយោបាយមានស្ថិរភាព និងការអភិវឌ្ឍហេដ្ឋា រចនាសម្ព័ន្ធផ្លូវថ្នល់ដល់តំបន់ទេសចរណ៍។ ម្យ៉ាងទៀត ការកើនឡើងភ្ញៀវទេសចរក្នុងស្រុក គឺបណ្តាលពីកំណើនកម្រិត ជីវភាពរបស់ប្រជាពលរដ្ឋ ដែលជាផ្លែផ្កានៃកំណើនសេដ្ឋកិច្ចក្នុងទសវត្សរ៍ចុងក្រោយនេះ។

**៤. ស្ថានភាពពាណិជ្ជកម្ម**

**ទំហំពាណិជ្ជកម្មនៅតាមច្រកអន្តរជាតិ ក្នុងឆ្នាំ២០១៦ កន្លងទៅនេះ មានភាពប្រសើរជាងឆ្នាំ២០១៥** ដោយសារការ ខិតខំជួយសម្របសម្រួលនីតិវិធីនិងបែបបទនៃការនាំចេញ-នាំចូលទំនិញ ទោះបីជានៅមានបញ្ហាប្រឈមមួយចំនួនដូច ជា ការពង្រឹងវិធានការនាំចូលរបស់ប្រទេសជិតខាង និងការធ្លាក់ចុះនៃតម្លៃកសិផលក្នុងស្រុកក៏ដោយ។

ស្ថានភាពនាំចូល តាមរយៈចំណូលពន្ធគយនៅតាមច្រកអន្តរជាតិជាមួយប្រទេសវៀតណាម នៅតែមានកំណើនខ្ពស់ បើប្រៀបធៀបនឹងផែនការចំណូលក្នុងឆ្នាំ២០១៦ ឬការអនុវត្តប្រមូលចំណូលឆ្នាំ២០១៥ ដោយសារកំណើនប្រើប្រាស់គ្រឿងឧបភោគបរិភោគ ឧបករណ៍កសិកម្ម ជី ចំណីសត្វនិងវត្ថុធាតុដើមចំណីសត្វ ម៉ូតូ សម្ភារសំណង់ និងគ្រឿងប្រើប្រាស់ផ្សេងៗ។ ជាក់ស្តែង ចំណូលពន្ធគយនៅខេត្តកំពតមានការកើនឡើង៣០៦% ធៀបនឹងឆ្នាំ២០១៥ ដោយសារកំណើនមុខទំនិញនាំចូលថ្មីៗ ដូចជា ធ្យូងថ្ម និងវត្ថុធាតុដើមសម្រាប់ផលិតស៊ីម៉ងត៍។ ដោយឡែក ស្ថានភាពនាំចូលតាមរយៈចំណូលពន្ធគយនៅតាមច្រកអន្តរជាតិជាមួយប្រទេសថៃ នៅមានសក្តានុពលខ្ពស់លើការដោះដូរពាណិជ្ជកម្ម។

ទំនិញនាំចេញសំខាន់ៗ តាមច្រកអន្តរជាតិជាមួយប្រទេសថៃ និងវៀតណាម រួមមាន ដំឡូងមីក្រៀម កៅស៊ូ សម្លៀកបំពាក់ និងគ្រឿងបង្គុំកុំព្យូទ័រ។

**៥. ស្ថានភាពសំណង់**

**ស្ថានភាពសំណង់នៅតាមបណ្តាខេត្តមួយចំនួន មានសន្ទុះខ្លាំងក្នុងឆ្នាំ២០១៦** កន្លងទៅនេះ ដោយសារកត្តាកំណើនជីវភាពរបស់ប្រជាពលរដ្ឋ ព្រមទាំងស្ថិរភាពនយោបាយ ដែលធានាដល់កំណើនការវិនិយោគទុនបន្ថែមក្នុងវិស័យសំណង់នេះ ពីមួយឆ្នាំទៅមួយឆ្នាំ។ តាមការសង្កេត សំណង់លំនៅដ្ឋាន ដូចជា ផ្ទះល្វែង និងភូមិគ្រឹះ, សំណង់ពាណិជ្ជកម្ម និងសំណង់ទេសចរណ៍ មានការរីកលូតលាស់ខ្លាំង ដែលភាគច្រើនប្រមូលផ្តុំនៅក្នុងទីប្រជុំជន និងទីរួមស្រុក។ បើប្រៀបធៀបប្រភេទសំណង់ខាងលើ សំណង់ឧស្សាហកម្ម វិនិយោគ និងសំណង់សាធារណៈ មានកំណើនទាប ដែលចាំបាច់ត្រូវមានការកៀរគរវិនិយោគបន្ថែម សំដៅជំរុញស្ថិរភាពនៃការវិនិយោគសំណង់ទាំងអស់នេះ។

ទោះបីជាស្ថានភាពសំណង់នៅតាមបណ្តាខេត្ត មានភាពប្រសើរយ៉ាងណាក្តី ការផ្តល់សេវាផ្នែកសំណង់ និងវប្បធម៌មិនសុំច្បាប់សាងសង់របស់ប្រជាពលរដ្ឋ នៅតែជាបញ្ហាប្រឈម។ ជាក់ស្តែង (ក).ការចុះបញ្ជីសាងសង់នៅខ្វះចន្លោះ ពោលគឺសំណង់ខុសច្បាប់នៅមានចំនួនច្រើនក្នុងរង្វង់២០% ទៅ ៥០% នៃសំណង់សរុប និង (ខ).ការស្ម័គ្រចិត្តរបស់ពលរដ្ឋក្នុងការចុះបញ្ជីសាងសង់នៅមានកម្រិត ពោលគឺការចុះបញ្ជីត្រូវបានធ្វើឡើងតែនៅតាមតំបន់ទីប្រជុំជនតែប៉ុណ្ណោះ ។

**៦. ស្ថានភាពហិរញ្ញវត្ថុសាធារណៈ**

**ស្ថានភាពអនុវត្តផ្នែកហិរញ្ញវត្ថុសាធារណៈសម្រាប់ខេត្តទាំង១៥ ក្នុងឆ្នាំ២០១៦ កន្លងទៅនេះ មានលក្ខណៈល្អប្រសើរជាងឆ្នាំ២០១៥។** ការប្រមូលចំណូលនៅថ្នាក់ក្រោមជាតិទាំងចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ បានអនុវត្តលើសផែនការដែលបានកំណត់។ ការអនុវត្តចំណូលពន្ធបានល្អប្រសើរនេះ ដោយសារ (ក).ការបង្វែរការបង់ពន្ធពីសាខាពន្ធដារទៅធនាគារដែលជាហេតុនាំឱ្យអ្នកជាប់ពន្ធមានទំនុកចិត្តខ្ពស់ (ខ).ការបន្តបញ្ច្រាបវប្បធម៌បង់ពន្ធ (គ).ការពង្រឹងការធ្វើសវនកម្មសហគ្រាស និង (ឃ).ការខិតខំប្រឹងប្រែងរបស់អង្គភាពប្រមូលចំណូលផ្ទាល់។ ទន្ទឹមនេះ គេសង្កេតឃើញថាចំណូលបានកើនឡើងក៏ដោយសារការរីកលូតលាស់នៃវិស័យសំណង់ (ការផ្ទេរអចលនទ្រព្យ និងពន្ធប្រថាប់ត្រា) និងវិស័យរ៉ែផងដែរ។ ចំណែកឯការចំណាយ ត្រូវបានអនុវត្តកាន់តែមានប្រសិទ្ធភាពដោយសារ (ក).ភាពប្រសើរឡើងនៃការកែលម្អនីតិវិធីចំណាយ (ខ).ការយល់ជ្រាបកាន់តែច្បាស់នៃនីតិវិធីចំណាយ និងការយល់ដឹងពីការពង្រឹងប្រសិទ្ធភាពចំណាយថវិកា តាមរយៈការអនុវត្តថវិកាកម្មវិធី តាមប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យាហិរញ្ញវត្ថុសាធារណៈ និងជំនួយរបស់សៀវភៅថវិកាប្រចាំឆ្នាំ។

## ៧. សេចក្ដីសន្និដ្ឋាន

ជារួម យោងតាមស្ថិតិ និងការសង្កេតជាក់ស្ដែង ស្ថានភាពសេដ្ឋកិច្ចនៅតាមបណ្ដាខេត្តទាំង១៥ នៅបន្តមានភាពល្អប្រសើរជាងឆ្នាំកន្លងមក ដោយសារ (ក).កំណើនផលិតផលកសិកម្ម (ខ).ការចុះបញ្ជីឧស្សាហកម្មនិងសិប្បកម្មថ្មីៗ ជាពិសេសការវេចខ្ចប់ និងបច្ចេកទេសផលិត ដែលឆ្លុះបញ្ចាំងពីការរីកលូតលាស់នៃវិស័យឧស្សាហកម្មនៅកម្ពុជា (គ) កំណើនភ្ញៀវទេសចរក្នុងស្រុកនិងអន្តរជាតិ និងតម្រូវការលំនៅដ្ឋាន (វិស័យទេសចរណ៍ និងសំណង់) និង (ឃ).កំណើនចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ(លើផ្នែករ៉ែនិងថាមពល) ដែលគាំទ្រដោយកិច្ចខិតខំប្រឹងប្រែងក្នុងការអនុវត្តវិធានការប្រមូលចំណូលរបស់រាជរដ្ឋាភិបាលកម្ពុជា។ ទោះបីយ៉ាងណាក្ដី វិស័យទេសចរណ៍របស់បណ្ដាខេត្តទាំងអស់នេះ ទាមទារនូវការបង្កើតតម្លៃបន្ថែមផ្សេងទៀតក្រៅពីរមណីយដ្ឋានធម្មជាតិ និងប្រវត្តិសាស្ត្រ តាមរយៈការធ្វើពិពិធកម្មកន្លែងកំសាន្តនិងហេដ្ឋារចនាសម្ព័ន្ធបន្ថែម និងការវិនិយោគបន្ថែមលើសំណង់ពាណិជ្ជកម្ម ឧស្សាហកម្ម និងទេសចរណ៍ ដែលអាចនឹងជួយទ្រទ្រង់ដល់សេដ្ឋកិច្ចខេត្តរបស់ខ្លួន។

យោងតាមការចុះបេសកកម្មខាងលើនេះ ក្រុមការងារយល់ឃើញថា ទិន្នន័យស្ថិតិសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅថ្នាក់ក្រោមជាតិពិតជាមានសារសំខាន់សម្រាប់ផ្ទៀងផ្ទាត់ទិន្នន័យថ្នាក់ជាតិ ការវិភាគនិងវាយតម្លៃស្ថានភាពសេដ្ឋកិច្ចប្រចាំឆមាស និងឆ្នាំ និងមូលដ្ឋានទិន្នន័យសម្រាប់គាំទ្របាយការណ៍ស្ដីពីការតាមដានវឌ្ឍនភាពម៉ាក្រូសេដ្ឋកិច្ចកម្ពុជាប្រចាំឆ្នាំ និងការព្យាករណ៍នៅឆ្នាំបន្តបន្ទាប់ ព្រមទាំងប្រើប្រាស់សម្រាប់ការងារផ្សេងៗរបស់អគ្គនាយកដ្ឋានដូចជា ការចងក្រង និងគ្រប់គ្រងទិន្នន័យរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតាមរយៈឃ្លាំងផ្ទុកទិន្នន័យ (MEF Database) និងព្រឹត្តិបត្រស្ថិតិសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាដើម។ ដោយមើលឃើញពីសារសំខាន់ខាងលើ និងធានាបាននិរន្តរភាពនៃការចងក្រងទិន្នន័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនោះ នាយកដ្ឋានស្ថិតិសូមគោរពស្នើសុំគោលការណ៍ដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមបណ្ឌិតទេសរដ្ឋមន្ត្រី** ដើម្បីបន្តចុះតាមដាន និងពិភាក្សាលើទិន្នន័យស្ថិតិសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតាមបណ្ដាខេត្តជាប្រចាំឆមាសនិងឆ្នាំ ព្រមទាំងពង្រីកវិសាលភាពទិន្នន័យឱ្យបានគ្រប់ខេត្តគោលដៅសំខាន់។

អាស្រ័យដូចបានជម្រាបជូនខាងលើសូម **ឯកឧត្តមបណ្ឌិតទេសរដ្ឋមន្ត្រី** មេត្តាជ្រាបជាសេចក្ដីរាយការណ៍ និងមានមតិណែនាំជាយថាហេតុដ៏ខ្ពង់ខ្ពស់។

សូម**ឯកឧត្តម** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

**ប្រធាននាយកដ្ឋានស្ថិតិ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៣១៨ សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការរៀបចំ និងការប្រព្រឹត្តទៅ នៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទ អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៤៤៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

៤

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

ស្ថិតិសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឃ្លាំងផ្ទុកទិន្នន័យ MEF Info Databases និងសម្រាប់ប្រើប្រាស់ក្នុង

ជាមួយនឹងអត្រាការប្រាក់របស់គ្រឹះស្ថានធនាគារពាណិជ្ជ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ផ្នែកអត្រាប្តូរប្រាក់ ទុនបម្រុងជារូបិយប័ណ្ណបរទេស និងព័ត៌មានស្តីពីការដាក់ចេញផ្សាយឧបករណ៍រូបិយវត្ថុរបស់ធនាគារជាតិនៃកម្ពុជា និងស្ថានភាពរូបិយវត្ថុតាមបណ្តាប្រទេសនានា។ របាយការណ៍នេះ ជាធាតុចូលយ៉ាងសំខាន់សម្រាប់របាយការណ៍និន្នាការសេដ្ឋកិច្ច-សង្គម ព្រឹត្តិបត្រស្ថិតិសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឃ្លាំងផ្ទុកទិន្នន័យ MEF Info Databases និងសម្រាប់ប្រើប្រាស់ក្នុងអគ្គនាយកដ្ឋាន។

១១. ការអភិវឌ្ឍឃ្លាំងផ្ទុកទិន្នន័យ (MEF Info Database)៖ ឃ្លាំងផ្ទុកទិន្នន័យនេះ គឺជាកម្មវិធីដែលផ្ទុកនូវបណ្តុំទិន្នន័យនៃសូចនាករម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាប្រចាំខែ ត្រីមាស និងប្រចាំឆ្នាំ ដែលត្រូវបានរៀបចំជាច្រើនដំណាក់កាលចាប់ពីឆ្នាំ២០១៥ និងបានបញ្ចប់នៅខែកញ្ញា ឆ្នាំ២០១៦ ព្រមទាំងបានធ្វើបច្ចុប្បន្នភាពទិន្នន័យជាប្រចាំ។

១២. ចេញរបាយការណ៍ថ្លៃទំនិញ និងសេវាលើទីផ្សារ (Market Prices) នៅរាជធានីភ្នំពេញប្រចាំខែ និងត្រីមាស និងនៅតាមបណ្តាខេត្តប្រចាំឆមាស៖ របាយការណ៍នេះ ត្រូវរៀបចំឡើងសម្រាប់ការងារលទ្ធកម្មសាធារណៈ និងចេញជាត្រីមាស ដោយប្រមូលនិងស្រង់ថ្លៃទំនិញនិងសេវាលើទីផ្សារនៅរាជធានីភ្នំពេញ ចំនួន ១០២៣មុខ ស្មើនឹង១២ ក្រុមទំនិញ និងចេញតារាងថ្លៃទំនិញនិងសេវាលើទីផ្សារនៅរាជធានីភ្នំពេញជាប្រចាំខែ ព្រមទាំងបានផ្សព្វផ្សាយលើគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាប្រចាំ។ ចំណែកឯ របាយការណ៍ថ្លៃទំនិញនិងសេវាលើទីផ្សារនៅតាមបណ្តាខេត្ត ត្រូវបានចុះស្រង់ថ្លៃជាប្រចាំឆមាស។

១៣. ការងារចុះបេសសកម្មនៅតាមបណ្តាខេត្ត៖ ក្រុមការងារនៃនាយកដ្ឋានបានចុះបេសកកម្មនៅតាមបណ្តាខេត្តគោលដៅ មានដូចជា៖

- ការចុះតាមដាន និងពិគ្រោះយោបល់លើទិន្នន័យស្ថិតិ និងការវិវត្តស្ថានភាពសេដ្ឋកិច្ចនិងហិរញ្ញវត្ថុប្រចាំឆមាសនិងឆ្នាំ៖ ក្នុងបំណងធ្វើបច្ចុប្បន្នភាព និងពង្រីកវិសាលភាពស្ថិតិទិន្នន័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈការចុះតាមដាន និងពិភាក្សាជាទៀងទាត់ជាមួយស្ថាប័នផ្តល់ទិន្នន័យរួមមានរដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដោយសិក្សាលម្អិត និងស៊ីជម្រៅលើសមិទ្ធផលហិរញ្ញវត្ថុនិងសេដ្ឋកិច្ចតាមវិស័យ ក៏ដូចជាគោលកំនិតសម្រាប់គាំទ្រការចងក្រងនិងគ្រប់គ្រងទិន្នន័យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងប្រើប្រាស់ជាធាតុចូលសម្រាប់ការងារផ្សេងៗក្នុងអគ្គនាយកដ្ឋាន។

- ការចុះស្រង់ថ្លៃទំនិញ និងសេវាលើទីផ្សារនៅតាមបណ្ដាខេត្ត÷ ក្រុមការងារចុះស្រង់ថ្លៃទំនិញ និងសេវាលើទីផ្សារនៅតាមបណ្ដាខេត្ត រៀងរាល់មួយឆមាសម្ដង និងចេញជារបាយការណ៍ថ្លៃទំនិញនិងសេវាលើទីផ្សារនៅតាមបណ្ដាខេត្តប្រចាំឆមាស។
- ការចុះតាមដាន និងសិក្សានិន្នាការវិវត្តនៃវិស័យសំណង់សម្រាប់ឆ្នាំ២០១៦÷ ដោយផ្ដោតលើការចងក្រងតាមដាន និងសិក្សាការវិវត្តវិស័យសំណង់នៅតាមបណ្ដាខេត្ត ដែលជាវិស័យមួយជួយជំរុញកំណើនសេដ្ឋកិច្ចជាតិ ព្រមទាំងបញ្ហាប្រឈម និងទិសដៅសម្រាប់ការអភិវឌ្ឍវិស័យសំណង់នៅតាមបណ្ដាខេត្តនីមួយៗ។
- ការចុះសិក្សារកគន្លឹះ និងលទ្ធភាពកសាងមូលដ្ឋានទិន្នន័យស្ថិតិហិរញ្ញវត្ថុសាធារណៈថ្នាក់ក្រោមជាតិ÷ ក្រុមការងារបានចុះទៅតាមបណ្ដារខេត្តគោលដៅមួយចំនួន ដើម្បីជួបពិភាក្សាជាមួយក្រុមមន្ត្រីមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរតនាគារខេត្តក្នុងគោលបំណងផ្សព្វផ្សាយចំណេះដឹងអំពី TOFE/GFS និងសិក្សាស្វែងយល់ពី ឬសគល់គណនី លំហូរទិន្នន័យ ការកត់ត្រា និងវិធីសាស្ត្ររៀបចំទិន្នន័យ" នៅថ្នាក់ក្រោមជាតិ ដើម្បីជាមូលដ្ឋានក្នុងការពិនិត្យលទ្ធភាពពង្រីកវិសាលភាពទិន្នន័យ TOFE/GFS ដល់ថ្នាក់ក្រោមជាតិ ហើយក្រុមការងារបានចេញជារបាយការណ៍ស្ដីពីលទ្ធផលនៃការសិក្សារកគន្លឹះ និងលទ្ធភាពកសាងមូលដ្ឋានទិន្នន័យស្ថិតិហិរញ្ញវត្ថុសាធារណៈថ្នាក់ក្រោមជាតិ។

## ខ. ទិសដៅសម្រាប់ឆ្នាំ២០១៧

ក្នុងឆ្នាំ២០១៧នេះ ដើម្បីបង្កើនប្រសិទ្ធភាពលើការចងក្រង វិភាគ និងផ្សព្វផ្សាយការងារស្ថិតិ នាយកដ្ឋានស្ថិតិមានផែនការ និងទិសដៅដូចងក្រោម÷

- បន្តពង្រីកការប្រមូល និងចងក្រងទិន្នន័យស្ថិតិគ្រប់វិស័យពាក់ព័ន្ធឱ្យកាន់តែទូលំទូលាយ និងមានប្រសិទ្ធភាព
- ពន្លឿន និងចេញផ្សាយរបាយការណ៍សេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានទាន់ពេលវេលាកំណត់÷
    - របាយការណ៍ប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋ (ស្តង់ដារ TOFE) ប្រចាខែ និងត្រូវបានចេញផ្សាយលើគេហទំព័រក្រសួងមិនលើសពី២សប្ដាហ៍បន្ទាប់ពីបាយការណ៍បានបញ្ចប់រួចរាល់
    - របាយការណ៍ប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋាភិបាល(ស្តង់ដារ GFS)ប្រចាំខែ និងត្រូវបានចេញផ្សាយលើគេហទំព័រក្រសួងមិនលើសពី២សប្ដាហ៍បន្ទាប់ពីរបាយការណ៍បានបញ្ចប់រួចរាល់

- របាយការណ៍និន្នាការសេដ្ឋកិច្ចសង្គម (FLASH REPORT) ប្រចាំខែ និងត្រូវបានចេញផ្សាយលើគេហទំព័រក្រសួងមិនលើសពី២សប្តាហ៍បន្ទាប់ពីរបាយការណ៍
- ព្រឹត្តិបត្រស្ថិតិសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (BULLETIN) ប្រចាំត្រីមាស និងត្រូវបានបោះពុម្ពផ្សាយជាសាធារណៈ និងចេញផ្សាយលើគេហទំព័រក្រសួង (នៅត្រីមាសបន្ទាប់)
- របាយការណ៍ការវិវត្តថ្លៃទំនិញប្រើប្រាស់នៅរាជធានីភ្នំពេញ (CPI) ជាប្រចាំខែ និងត្រូវបានចេញផ្សាយលើគេហទំព័រក្រសួងជាប្រចាំ។

- ពង្រឹងសមត្ថភាពវិភាគស្ថិតិ និងតាមដានស្ថានភាពសេដ្ឋកិច្ចតាមវិស័យ មានដូចជា÷
  - ចេញរបាយការណ៍តាមដាន និងវាយតម្លៃពាណិជ្ជកម្មក្រៅប្រទេស [Real/Nominal Effective Exchange Rate (REER/NEER)]
  - ចេញរបាយការណ៍វិស័យទេសចរណ៍ជាប្រចាំខែ និងរបាយការណ៍ស្ថិតិវិស័យទេសចរណ៍នៅខេត្តចំនួន១២
  - ចេញរបាយការណ៍វិស័យសំណង់ និងវិនិយោគឯកជន ជាប្រចាំខែ
  - ចេញរបាយការណ៍ស្តីពីពាណិជ្ជកម្មកម្ពុជា ជាប្រចាំខែ និងរបាយការណ៍សិក្សាស្វែងយល់ពីការកត់ត្រាទិន្នន័យពាណិជ្ជកម្មអន្តរជាតិ ត្រូវបានរៀបចំឡើង
  - ចេញរបាយការណ៍ស្តីពីស្ថានភាពរូបិយវត្ថុកម្ពុជា ជាប្រចាំខែ
  - ចេញរបាយការណ៍វិស័យកសិកម្ម ជាប្រចាំត្រីមាស
  - ចេញរបាយការណ៍វិស័យឧស្សាហកម្ម និងសិប្បកម្មជាប្រចាំខែ
- ពង្រឹង និងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងទិន្នន័យ
  - បន្តធ្វើបច្ចុប្បន្នភាពទិន្នន័យក្នុងឃ្លាំងផ្ទុកទិន្នន័យ MEF Database ជាប្រចាំ
  - រៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោល MEF Databases និងសិក្ខាសាលាផ្សព្វផ្សាយ វគ្គបណ្តុះបណ្តាល ក្នុងគោលដៅតាមដានស្ថានភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានផ្សព្វផ្សាយទៅអ្នកប្រើប្រាស់ នៃអគ្គនាយកដ្ឋានពាក់ព័ន្ធមួយចំនួន (សហវ) និងដល់ក្រសួង-ស្ថាប័នផ្តល់ទិន្នន័យក្នុងគោលបំណងប្រសិទ្ធភាពប្រមូលទិន្នន័យ
  - ចេញរបាយការណ៍វាយតម្លៃប្រសិទ្ធភាព នៃការប្រើប្រាស់ MEF Database
  - អភិវឌ្ឍប្រព័ន្ធសម្រួលការងារ និងគ្រប់គ្រងទិន្នន័យ

- វគ្គបណ្ដុះបណ្ដាល និងការដកស្រង់បទពិសោធន៍លើការគ្រប់គ្រងប្រព័ន្ធស្ថិតិ (Database Management) នៅប្រទេសជប៉ុន ក្នុងគោលដៅបង្កើនសមត្ថភាព និងប្រសិទ្ធភាពនៃការអភិវឌ្ឍ និងការគ្រប់គ្រងទិន្នន័យ
- បន្តរៀបចំយន្តការសម្របសម្រួលទិន្នន័យជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ

- បង្កើនប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃស្តង់ដារស្ថិតិហិរញ្ញវត្ថុ (TOFE) សម្រាប់ការប្រើប្រាស់
  - របាយការណ៍ត្រួតពិនិត្យ និង ផ្ទៀងផ្ទាត់ស្ថិតិហិរញ្ញវត្ថុ (មាន-Province visits)
  - ស្តង់ដារស្ថិតិប្រតិបត្តិការហិរញ្ញវត្ថុ TOFE ថ្នាក់ក្រោមជាតិ
- ពង្រឹង និងពង្រីកការរៀបចំ GFS និងបង្កើនការផ្សព្វផ្សាយ ដើម្បីបង្កើនប្រសិទ្ធភាពនៃស្តង់ដារស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល (GFS) សម្រាប់ការប្រើប្រាស់ប្រកបដោយគណនេយ្យភាព និងស័ក្តិសិទ្ធភាព
  - ស្ថិតិតាមស្តង់ដារ GFS ត្រូវបានពិនិត្យ និងផ្ទៀងផ្ទាត់ដោយជំនាញការ GFS របស់ IMF
  - វគ្គបណ្ដុះបណ្ដាលផ្នែកគណនេយ្យហិរញ្ញវត្ថុ ដើម្បីបង្កើនសមត្ថភាពមន្ត្រីក្នុងការរៀបចំស្តង់ដារស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល (GFS)
  - ទិន្នន័យប្រតិបត្តិការហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ ត្រូវបានសិក្សាបញ្ចប់ និង បន្ស៊ីក្នុងទម្រង់ GFS
  - ទិន្នន័យ Extra-budgetary នៃអង្គភាពសាធារណៈរដ្ឋបាល ត្រូវសាកល្បងបញ្ចូលក្នុង GFS ថ្នាក់ជាតិ (សាកល្បងទិន្នន័យឆ្នាំ ២០១៦)
- បន្តចុះស្រង់ថ្លៃទំនិញ និងសេវាលើទីផ្សារនៅរាជធានីភ្នំពេញជាប្រចាំខែ និងនៅតាមបណ្ដាខេត្តគោលដៅប្រចាំឆមាស។
- បន្តចុះតាមដាន និងពិគ្រោះយោបល់លើទិន្នន័យស្ថិតិ និងការវិវត្តស្ថានភាពសេដ្ឋកិច្ចនិងហិរញ្ញវត្ថុប្រចាំឆមាសនិងឆ្នាំ នៅតាមបណ្ដារាជធានី-ខេត្ត។
- សិក្សាលទ្ធភាពការរៀបចំសន្ទស្សន៍ដូចជា Consumer Confidence Index និង Business Confidence Index ។

*រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៧*

**អ្នករៀបចំរបាយការណ៍**

បានឃើញ និងឯកភាព

**ប្រធាននាយកដ្ឋានស្ថិតិ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ..................សហវ.....

សូមគោរពជូន

លោកប្រធាន នាយកដ្ឋានស្ថិតិ

**កម្មវត្ថុ:** របាយការណ៍ស្តីពីការបូកសរុបលទ្ធផលការងារប្រចាំឆ្នាំរបស់ការិយាល័យស្ថិតិសេដ្ឋកិច្ចតាមវិស័យ ។

តបតាមកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបជូនលោកប្រធានពីសមិទ្ធផលការងារ របស់ការិយាល័យស្ថិតិសេដ្ឋកិច្ចតាមវិស័យសម្រាប់ឆ្នាំ២០១៥ ដូចខាងក្រោម÷

## ១. វឌ្ឍនភាពក្នុងការបំពេញភារកិច្ចស្នូល និងភារកិច្ចជំនាញ

### ១.១. ភារកិច្ចជំនាញ និងការសម្របសម្រួល

ការិយាល័យស្ថិតិសេដ្ឋកិច្ចតាមវិស័យ បានបន្តធ្វើការសម្របសម្រួលជាមួយក្រសួងចំនួន ១១ បន្ថែមទៀត ដើម្បីប្រមូល ចងក្រង រៀបចំរបាយការណ៍ខ្លីៗ និងជាពិសេសរៀបចំកម្រងទិន្នន័យមូលដ្ឋាន សំដៅធ្វើឲ្យនាយកដ្ឋានស្ថិតិមានទិន្នន័យកាន់តែសំបូរបែប ឆ្លើយតបនឹងកំណើនតម្រូវការប្រើប្រាស់ទិន្នន័យជាប្រចាំ និងជាធាតុចូលដ៏សំខាន់សម្រាប់ព្រឹត្តិប័ត្រសេដ្ឋកិច្ច ក៏ដូចជារបាយការណ៍និន្នាការសេដ្ឋកិច្ច-សង្គម ។ ក្នុងន័យនេះ ការិយាល័យស្ថិតិសេដ្ឋកិច្ចតាមវិស័យ បានទទួលរបាយការណ៍ពីបណ្តាក្រសួង រួមមានរបាយការណ៍÷

- ស្ថិតិទេសចរណ៍ (២ខែ បន្ទាប់នៃខែថ្មី)
- ស្ថិតិសំណង់ (២ សប្តាហ៍នៃខែថ្មី)
- ស្ថិតិវិនិយោគ (២ សប្តាហ៍នៃខែថ្មី)
- ស្ថិតិកសិកម្ម (២-៣ សប្តាហ៍នៃខែថ្មី)
- ស្ថិតិឧស្សាហកម្ម និងសិប្បកម្ម (២-៣ សប្តាហ៍នៃខែថ្មី)
- ស្ថិតិ រ៉ែ និងថាមពល (២-៣ សប្តាហ៍នៃខែថ្មី)
- ស្ថិតិការងារចុះបញ្ជីយានយន្ត (២-៣ សប្តាហ៍នៃខែថ្មី)
- ស្ថិតិការងារពាណិជ្ជកម្ម (២-៣ សប្តាហ៍នៃខែថ្មី)
- ស្ថិតិការងារបណ្តុះបណ្តាលវិជ្ជាជីវៈ (២-៣ សប្តាហ៍នៃខែថ្មី)
- ស្ថិតិតារាងវឌ្ឍភាពការសាងសង់ ជួសជុល ថែទាំរចនាសម្ព័ន្ធរូបវន្ត (២-៣ សប្តាហ៍នៃខែថ្មី)
- ស្ថិតិលទ្ធផលការងារប្រៃសណីយ៍ និងទូរគមនាគមន៍ (២-៣ សប្តាហ៍នៃខែថ្មី)



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨

លទ្ធផលដែលការិយាល័យស្ថិតិសេដ្ឋកិច្ចតាមវិស័យសម្រេចបានផលិតរួមមាន÷

- កម្រងស្ថិតិប្រចាំខែ មានដូចជា ÷ ការចុះបញ្ជីយានយន្ត កសិកម្ម ឧស្សាហកម្ម និងសិប្បកម្ម រ៉ែ និងថាមពល ការចុះបញ្ជីពាណិជ្ជកម្ម និងការងារ (employment) ។
- របាយការណ៍ជាប្រចាំខែ មានដូចជា ÷ ទេសចរណ៍ សំណង់ និងវិនិយោគ ។

**១.២. ការចូលរួម**

- បានបញ្ចប់ការរៀបចំសេចក្តីព្រាងអំពី *អង្កេតតម្លៃទំនិញទីផ្សារ* និងបានចូលរួមប្រមូល និងចងក្រងទិន្នន័យ*អង្កេតតម្លៃទំនិញទីផ្សារ* ។
- ការិយាល័យស្ថិតិសេដ្ឋកិច្ចតាមវិស័យ បានរៀបចំរបាយការណ៍និងផែនការសកម្មភាពប្រចាំខែ និងត្រីមាស ព្រមទាំងផែនការសកម្មភាពរបស់ការិយាល័យ សម្រាប់ឆ្នាំ២០១៦-២០១៨ នៃ*កម្មវិធីកែទម្រង់ការគ្រប់គ្រង ហិរញ្ញវត្ថុសាធារណៈ ។*
- បានចូលរួមក្នុងការផ្តួចផ្តើមបង្កើត*ទិន្នន័យមូលដ្ឋានពាណិជ្ជកម្ម (Trade Database ២០០៨-២០១៤)* ដោយប្រើប្រាស់ទិន្នន័យ ASYCUDA ប្រភពពីអគ្គនាយកដ្ឋានគយនិងរដ្ឋករ។ គិតមកត្រឹមខែធ្នូ ឆ្នាំ២០១៥ នៃដំណាក់កាលសាកល្បងនេះ Revision ចំនួន ៥ ត្រូវបានអភិវឌ្ឍ សំដៅកែសម្រួល និងពង្រឹងគុណភាពទិន្នន័យ ឲ្យកាន់តែសុក្រឹត្យ និងជំរុញការប្រើប្រាស់នាពេលអនាគតដ៏ខ្លី ។
- បានផ្តល់ការបណ្តុះបណ្តាលជំនាញក្នុងការប្រមូល និងរៀបចំទិន្នន័យ សម្រាប់ការបង្កើត*ទិន្នន័យមូលដ្ឋាន ពាណិជ្ជកម្ម* និងការបណ្តុះបណ្តាលដល់ក្រុមការងាររបស់ការិយាល័យស្ថិតិហិរញ្ញវត្ថុ ក្នុងការចងក្រង និង ផលិតទិន្នន័យ GFS ដែលត្រូវបានបន្សីុជាមួយស្តង់ដារគណនីថ្មី (COA) ។

**១.៣. ការកសាងសមត្ថភាព**

- បានចូលរួមសិក្ខាសាលាស្តីពីស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល TOFE/GFS
- បានចូលរួមសិក្ខាសាលាស្តីពីការរៀបចំស្ថិតិ និងមូលដ្ឋាន

**១.៤. បញ្ហាប្រឈម**

- កង្វះមន្ត្រីទទួលបន្ទុកលើការងារដែលកំពុងត្រូវបានពង្រីក និងអនុវត្តបន្ថែម ។
- កង្វះខាតប្រព័ន្ធគ្រប់គ្រងទិន្នន័យ និងសំភារៈប្រើប្រាស់ (ចាស់ៗ) ។
- មន្ត្រីទទួលបន្ទុកវិស័យមួយៗនៅមានកម្រិត ដោយសារមិនមានសញ្ញាប័ត្រស្ថិតិ ឬជំនាញពាក់ព័ន្ធនឹងការអភិវឌ្ឍស្ថិតិឲ្យកាន់តែសំបូរបែប ។
- កង្វះខាតកិច្ចសហការ និងភាពជាដៃគូរវាងនាយកដ្ឋានស្ថិតិ និងស្ថាប័ណស្ថិតិដ៏ទៃទៀត ក្នុងការសម្រប សម្រួលផ្នែកទទួល និងផ្តល់ទិន្នន័យស្ថិតិតាមវិស័យឲ្យបានជាប់លាប់ និងទាន់ពេលវាលា ។

***<u>កំណត់សំគាល់÷</u>***

- ស្ថិតិតាមវិស័យដែលមិនទាន់បានផលិតជាកម្រងស្ថិតិរួមមាន÷ ស្ថិតិចុះបញ្ជីយានយន្ត តារាងវឌ្ឍភាពការសាងសង់ ជួសជុល ថែទាំរចនាសម្ព័ន្ធរូបវន្ត និងលទ្ធផលការងារប្រៃសណីយ៍ និងទូរគមនាគមន៍ ។
- របាយការណ៍ស្ថិតិដែលមិនទាន់បានទទួលមានដូចជា÷ របាយការណ៍ក្រសួងធនធានទឹក និងរដ្ឋបាលព្រៃឈើ
- របាយការណ៍ស្ថិតិទេសចរណ៍មានភាពយឺតយ៉ាវ ដោយសារមានការលំបាកក្នុងការម្របសម្រួលយកទិន្នន័យ ពីក្រសួងមហាផ្ទៃ (មានភាពយឺតជារៀងរាល់ខែ) ហើយរាល់ការទទួលទិន្នន័យបានមកពីក្រសួងទេសចរណ៍ គឺរយៈពេល២ខែបន្ទាប់នៃខែថ្មី ជាហេតុធ្វើឲ្យរបាយការណ៍ប្រចាំខែមានភាពយឺតយ៉ាវ ។

**២. សេចក្តីសន្និដ្ឋាន**

ជារួម សម្រាប់ឆ្នាំ២០១៥ នេះ លទ្ធផលដែលការិយាល័យស្ថិតិសេដ្ឋកិច្ចតាមវិស័យសម្រេចបានគួរឲ្យកត់សម្គាល់ គឺការសម្រេចបាននូវ*អង្កេតតម្លៃទំនិញទីផ្សារ* កម្រងទិន្នន័យស្ថិតិ ផែនការសកម្មភាពរបស់ការិយាល័យ សម្រាប់ឆ្នាំ ២០១៦-២០១៨ នៃ*កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ* និងសេចក្តីព្រាងព្រឹត្តប័ត្រសេដ្ឋកិច្ច ។ ព្រឹត្តប័ត្រសេដ្ឋកិច្ចនេះ រំពឹងថានឹងទទួលបានការយល់ព្រមពីថ្នាក់ដឹកនាំ ក្នុងការបោះពុម្ពនិងផ្សព្វផ្សាយ ដើមឆ្នាំ២០១៦ ។

**៣. និសដៅក្នុងឆ្នាំ២០១៦**

ស្របពេលនឹងការមកដល់នៃសមាហរណកម្មសហគមន៍សេដ្ឋកិច្ចអាស៊ាន ចុងឆ្នាំ២០១៥ តម្រូវការស្ថិតិកាន់តែទូលំទូលាយ និងទាន់ពេលវេលា គឺជាការងារចាំបាច់ និងអាទិភាព ។ ក្នុងន័យនេះ ការិយាល័យស្ថិតិសេដ្ឋកិច្ចតាមវិស័យនឹងមានតួនាទីសំខាន់ជាងមុន ក្នុងការឆ្លើយតបនឹងតម្រូវការនេះ ក៏ដូចជា ដោះស្រាយនូវបញ្ហាប្រឈមនានា ដែលការិយាល័យកំពុងប្រឈម ។

- បន្តការចូលរួមការងារស្រាវជ្រាវជាមួយ នាយកដ្ឋានម៉ាក្រូសេដ្ឋកិច្ច លើប្រធានបទថ្លៃម្ហូបអាហារ កសិកម្ម និងទេសចរណ៍ និងការងារស្រាវជ្រាវបន្ថែមផ្សេងៗទៀត ។
- បន្តយន្តការសម្របសម្រួលប្រមូលទិន្នន័យតាមវិស័យផ្សេងៗបន្ថែមទៀត ។
- បន្តកែលម្អកម្រងទិន្នន័យ និងធ្វើការវិភាគរបាយការណ៍ដែលមានស្រាប់ឲ្យមានភាពប្រសើរឡើង ។
- កម្រងស្ថិតិលទ្ធផលការងារប្រៃសណីយ៍ និងទូរគមនាគមន៍ ។
- បង្កើតឲ្យមានរបាយការណ៍សេដ្ឋកិច្ចតាមវិស័យ (ប្រចាំខែ) រួមមាន វិស័យកសិកម្ម ។
- ត្រៀមផ្តល់ជំនួយបច្ចេកទេសក្នុងការអភិវឌ្ឍ និងតាមដានស្ថិតិគ្រប់វិស័យរបស់ការិយាល័យ ទាំង ៣ ផ្សេងទៀត នៃនាយកដ្ឋានស្ថិតិ ។
- ត្រៀមផ្តល់ការបណ្តុះបណ្តាលពីចំណេះដឹងក្នុងការប្រើប្រាស់ Micro-data ។
- ត្រៀមបន្តសហការផ្តល់ជំនួយបច្ចេកទេសរៀបចំផែនការសកម្មភាពប្រចាំខែ និងត្រីមាស និងការគ្រប់គ្រង ការិយាល័យ សំដៅពង្រឹងប្រសិទ្ធភាព និងគុណភាពការងារ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោកប្រធានមេត្តាជ្រាបជាពត៌មាន ។

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥

**ប្រធាន**

**ការិយាល័យស្ថិតិសេដ្ឋកិច្ចតាមវិស័យ**

**ស្រៀង ចន្ធី**

# ច្បាប់ស្តីពីស្ថិតិ
## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

<u>មាត្រា ១</u>

ច្បាប់ស្ថិតិនេះគ្រប់គ្រងការងារទាំងឡាយ ដែលទាក់ទងដល់ការប្រមូល ការកែច្នៃ ការចងក្រង ការវិភាគ ការបោះពុម្ព និងការផ្សព្វផ្សាយទិន្នន័យស្ថិតិ ហើយមានវិសាលភាពគ្របដណ្តប់ទូទាំងព្រះរាជាណាចក្រកម្ពុជា។

<u>មាត្រា ២</u>

ពាក្យបច្ចេកទេសទាំងឡាយនៃច្បាប់នេះមានន័យដូចខាងក្រោម

ក-ស្ថិតិគឺជាទិន្នន័យដែលបានមកដោយការប្រមូល ការកែច្នៃ ការចងក្រង ការវិភាគ ការបោះពុម្ព និងការផ្សព្វផ្សាយលទ្ធផលនៃចម្លើយតាមការប្រមូលស្ថិតិ ឬពីប្រភពទិន្នន័យ រដ្ឋបាល ។

ខ- ប្រព័ន្ធស្ថិតិជាតិ គឺជាសមាហរណកម្មនៃទិន្នន័យស្ថិតិថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន និងហេដ្ឋារចនាសម្ព័ន្ធស្ថិតិ រួមបញ្ចូលទាំង ទិន្នន័យស្ថិតិផ្លូវការ និងកម្មវិធីស្ថិតិជាតិ រចនាសម្ព័ន្ធ ស្ថិតិ និង ទិន្នន័យស្ថិតិផ្លូវការ និងកម្មវិធីស្ថិតិជាតិ រចនាសម្ព័ន្ធស្ថិតិ និង អង្គភាពស្ថិតិ ក្នុងក្រសួង និងស្ថាប័ន រាជរដ្ឋា ភិបាល ព្រមទាំង មន្ត្រីស្ថិតិ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងទៀត។

គ-ស្ថិតិគ្រឹះ គឺជាស្ថិតិផ្លូវការស្តីពី សេដ្ឋកិច្ច សង្គមកិច្ច បរិស្ថាន និងប្រជាសាស្ត្រ ដែលជាស្ថិតិមានចរិតទាក់ទងនឹងផ្នែកជាច្រើន កម្រិតជាតិ មូលដ្ឋាន ដែលជាតម្រូវការរបស់ រាជរដ្ឋាភិបាលក្នុង ការរៀបចំគោលនយោបាយ កម្មវិធី និងការវាយតម្លៃក៏ដូចជា ការប្រើប្រាស់ដ៏ទូលាយរបស់សហគមន៍ជាតិ និងអន្តរជាតិ ។

ឃ-ស្ថិតិតាមវិស័យ គឺជាស្ថិតិដែលប្រមូលដោយបណ្តាក្រសួង ស្ថាប័នរាជរដ្ឋាភិបាលសម្រាប់ តម្រូវការផ្ទៃក្នុងផ្ទាល់ខ្លួន និងគោលដៅធ្វើរបាយការណ៍។

ង-ជំរឿន គឺជាការប្រមូលស្ថិតិពីបុគ្គល គ្រួសារ សហគ្រាស ឬ អង្គភាពចាត់តាំងផ្សេងទៀត ដែលអង្គភាពទាំងអស់ត្រូវបានធ្វើ សម្ភាសន៍ ។

ច-អង្កេត គឺជាការប្រមូលទិន្នន័យតាមបែបវិទ្យាសាស្ត្រ ពីបុគ្គល គ្រួសារ សហគ្រាស ឬអង្គភាពចាត់តាំងផ្សេងទៀត ដែលអង្គភាព ជ្រើសរើសគំរូ តែប៉ុណ្ណោះ ត្រូវបានសម្ភាសន៍ ។ ឆ-មន្ត្រីស្ថិតិ គឺជាមន្ត្រីរាជរដ្ឋាភិបាល ដែលមានសិទ្ធិអំណាចក្នុង ការធ្វើសកម្មភាពស្ថិតិផ្លូវការ ។

ជ-អ្នកឆ្លើយ គឺជាបុគ្គល គ្រួសារ ក្រុមហ៊ុន សហគ្រាស ស្ថាប័ន រាជរដ្ឋាភិបាល ឬក្រៅរដ្ឋាភិបាល ឬអង្គការផ្សេងទៀត ដែលត្រូវ បានជ្រើសរើស ក្នុងការជំរឿន ឬអង្កេត ។

ឈ-ទិន្នន័យ គឺជាព័ត៌មានដែលមានរូបភាពជាតួលេខ ។

ញ-"ស្ថិតិផ្លូវការដែលបានចាត់តាំង"គឺជាស្ថិតិដែលបានផលិតដោយក្រសួង ស្ថាប័នដែលកំណត់ដោយរាជរដ្ឋាភិបាល ដើម្បីបម្រើ សំណូមពរព័ត មានស្ថិតិរបស់អ្នកធ្វើគោល នយោ បាយ ក្នុងការរៀប ចំ វាយតំលៃគោលនយោបាយ និងកម្មវិធីសេដ្ឋកិច្ច សង្គម- កិច្ចដើម្បីឆ្លើយតបទៅ នឹងកិច្ចអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច របស់ ប្រទេស ក៏ដូចជាបម្រើ សេចក្តី ត្រូវការព័ត៌មានរបស់អ្នកធ្វើសេចក្តី សម្រេចចិត្ត និងអ្នកស្រាវ ជ្រាវក្នុងសហគមន៍ជាតិ និងអន្តរជាតិ ដ៏ទូលំទូលាយ ។

## ជំពូកទី ២
## គោលការណ៍ និងទិសដៅ

មាត្រា ៣

ការអភិវឌ្ឍស្ថិតិ ត្រូវឈរលើមូលដ្ឋាននៃគោលការណ៍ ៖ ភាពត្រឹមត្រូវ ភាពឯករាជ្យ ភាពសត្យានុម័ត ភាពគួរទុកចិត្តបាន ភាពសំខាន់ និងភាព ទាន់ពេលវេលា ។

មាត្រា ៤

សកម្មភាពស្ថិតិ ត្រូវដឹកនាំទៅតាមទិសដៅដូចតទៅ

ក- គាំទ្រសេចក្តីត្រូវការទិន្នន័យស្ថិតិ របស់អ្នកធ្វើគោលនយោបាយរបស់ រាជរដ្ឋាភិបាល ក្នុងការរៀបចំវាយតម្លៃគោលនយោបាយ និងកម្មវិធី សេដ្ឋកិច្ច សង្គមកិច្ច ដែលផ្តោត លើ កិច្ចអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច និងសុខុមាលភាពរបស់ប្រជាជាតិ ក៏ដូចជាសេចក្តីត្រូវការសម្រាប់អ្នក ធ្វើសេចក្តីសម្រេច និងអ្នកស្រាវ ជ្រាវក្នុង សហគមន៍ជាតិ និងអន្តរជាតិ ដ៏ទូលំទូលាយ

ខ- សម្រួលកិច្ចអភិវឌ្ឍប្រព័ន្ធស្ថិតិជាតិ ឱ្យមានសមត្ថភាព និង ប្រសិទ្ធភាព

គ- បង្កើនការយល់ដឹងជាសាធារណៈ នូវសារសំខាន់អំពីមុខងារ និង តួនាទីរបស់ស្ថិតិ នៅក្នុងកម្មវិធីអភិវឌ្ឍជាតិ

ឃ- លើកទឹកចិត្តដល់កិច្ចអភិវឌ្ឍ វិធីសាស្ត្រ និងបច្ចេកវិជ្ជានៅក្នុង សកម្មភាពស្ថិតិ ។

## ជំពូកទី ៣
## ការប្រមូលទិន្នន័យស្ថិតិ

មាត្រា ៥

ទិន្នន័យស្ថិតិត្រូវបានប្រមូលតាមរយៈ

ក- ការធ្វើជំរឿន

ខ- ការធ្វើអង្កេត

គ- ការទទួលបានទិន្នន័យរដ្ឋបាលពីប្រភពរដ្ឋាភិបាល និង មិនមែនរដ្ឋាភិបាល ។

មាត្រា ៦

ជំរឿនដូចមានចែងក្នុងមាត្រា ៥ កថាខណ្ឌ ក នៃច្បាប់នេះ ត្រូវដំណើរ ការយ៉ាងតិច មួយដង ក្នុងរ

យៈពេល១០ឆ្នាំ ។
ជំរឿនមាន ៣ ប្រភេទ
ក- ជំរឿនប្រជារាស្ត្រ
ខ- ជំរឿនកសិកម្ម
គ- ជំរឿនសហគ្រាស ។
ជំរឿនទាំងនេះ ត្រូវអនុវត្តដោយវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ សហការជាមួយស្ថាប័នពាក់ព័ន្ធ។

មាត្រា ៧

រាជរដ្ឋាភិបាលត្រូវកំណត់កាលបរិច្ឆេទ សម្រាប់ដំណើរការជំរឿនទាំងបី ដោយអនុក្រឹត្យក្នុងរយៈពេល ១០ឆ្នាំម្តង ។ កាលបរិច្ឆេទនេះ អាចធ្វើការផ្លាស់ ប្តូរបានក្នុងករណីចាំបាច់ ។

មាត្រា ៨

អង្កេតចន្លោះជំរឿនទាំងឡាយអាចត្រូវបានដំណើរការក្នុងចន្លោះជំរឿនពីរសម្រាប់ធ្វើបច្ចុប្បន្នកម្មប្រចាំឆ្នាំនូវទិន្នន័យជំរឿនគោលដើម្បីចងក្រងស្ថិតិសេដ្ឋកិច្ច និងសង្គមកិច្ចត្រឹមត្រូវ គួរទុកចិត្តបានដែលឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់អ្នកធ្វើគោលនយោបាយរបស់រាជរដ្ឋាភិបាល និងអ្នកប្រើប្រាស់នានា។

មាត្រា ៩

អង្កេតដូចមានចែងក្នុងមាត្រា ៥ កថាខណ្ឌ ខ នៃច្បាប់នេះ ត្រូវបាន ដំណើរការតាមពេលកំណត់ដើម្បីផលិតស្ថិតិជាតិ ជាគ្រឹះដ៏ត្រឹមត្រូវ គួរទុកចិត្តបាន និងជាពិសេសដើម្បី បម្រើសេចក្តីត្រូវការទិន្នន័យស្ថិតិបន្ទាន់របស់រាជរដ្ឋាភិបាល។ ក្នុងគោលបំណងធ្វើអង្កេតសេដ្ឋកិច្ច វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ ត្រូវ បង្កើតបញ្ជីពាណិជ្ជកម្ម ឬក្របខ័ណ្ឌ សរុប ដើម្បីរក្សាទុក និងធ្វើបច្ចុប្បន្នកម្មប្រចាំឆ្នាំ ។

មាត្រា ១០

កថាខណ្ឌ គ នៃច្បាប់នេះ ត្រូវចងក្រងដោយប្រើប្រាស់ទិន្នន័យកត់ត្រាក្នុង ឯកសារ តារាង និងកំណត់ត្រាផ្សេងៗដែលមានប្រភពពីរដ្ឋាភិបាល និងអង្គការ ក្រៅរដ្ឋាភិបាល ។ ក្នុងគោលដៅចងក្រងស្ថិតិ ពីប្រភពទិន្នន័យរដ្ឋបាល វិទ្យា- ស្ថានជាតិស្ថិតិ នៃក្រសួងផែនការ ត្រូវធ្វើសៀវភៅវាយឈ្មោះ និងទីតាំងរបស់ ប្រភពទិន្នន័យស្ថិតិ និងរដ្ឋបាលដែល ត្រូវថែរក្សា និងធ្វើបច្ចុប្បន្នកម្មប្រចាំឆ្នាំ ។

មាត្រា ១១

ក្នុងក្របខ័ណ្ឌនៃច្បាប់នេះ វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ មាន
ភារកិច្ចទទួលខុសត្រូវក្នុងការ ៖

-ប្រមូល កែច្នៃ ចងក្រង វិភាគ បោះពុម្ព និងផ្សព្វផ្សាយ ទិន្នន័យគ្រឹះ តាមការធ្វើជំរឿន អង្កេត និង ប្រើប្រាស់ ប្រភពទិន្នន័យរដ្ឋបាល
-ចងក្រងគណនេយ្យជាតិកម្ពុជា និងសន្ទស្សន៍ថ្លៃក៏ដូចជា សូចនាករសេដ្ឋកិច្ច សង្គមកិច្ច បរិស្ថាន និងប្រជាសាស្ត្រ។

<u>មាត្រា ១២</u>

បណ្តាក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល ត្រូវប្រមូលទិន្នន័យតាមផ្នែក ដោយខ្លួនឯង ឬដោយសហប្រតិបត្តិការជាមួយវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួង ផែនការតាម
- ការធ្វើអង្កេត
- ការប្រមូលទិន្នន័យស្ថិតិពីការកត់ត្រារដ្ឋបាល ។

**ជំពូកទី ៤**

**ការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការ**

<u>មាត្រា ១៣</u>

វិទ្យាស្ថានជាតិស្ថិតិ ស្ថិតក្រោមឱវាទក្រសួងផែនការ មានភារកិច្ចកសាង គោលនយោបាយស្ថិតិផ្លូវការ ក្នុងការបង្កើតប្រព័ន្ធស្ថិតិជាតិរួមបញ្ចូលគ្នាមួយ ដែលគ្របដណ្តប់ស្ថិតិ ផ្លូវការដែលបានចាត់តាំងទាំងអស់ និងអង្គភាពស្ថិតិក្នុង ក្រសួង ស្ថាប័ន ។ ដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ និងស្ថិតិផ្លូវការដែលបាន ចាត់តាំង ត្រូវកំណត់ដោយអនុក្រឹត្យ ។

<u>មាត្រា ១៤</u>

ក្នុងភារកិច្ចនេះ វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ ត្រូវ
ក- ធ្វើការសម្របសម្រួល ក្នុងសកម្មភាពនៃកិច្ចអភិវឌ្ឍស្ថិតិ រួមនឹងការបណ្តុះបណ្តាល ជាមួយ ក្រសួង ស្ថាប័នរាជរដ្ឋា- ភិបាល និងផ្នែកឯកជន ថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន
ខ- ធ្វើកិច្ចសហប្រតិបត្តិការ ក្នុងសកម្មភាពស្ថិតិជាមួយអង្គការ អន្តរជាតិ អង្គភាពស្ថិតិជាតិនៃ ប្រទេសនានា និងផ្នែក ឯកជននានា ទៅតាមបទប្បញ្ញត្តិច្បាប់ជាធរមាន
គ- កំណត់ស្តង់ដារស្ថិតិជាតិ ដែលទាក់ទងនឹងចំណាត់ថ្នាក់ ទស្សនទាន និយមន័យ និងអង្គពិនិត្យពិចារណាស្ថិតិ ដើម្បី ចៀសវាងការភ័ន្តច្រឡំពីសំណាក់អ្នកប្រើប្រាស់ទិន្នន័យ និង ការជាន់គ្នាក្នុងការផលិតទិន្នន័យស្ថិតិផ្លូវការ។

<u>មាត្រា ១៥</u>

ក្រុមប្រឹក្សាស្ថិតិ ត្រូវបានបង្កើតឡើងដើម្បីផ្តល់ប្រឹក្សាជូនក្រសួងផែនការ ក្នុងការជំរុញកិច្ចអភិវឌ្ឍប្រព័ន្ធស្ថិតិជាតិ ។ សមាសភាព តួនាទី និងភារកិច្ច របស់ក្រុមប្រឹក្សាស្ថិតិត្រូវកំណត់ ដោយអនុក្រឹត្យ ។

មាត្រា ១៦

គណៈកម្មាធិការសម្របសម្រួលស្ថិតិ ត្រូវបានបង្កើតឡើងដើម្បីជួយវិទ្យា-ស្ថានជាតិស្ថិតិ នៃក្រសួងផែនការក្នុងការសម្របសម្រួលផ្នែកបច្ចេកទេសស្ថិតិ ផ្លូវការរបស់រាជរដ្ឋាភិបាល ។សមាសភាព តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការសម្របសម្រួល ស្ថិតិត្រូវកំណត់ដោយអនុក្រឹត្យ ។

**ជំពូកទី ៥**

**រចនាសម្ព័ន្ធ**

មាត្រា ១៧

វិទ្យាស្ថានជាតិស្ថិតិ ជាស្ថាប័នស្ថិតិជាតិផ្លូវការ ជាអគ្គនាយកដ្ឋានចំណុះ ក្រសួងផែនការ ហើយមាននាយកដ្ឋានមួយចំនួន ទទួលខុសត្រូវសកម្មភាពស្ថិតិ ដោយឡែកៗ ។វិទ្យាស្ថាន ជាតិស្ថិតិ នៃក្រសួងផែនការ មានរចនាសម្ព័ននៅតាមខេត្ត ក្រុង ស្រុក ខ័ណ្ឌ និងឃុំ សង្កាត់។

មាត្រា ១៨

បណ្តាក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល ដែលត្រូវផលិតស្ថិតិផ្លូវការក្នុង ច្បាប់នេះ ត្រូវបង្កើតអង្គភាពស្ថិតិនៅក្នុងរចនាសម្ព័ន្ធរបស់ខ្លួន សម្រាប់បម្រើឱ្យ គោលដៅស្ថិតិ ហើយត្រូវផ្ញើ ទិន្នន័យស្ថិតិដែលផលិតបានមកវិទ្យាស្ថានជាតិស្ថិតិ នៃ ក្រសួងផែនការ។

**ជំពូកទី ៦**

**ការបោះពុម្ព និងផ្សព្វផ្សាយ**

មាត្រា ១៩

ដើម្បីបម្រើនូវសំណូមពរស្ថិតិរបស់អ្នកប្រើប្រាស់

ក- វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ ក៏ដូចជាអង្គភាពស្ថិតិនៃ ក្រសួង ស្ថាប័នផ្សេងៗទៀតរបស់រាជរដ្ឋាភិបាល ត្រូវបោះពុម្ព និងផ្សព្វផ្សាយទិន្នន័យស្ថិតិដែលបានផលិតជូន ដល់អ្នក ប្រើប្រាស់ទាំងអស់

ខ- វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ ត្រូវបោះពុម្ពព្រឹត្តិបត្រ ស្ថិតិប្រចាំឆ្នាំ ដែលគ្របដណ្តប់ទិដ្ឋភាពសំខាន់ៗ នៃល័ក្ខខ័ណ្ឌ សេដ្ឋកិច្ច សង្គមកិច្ច របស់ប្រទេស ។

មាត្រា ២០

រាល់ទិន្នន័យស្ថិតិដែលប្រកាសផ្សាយ ដោយវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួង ផែនការ គឺជាស្ថិតិផ្លូវការដែលបានចាត់តាំងដោយរាជរដ្ឋាភិបាល ។

**ជំពូកទី ៧**

**សិទ្ធិ និងកាតព្វកិច្ច**

មាត្រា២១

វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ និងអង្គភាពស្ថិតិតាមបណ្តាក្រសួង ស្ថាប័នរាជរដ្ឋាភិបាល ត្រូវបានអនុញ្ញាតឱ្យដំណើរការសកម្មភាពស្ថិតិនានា ដើម្បី ទទួលបាននូវព័ត៌មាន ស្ថិតិ ពីអ្នកឆ្លើយ

សម្រាប់ផលិតស្ថិតិផ្លូវការដោយយោងទៅតាម មាត្រា ១១ និង ១២ នៃច្បាប់នេះ ។

<u>មាត្រា ២២</u>
មន្ត្រីរាជការ បុគ្គលិក ធ្វើការនៅក្នុងវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ និងអង្គភាពស្ថិតិ ក្នុងក្រសួង ស្ថាប័នរាជរដ្ឋាភិបាល ក៏ដូចជាមន្ត្រីស្ថិតិ ដែលបាន ចាត់តាំងដោយអង្គការ ទាំងនោះ នៅពេលបម្រើការងារ ឬបំពេញភារកិច្ចក្រោម ច្បាប់នេះ ត្រូវធានារក្សាការសម្ងាត់នូវ រាល់ព័ត៌មានបុគ្គលទាំងឡាយដែលបានមក ពីអ្នកឆ្លើយ លើកលែងតែក្នុងករណី ពិសេស ដោយមានការឯកភាពពីរដ្ឋមន្ត្រីក្រសួង ផែនការ ។ ព័ត៌មានដែលប្រមូលបានក្រោមច្បាប់នេះ ត្រូវយកមកប្រើប្រាស់តែក្នុង គោលដៅស្ថិតិប៉ុណ្ណោះ ។

<u>មាត្រា ២៣</u>
មន្ត្រីស្ថិតិនៃក្រសួងផែនការ ឬក្រសួង ស្ថាប័នដទៃទៀត របស់រាជរដ្ឋា- ភិបាល មានសិទ្ធិចេញចូលក្នុងបរិវេណលំនៅដ្ឋាន ដោយមានការអនុញ្ញាតពីម្ចាស់ កម្មសិទ្ធិ ឬអ្នកស្នាក់នៅ សម្រាប់គោលដៅប្រមូលទិន្នន័យស្ថិតិ
ក- លំនៅដ្ឋាន ឬទីកន្លែងស្នាក់នៅ រួមមានផ្ទះសំបែង ឬផ្នែកនៃ ទីបរិវេណផ្សេងទៀត ដែលមានមនុស្សស្នាក់នៅដាច់ដោយឡែក ។
ខ- ទីកន្លែងផ្សេងៗទៀត ។

<u>មាត្រា ២៤</u>
មន្ត្រីស្ថិតិដែលបានចាត់តាំង ដោយក្រសួងផែនការ និងបណ្ដាក្រសួង ស្ថាប័នរាជរដ្ឋាភិបាល ត្រូវបង្ហាញលិខិតបញ្ជាបេសកកម្មរបស់ខ្លួន និងអត្តសញ្ញាណ-ប័ណ្ណផ្លូវការជូន ដល់ អ្នកឆ្លើយ ហើយត្រូវប្រកាន់អាកប្បកិរិយាសុភាពរាបសា និងវិជ្ជាជីវៈ ក្នុងការសាកសួរព័ត៌មានឱ្យបានសមស្រប ទៅតាមទំនៀមទម្លាប់ មូលដ្ឋាន និងសណ្ដាប់ធ្នាប់ សាធារណៈ ។
<u>មាត្រា ២៥</u>
អ្នកឆ្លើយទាំងឡាយ ត្រូវផ្ដល់ព័ត៌មានត្រឹមត្រូវ គ្រប់គ្រាន់ និងទាន់ពេល វេលា ជូនមន្ត្រីស្ថិតិដែលបានចាត់តាំង ដោយក្រសួងផែនការ និងបណ្ដាក្រសួង ស្ថាប័នរាជរដ្ឋាភិបាល ។

## ជំពូកទី ៨
## ទោសប្បញ្ញត្តិ

<u>មាត្រា ២៦</u>
មន្ត្រីរាជការ និងមន្ត្រីស្ថិតិដែលបានចាត់តាំងទាំងអស់ នៃក្រសួងផែនការ និងបណ្ដាក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ដែលបានប្រព្រឹត្តល្មើសនឹងមាត្រា ២២នៃច្បាប់នេះ ត្រូវផ្ដន្ទា ទោសដាក់ពន្ធនាគារពី១ខែ(មួយខែ) ដល់៦ខែ (ប្រាំមួយខែ) និងឬត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ពី ៥០.០០០ រៀល( ហាសិបពាន់រៀល ) ដល់ ២០០.០០០រៀល( ពីររយពាន់រៀល ) ។

មាត្រា ២៧

មន្ត្រីរាជការ និងមន្ត្រីស្ថិតិដែលបានចាត់តាំងទាំងអស់ នៃក្រសួងផែនការ និងបណ្តាក្រសួង ស្ថាប័ន របស់រាជរដ្ឋាភិបាល ដែលបានប្រព្រឹត្តល្មើសនឹងមាត្រា២៣នៃច្បាប់នេះ ត្រូវផ្តន្ទា ទោសដាក់ពន្ធនាគារពី១ថ្ងៃ (មួយថ្ងៃ) ដល់៦ថ្ងៃ (ប្រាំមួយថ្ងៃ) និង , ឬត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០.០០០ រៀល ( ដប់ពាន់រៀល ) ដល់ ៥០.០០០រៀល ( ហាសិបពាន់រៀល ) ។

មាត្រា ២៨

បណ្តាអ្នកឆ្លើយណា ដែលបានប្រព្រឹត្តល្មើសដោយចេតនា នឹងមាត្រា២៥ នៃច្បាប់នេះ ត្រូវផ្តន្ទា ទោសដូចតទៅ:

ក-បុគ្គល ឬមេគ្រួសារត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០.០០០រៀល(ដប់ ពាន់រៀល) ដល់ ៥០.០០០រៀល (ហាសិបពាន់រៀល) ។

ខ-នាយក ឬនិយោជិតទទួលខុសត្រូវក្នុងក្រុមហ៊ុន ឬសហគ្រាស ឬអង្គការផ្សេងទៀត ត្រូវផ្តន្ទា ទោសដាក់ពន្ធនាគារពី ១ខែ(មួយខែ) ដល់៦ខែ (ប្រាំមួយខែ) និង , ឬត្រូវផ្តន្ទាទោស ពិន័យជាប្រាក់ពី ១.០០០.០០០រៀល (មួយលានរៀល) ដល់ ៤.០០០.០០០រៀល (បួនលានរៀល) ។

មាត្រា ២៩

បុគ្គលណាដែលទប់ស្កាត់ដោយចេតនា ឬហាមឃាត់ដោយគ្មានមូលហេតុ ផ្លូវច្បាប់ មិនឱ្យសកម្មភាពស្ថិតិ ដំណើរការដោយវិទ្យាស្ថានជាតិស្ថិតិ ឬបណ្តាក្រសួង ស្ថាប័នរាជ រដ្ឋាភិបាល តាមច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ថ្ងៃ ( ប្រាំពីរថ្ងៃ ) ដល់ ១ខែ ( មួយខែ ) និង ឬត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៦០០.០០០រៀល ( ប្រាំមួយរយពាន់រៀល ) ដល់ ១.៥០០.០០០ រៀល (១លានប្រាំសែនរៀល) ។

## ជំពូកទី ៩

## អវសានប្បញ្ញត្តិ

មាត្រា ៣០

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយ នឹងច្បាប់នេះ ត្រូវចាត់ទុកជា និរាករណ៍ ។